# វគ្គទី ៦
# ចេញទៅធ្វើសង្គ្រាម
# ( ទសវត្សរ៍ឆ្នាំ ១៩៨០ )

នៅពេលដែលកងទ័ពវៀតណាម និង កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះកម្ពុជាបានវាយដណ្តើមទីក្រុងភ្នំពេញ និង ទឹកដីស្ទើរទាំងមូលនៃប្រទេសយើងមក ប្រទេសវៀតណាម ប្រកាសថាសភាពការណ៍នយោបាយនៅកម្ពុជាមិនអាចប្រែត្រឡប់វិញបានឡើយ ។ ដូចនេះក្រុមប្រទេសប្រឆាំងវៀតណាមមានជាអាទិ៍៖ ប្រទេសចិន អាស៊ាន និង សហរដ្ឋអាមេរិក បាននាំគ្នាបង្កើតរណសិរ្សមួយថ្មី ដើម្បីទប់ទល់ចំពោះដំណើរលឿនទៅមុខនៃសម្ព័ន្ធភាពវៀតណាម-សូវៀត ចូលទៅក្នុងតំបន់អាស៊ីភាគអគ្នេយ៍ ។ ប្រទេសទាំងនោះប្រកាន់ថា ការវាយប្រហារផ្តួលរំលំរបប ប៉ុល ពត ជាការរុលទៅមុខ និង ការពង្រីកឥទ្ធិពលនៃប្លុកលោកខាងកើតដែលកាលនោះមានសហភាពសូវៀតជាមេក្លោង ។ មិនយូរប៉ុន្មាន ប្រទេសកម្ពុជាបានក្លាយទៅជាសមរភូមិប្រយុទ្ធមួយ ដែលមហាអំណាចនាំគ្នាមកសាកកម្លាំង និងរុញច្រានដណ្តើមយកប្រទេសខ្មែរជារណបរៀងៗខ្លួន ។ ឯប្រជាពលរដ្ឋខ្មែរជាទូទៅក៏ក្លាយជាចំណាប់ខ្មាំងនៃការដណ្តើមឥទ្ធិពលគ្នានេះ ។

## ចិន និង អាស៊ាន ត្រៀមកម្លាំងវាយបក

ក្រុមចលនាប្រទេសប្រឆាំងវៀតណាម ជាពិសេស ប្រទេសចិន នៅពេលនោះ ត្រូវការរៀបចំកងទ័ពខ្មែរក្រហមជាថ្មីឡើងវិញដែលយ៉ាងហោចណាស់ ក៏អាច

ឆាផៅបុករុករំខានកងទ័ពវៀតណាម ឲ្យចូលមកធ្វើការចរចាស្វែងរកដំណោះស្រាយបញ្ចប់ជម្លោះជាមួយពួកគេដែរ ។ បន្ថែមលើនេះ នៅសម័យនោះ ក្រុមប្រទេសប្រឆាំងវៀតណាមទាំងនោះ ក៏មានការយល់ឃើញថា អ្នកដឹកនាំខ្មែរទាំងឡាយណា ក្រៅពីក្រុមខ្មែរក្រហមចេញ ដែលអាចឲ្យប្រជាពលរដ្ឋខ្មែរជឿទុកចិត្ត និង ដែលអាចទទួលការគាំទ្រពីសហគមន៍អន្តរជាតិបាន ត្រូវតែចូលមកដឹកនាំចលនាតស៊ូខ្មែរប្រឆាំងនឹងវៀតណាមនេះ ។ នៅសម័យនោះ គេសម្លឹងឃើញមេដឹកនាំខ្មែរមិនមែនកុម្មុយនីស្ត ជាពិសេសសម្តេច សីហនុ និង លោកតា សឺន សាន ។ គេយល់ឃើញថា កងទ័ពខ្មែរក្រហមត្រូវតែពង្រឹងសមត្ថភាពសាជាថ្មីឡើងវិញ ។ ចំណែកយុទ្ធជនខ្មែរមិនមែនកុម្មុយនីស្តដែលនៅបែកខ្ញែកគ្នាត្រូវតែរួបរួមគ្នាឡើង ។ ក្នុងផ្នែកការទូត ចលនាតស៊ូត្រូវតែអង្គុយលើអាសនៈជាតំណាងប្រទេសកម្ពុជានៅអង្គការសហប្រជាជាតិ ។ ដូច្នេះកិច្ចការជាបន្ទាន់ ដែលក្រុមប្រទេសប្រឆាំងវៀតណាមជាពិសេស សហរដ្ឋអាមេរិក និង អាស៊ាន ត្រូវធ្វើនោះគឺ ត្រូវជួយរៀបចំចលនាតស៊ូខ្មែរមិនមែនកុម្មុយនីស្តឲ្យរឹងមាំ ដោយសារខ្មែរក្រហមកំពុងតែបាត់បង់នូវការគាំទ្រពីប្រជាពលរដ្ឋខ្មែរ និង ពីសហគមន៍អន្តរជាតិ ។

អ្នកដឹកនាំ រ.ជ.រ.ប.ខ. បានប្រមើលឃើញថា មានចរន្តនៃការបង្រួបបង្រួមអ្នកតស៊ូមិនមែនកុម្មុយនីស្ត ។ អ្នកដឹកនាំទាំងនោះ ក៏បានសាកល្បងចាប់ផ្តើមជំរុញពង្រឹងកម្លាំងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ឲ្យក្លាយទៅជាចលនាខ្មែរអ្នកជាតិនិយមតែមួយគត់ ជាជំនួសកម្លាំងខ្មែរក្រហម ។ នៅថ្ងៃទី ២៣ វិច្ឆិកា ១៩៧៩ ប្រធាន រ.ជ.រ.ប.ខ. បានបើកសន្និសីទសារព័ត៌មានមួយនៅលើទឹកដីខ្មែរ លើកសំណើសុំឲ្យយុទ្ធជនប្រដាប់អាវុធទាំងអស់ រួមទាំងយុទ្ធជននៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាផង ដែលកំពុងនៅជាមួយកងទ័ពវៀតណាមឲ្យជួបជុំគ្នាជាបន្ទាន់ ដើម្បីធ្វើការសិក្សាស្វែងរកកិច្ចព្រមព្រៀងរួមគ្នាមួយ ឈានទៅបញ្ចប់ទុក្ខ

វេទនារបស់ប្រជាពលរដ្ឋខ្មែរ និង កសាងឡើងវិញនូវប្រទេសកម្ពុជាឯករាជ្យ ដែលខ្មែរម្នាក់ៗអាចទទួលយកបាន ។ ទីកន្លែងជួបប្រជុំគ្នាអាចធ្វើនៅក្នុងតំបន់អព្យាក្រឹតមួយក៏បាន ឬ នៅទីក្រុងប៉ារីសប្រទេសបារាំងក៏បាន[107] ។

រ.ជ.រ.ប.ខ. បានគាំទ្រសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ១៩៧៩ ដែលមានចំណុចសំខាន់ៗដូចតទៅៈ - អំពាវនាវឲ្យគ្រប់ភាគីនៅក្នុងជម្លោះសហការគ្នាតាមគ្រប់មធ្យោបាយដែលអាចធ្វើបាន ដើម្បីសម្រួលដល់ការខំប្រឹងប្រែងផ្នែកមនុស្សធម៌ (ចំណុច ៤) - អំពាវនាវសូមឲ្យភាគីទាំងអស់នៅក្នុងជម្លោះ បញ្ចប់ជម្លោះ(ចំណុចទី ៦) - អំពាវនាវឲ្យមានការដកកងទ័ពបរទេសចេញពីកម្ពុជាព្រមទាំងអំពាវនាវដល់រដ្ឋទាំងអស់មិនត្រូវឈ្លានពាន ឬ ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសនៅអាស៊ីភាគអាគ្នេយ៍ឡើយ (ចំណុច ៧) - អំពាវនាវដល់រដ្ឋទាំងអស់ មិនត្រូវជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសកម្ពុជា (ចំណុច ៩) -សំរេចថាប្រជាពលរដ្ឋខ្មែរ ត្រូវមានសិទ្ធិជ្រើសរើសរដ្ឋាភិបាលរបស់ខ្លួនតាមលទ្ធិប្រជាធិបតេយ្យ ដោយគ្មានការជ្រៀតជ្រែកពីខាងក្រៅ (ចំណុច ១០) និង -ស្នើឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិស្វែងរកគ្រប់លទ្ធភាព ដើម្បីរៀបចំសន្និសីទអន្តរជាតិមួយស្តីពីកម្ពុជា ដែលជាមធ្យោបាយមួយនៃការអនុវត្តសេចក្តីសំរេចនេះ (ចំណុច ១២) ។ តាមពិតទៅ ការប្រកាសបង្កើត រ.ជ.រ.ប.ខ. នៅថ្ងៃទី ៩ តុលា ១៩៧៩ គឺធ្វើឡើងឲ្យទាន់ពេលវេលា ដើម្បីត្រៀមចូលរួមប្រជុំសន្និសីទមួយនៃអង្គការសហប្រជាជាតិ ដែលត្រូវកោះប្រជុំ និង ចេញសេចក្តីសំរេចនៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧៩ ខាងមុខ ។

នៅសម័យនោះ ក្រុមអ្នកជាតិនិយមគឺ ក្រុមមិនមែនកុម្មុយនីស្តត្រូវការឲ្យមានការចាត់តាំងរឹងមាំ និង មានឯកភាពគ្រប់គ្រាន់ ដើម្បីប្រមូលកម្លាំងគ្រប់យ៉ាង

[107] Son Sann, President of the Khmer People's National Liberation Front, Press Conference, Khmer Territory, November 23, 1979.

និង ធនធានគ្រប់ប្រភេទ ។ នៅពេលនោះ ប្រសិនបើលោកតា សឺន សាន និង សម្តេច សីហនុ អាចរួបរួមគ្នាក្នុងចលនាតស៊ូតែមួយបាននោះគឺជាមហាសាមគ្គីភាពដ៏ប្រពៃបំផុត ។ ក៏ប៉ុន្តែអស់រយៈពេលជាច្រើនខែកន្លងមក ឥស្សរជនធំៗទាំងពីររូបបានជ្រើសរើសផ្លូវដើរទីទៃៗពីគ្នា ដែលនាំឲ្យមានការរិះគន់ពីមជ្ឈដ្ឋាននានា ។ នៅក្នុងសន្និសីទសារព័ត៌មានមួយនៅលើទឹកដីខ្មែរនាភូមិសុខសាន្តលោកតា សឺន សាន ថ្លែងថា ជាច្រើនលើកច្រើនសារលោកតាបានស្នើទូលថ្វាយសម្តេច សីហនុ ឲ្យយាងមកដឹកនាំរ.ជ.រ.ប.ខ ។ ពេលស្នើចុងក្រោយនោះគឺ នៅខែ មីនា ១៩៧៩ ពេលដែលព្រះអង្គប្រកែកមិនព្រមទទួលតួនាទីដឹកនាំរបស់រណសិរ្សនេះ ។

## មេដឹកនាំអ្នកជាតិនិយមប៉ះទង្គិចពាក្យសំដីគ្នា

ប៉ុន្មានខែមុននោះ សម្តេច សីហនុ បានទ្រង់បង្កើតចលនាតស៊ូរបស់ព្រះអង្គនៅទីក្រុងព្យុងយ៉ាងដែលមានឈ្មោះថាសហព័ន្ធខ្មែរអ្នកជាតិនិយម ដោយទ្រង់បានប្រមែប្រមូលសមាគមខ្មែរក្រៅប្រទេសមួយចំនួន ។ នៅទីក្រុងប៉ារីស កាសែតបារាំងខ្លះរាប់ទាំងកាសែតឡឺម៉ុង (Le Monde) ផង បានធ្វើការផ្សព្វផ្សាយសេចក្តីថ្លែងការណ៍ និង សេចក្តីអំពាវនាវរបស់លោកតា សឺន សាន ជាពិសេស កាសែតឡឺម៉ុងចេញថ្ងៃទី ១៨ ធ្នូ ១៩៧៩ ។ កាសែតផ្សាយថាសម្តេច សីហនុ ប្រកែកមិនព្រមដឹកនាំ រ.ជ.រ.ប.ខ. នោះ ព្រោះព្រះអង្គយល់ថាមិនទាន់ដល់ពេលវេលា ប៉ុន្តែ ក្រោយមកព្រះអង្គបែរជាបង្កើតសហព័ន្ធខ្មែរអ្នកជាតិនិយម ជាចលនាផ្ទាល់របស់ព្រះអង្គទៅវិញ ។ ការផ្លាស់ប្តូរព្រះទ័យរបស់ព្រះអង្គត្រូវបានលោកតា សឺន សាន ធ្វើការរិះគន់យ៉ាងខ្លាំង ។ កាសែតឡឺម៉ុង បានចុះផ្សាយសំដីលោកតា សឺន សាន ថា "នៅពេលដែលសម្តេច សីហនុ ដូរព្រះទ័យចុះឡើងនេះ មានខ្មែរទាំងស្រីទាំងប្រុសកំពុងស្លាប់ជារៀងរាល់ថ្ងៃ ។ យុទ្ធជនអ្នកតស៊ូដែលកាន់អាវុធតាំងពីឆ្នាំ ១៩៧៥

រៀងមក មិនព្រមទម្លាក់អាវុធ ដូចសម្តេចចង់បាននោះទេ និង មិនខ្លាចស្លាប់ក្នុងការធ្វើដំណើរជ្រៀតចូលជ្រៅទៅក្នុងទឹកដីខ្មែរ ដើម្បីនាំស្បៀងទៅផ្តល់ជូនប្រជាពលរដ្ឋខ្មែរដែលកំពុងមានការខ្វះខាត ។ តើយើងត្រូវរង់ចាំឬ? តើ ត្រូវនៅត្រេងត្រាងឬ? ឬ ត្រូវលោតចុះទៅក្នុងទឹក ដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋ ខ្មែរដែលកំពុងលង់ទឹកនោះ? ខ្ញុំ (សឺន សាន) បានសុខចិត្តមករួបរួមជាមួយយុទ្ធជនទាំងនោះ ។ ខ្ញុំមិនបានបង្ខំពួកគេទេ ឬ ដាក់លក្ខខណ្ឌណាដល់ពួកគេទេ ពួកយើងធ្វើការសម្រេចរួមគ្នា" ។ នៅក្នុងកាសែតនោះលោកតា សឺន សាន បន្តទៀត ថា៖ "ពួកយើងកំពុងបន្តនូវអ្វីដែលយើងបានចាប់ផ្តើមធ្វើ ។ ប្រសិនបើអ្នកឯទៀតចង់ចូលមកជួយតាមផ្លូវណាក៏ដោយ អ្នកទាំងនោះអាចធ្វើបានដោយសេរី ទោះជាត្រូវធ្វើសកម្មភាពផ្សេងគ្នាក៏ដោយ ព្រោះសកម្មភាពរបស់គេ និង សកម្មភាពរបស់យើង សុទ្ធតែអាចបំពេញឲ្យគ្នាទៅវិញទៅមកបាន" ។ នៅសម័យនោះ អ្នកជិតជិត និង លោកតា សឺន សាន ដែលមិនចូលចិត្តសម្តេច សីហនុ តែងព្យាយាមអូសទាញលោកតាឲ្យដើរតួជាអ្នកប្រណាំងប្រជែងជាមួយសម្តេច ក្នុងការដឹកនាំចលនាតស៊ូអ្នកជាតិនិយមមិនមែនកុម្មុយនីស្ត ។ ពួកគេតែងបន្ទោសព្រះអង្គថាជាអ្នកទទួលខុសត្រូវកំពូលដែលនាំឲ្យមានវិបត្តិធ្ងន់ធ្ងរដល់ប្រទេសជាតិយ៉ាងនេះ ។ ចំណែកឯសម្តេច សីហនុ វិញ ព្រះអង្គក៏ពិតជាមានការលំបាកក្នុងទទួលយកការដឹកនាំរណសិរ្សរបស់លោកតា សឺន សាន ព្រោះនៅក្នុងរណសិរ្សនោះ នាយទាហានជាន់ខ្ពស់មួយចំនួន រាប់តាំងពីឧត្តមសេនីយ ដៀន ដែល ផង សុទ្ធតែជាអ្នកសាធារណរដ្ឋដែលមានសមានចិត្តតិចតួចណាស់ចំពោះព្រះអង្គ ។ ការយកថ្ងៃទី ៩ តុលា ១៩៧៩ ជាថ្ងៃប្រកាសបង្កើតរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ អាចធ្វើឲ្យសម្តេចឈ្វេងយល់ថារណសិរ្សនេះមានគោលដៅនាំយករបបសាធារណរដ្ឋមកវិញ ព្រោះថ្ងៃ ៩ តុលា ជាថ្ងៃខួបកំណើតនៃសាធារណរដ្ឋរបស់លោកសេនាប្រមុខ លន់ នល់

ដែលបានផ្តួលរំលំរបបរាជានិយមរបស់ព្រះអង្គ ។ សាធារណរដ្ឋខ្មែរត្រូវបានប្រកាសឡើងជាលើកទី១នៅថ្ងៃទី ៩ តុលា ឆ្នាំ ១៩៧០ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេច សីហនុ នៅថ្ងៃទី ១៨ មីនា ១៩៧០ ។ ដូច្នេះការស្នើយាងព្រះអង្គឲ្យមកដឹកនាំរ.ជ.រ.ប.ខ.របស់លោកតា សឺន សាន នោះ អាចត្រូវបកស្រាយថាជាសំណើលាក់ពុត មិនមែនដោយចិត្តបរិសុទ្ធឡើយ ។ ម្យ៉ាងទៀត សម្តេចក៏ប្រកាន់ឥរិយាបថមួយថាក្នុងឋានៈព្រះអង្គជាអតីតមហាក្សត្រ និង មេដឹកនាំខ្មែរផង ព្រះអង្គត្រូវគង់នៅឲ្យផុតពីជម្លោះ ដែលអាចជាស្ពានផ្សារភ្ជាប់គូបដិបក្ខ ក្នុងដំណោះស្រាយនយោបាយណាមួយ ដែលអាចកើតមាននាពេលខាងមុខ ។ ជាមួយគ្នានោះដែរ ការគាំទ្ររបស់ប្រទេសថៃ និង អង្គការប្រទេសអាស៊ាន ជាការគាំទ្រចាំបាច់បំផុតសំរាប់ចលនាតស៊ូមិនមែនកុម្មុយនីស្ត ។ នៅសម័យនោះ សម្តេច សីហនុ មិនទាន់ទទួលបាននូវការគាំទ្រទាំងអស់នោះនៅឡើយទេ ។

## ខ្មែរក្រហមខំកែមុខមាត់ថ្មី

ចំពោះពួកខ្មែរក្រហមវិញ ពួកគេក៏ចាប់ផ្តើមធ្វើការផ្សព្វផ្សាយអំពីការផ្លាស់ប្តូរក្នុងកងទ័ព និង ក្នុងរដ្ឋាភិបាលរបស់គេដែរ ។ លោក ខៀវ សំផន ត្រូវទទួលបានមុខនាទីនយោបាយដ៏សំខាន់គឺ ជាប្រធាន និង ជានាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ក៏ប៉ុន្តែ ប៉ុល ពត នៅតែបន្តកាន់អំណាចជាប្រធានកងទ័ពដដែល។ សមាជិកឯទៀតនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមាន៖[108] លោក អៀង សារី ជាឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការបរទេស លោក សុន សេន ជាឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីការពារប្រទេស លោក ដួន ជុំ ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច លោកស្រី អៀង ធីរិទ្ធ ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច លោកស្រី យន់ យ៉ាត

[108] Alan Dawson, New Khmer Rouge govt announced, Lineup, Bangkok Post, December 28, 1979.

ជារដ្ឋមន្ត្រីក្រសួងអប់រំ លោក គាត ឈន់ រដ្ឋមន្ត្រីប្រចាំទីស្តីការគណៈរដ្ឋមន្ត្រី លោក ជួន ម៉ុម ជារដ្ឋមន្ត្រីក្រសួងវិទ្យាសាស្ត្រ លោក ធុច រិន ជារដ្ឋលេខាធិការក្រសួងព័ត៌មាន លោក ស គិមល្មុត ជារដ្ឋលេខាធិការក្រសួងបរិក្ខារ និង ដឹកជញ្ជូន លោក ឈន ហៃ រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍[109] ។

ការរៀបចំសមាសភាពគណៈរដ្ឋមន្ត្រីថ្មីរបស់ពួកខ្មែរក្រហមនោះគឺ ជាការសាកល្បងរបស់ពួកគេ ដើម្បីបង្ហាញមុខមាត់ថ្មីនៃថ្នាក់ដឹកនាំដែលត្រូវចោទប្រកាន់ថាមានដៃប្រឡាក់ឈាម ។ គួរបញ្ជាក់ថារដ្ឋមន្ត្រីខ្មែរក្រហមពីរនាក់គឺ លោក ជួន ជុំ ជួន ម៉ុម និង មន្ត្រីការទូតជាន់ខ្ពស់របស់ខ្មែរក្រហមឈ្មោះ ជួន ប្រសិទ្ធ សុទ្ធតែជាបងប្អូននឹងគ្នា ដែលចេញពីត្រកូលឧកញ៉ាវាំង ជួន ដែលជាមន្ត្រីធំម្នាក់ធ្លាប់មានឥទ្ធិពលស្មើរស្មើស្តេចផែនដី ក្នុងសម័យព្រះករុណាព្រះបាទ ស៊ីសុវត្ថិ និង ព្រះបាទ មុនីវង្ស ព្រោះតែឧកញ៉ាវាំង ជួន បានទទួលការគាំទ្រពីអាជ្ញាធរអាណាព្យាបាលបារាំងប្រចាំប្រទេសកម្ពុជា ។ នៅពេលក្រោយៗមក ទើបខ្ញុំដឹងថា លោកតា ឈាន វ៉ម ដែលកាលនោះជាអនុប្រធាន រ.ជ.រ.ប.ខ. ក៏ជាបងប្អូនថ្លៃរបស់បងប្អូន ជួន ទាំង ៣ នាក់នេះដែរ ។

## រត់ការឲ្យបងថ្លៃស្រី បានចេញពីជំរុំ

ក្រៅពីការងារដ៏មមាញឹក ដើម្បីជួយគាំទ្ររ.ជ.រ.ប.ខ. នោះ ខ្ញុំក៏ត្រូវជាប់រវល់ និង មានកង្វល់យ៉ាងខ្លាំងក្នុងការជួយដោះស្រាយបញ្ហាបងថ្លៃស្រីរបស់ខ្ញុំគឺទេពធីតា ដែលទើបធ្វើដំណើរមកដល់ជំរុំជនភៀសខ្លួនឯជាយដែន ។ តាំងពីបានទទួលសំបុត្រពីគាត់កាលណា ខ្ញុំយល់ថា ខ្ញុំមានការទទួលខុសត្រូវទាំងស្រុងក្នុងការជួយ

[109] Alan Dawson, New Khmer Rouge govt announced, Lineup, op. cit.

ជ្រោមជ្រែងបងស្រី ទេពធីតា ឲ្យបានចេញពីជំរុំជនភៀសខ្លួន ។ ខ្ញុំក៏ចាប់ផ្ដើមរត់ការធ្វើសំបុត្រស្នាម គ្រប់យ៉ាងនៅសាលាក្រុងស្តាំង (Stains) ដើម្បីធានាយកបងស្រី ទេពធីតា មកប្រទេសបារាំង ។ តាមពិតទៅ បងថ្លៃស្រីរបស់ខ្ញុំនោះមិនមែនមកដល់ជំរុំជនភៀសខ្លួនតែម្នាក់ឯងនោះទេគឺ គាត់មកជាមួយបុរសម្នាក់ឈ្មោះ សេង លាងហាក់ ដែលកាលនោះមានអាយុ ៣៨ ឆ្នាំ ។ បុរសនោះ ជាអ្នកស្រុកភូមិស្នាយពលរបស់ខ្ញុំដែរ ហើយដែលស្រឡាញ់បងទេពធីតា នៅពេលដែលរបប ប៉ុល ពតត្រូវដួលរលំទៅ ។ ដោយកាលនោះ ខ្ញុំមិនបានដឹងទំនាក់ទំនងរបស់អ្នកទាំងពីរនោះ ខ្ញុំសរសេរឈ្មោះ សេង លាងហាក់ នោះថាជាបងប្អូនជីដូនមួយរបស់បង ទេពធីតា នៅក្នុងសំបុត្រធានារបស់ខ្ញុំ ។ ខ្ញុំខិតខំសរសេរសំបុត្រទៅស្ថានទូតបារាំងនៅទីក្រុងបាងកក ដើម្បីសុំទិដ្ឋាការឲ្យក្រុមគ្រួសារបងទេពធីតា បានមករស់នៅៗប្រទេសបារាំង ។ ក្នុងពេលនោះ ខ្ញុំក៏សរសេរសំបុត្រទៅក្រុមកាកបាទក្រហមអន្តរជាតិ ឲ្យជួយធ្វើអន្តរាគមន៍ ដើម្បីឲ្យគ្រួសារបងថ្លៃស្រីរបស់ខ្ញុំនោះ បានមករស់នៅជាមួយខ្ញុំឯប្រទេសបារាំងដែរ ។ ក៏ប៉ុន្តែសំបុត្រទាំងអម្បាលម៉ានរបស់ខ្ញុំនោះ ពុំដែលមានចម្លើយឆ្លើយតបមកវិញឡើយ ។

ខ្ញុំចេះតែបន្តសរសេរសំបុត្រទៅអាជ្ញាធរបារាំងនៅទីក្រុងប៉ារីស និង នៅទីក្រុងបាងកកឲ្យជួយផ្ដល់ទិដ្ឋាការដល់ពួកគេ ។ ជាមួយនោះ ខ្ញុំក៏ផ្ដល់លុយកាក់ខ្លះដល់អ្នកទាំងនោះដែរ ។ ជីវភាពរស់នៅរបស់ជនភៀសខ្លួននៅក្នុងជំរុំឈ្មោះជំរុំមានជ័យ០០៧ ជួបប្រទះគ្រោះថ្នាក់ខ្លាំងណាស់ ដោយសារមានជនប្រដាប់អាវុធជាច្រើនក្រុម ដែលគ្មានសណ្ដាប់ធ្នាប់ ។ នៅពេលមានជម្លោះបន្តិចបន្តួចក៏ធ្វើឲ្យមានការផ្ទុះអាវុធបាញ់សម្លាប់គ្នាភ្លាម ដោយមិនទាន់និយាយពីអំពើលួចប្លន់ និង រំលោភលើនារីភេទផង ។ មេដឹកនាំរបស់ជំរុំ០០៧ នោះ មិនបានចូលរួមជាមួយរ.ជ.រ.ប.ខ. ទេ ។ ម្យ៉ាងទៀត ជនភៀសខ្លួនដ៏ស្លូតត្រង់ទាំងនោះមិនត្រឹមតែភ័យបារម្ភអំពីសុវត្ថិ

ភាពក្នុងការរស់នៅក្នុងជំរុំតែប៉ុណ្ណោះទេ ក៏ប៉ុន្តែនៅមានក្តីបារម្ភជាប់ជានិច្ចខ្លាចក្រែងអាជ្ញាធរថៃចាប់បញ្ជូនទៅចាក់ចោលនៅឯតំបន់ព្រះវិហារថែមទៀត ។ ក្នុងពេលមុននោះបន្តិច ពួកទាហានថៃបានបញ្ជូនជនភៀសខ្លួនខ្មែរទៅឲ្យស្លាប់រាប់ពាន់នាក់រួចទៅហើយគឺស្លាប់ដោយអត់អាហារ ឬ ថ្នាំពេទ្យ ឬ ជាន់មីន នៅតំបន់ព្រះវិហារ ។ តាមពិតទៅ ជនភៀសខ្លួនរស់នៅក្នុងជំរុំមានការភិតភ័យជាប់ជានិច្ច ព្រោះចេះតែឮពាក្យចចាមអារាមកំញើញគំរាមឥតឈប់ឈរ ។ ជាភ័ព្វសំណាងល្អបងថ្លៃស្រីរបស់ខ្ញុំនោះមិនបានស្នាក់អាស្រ័យយូរប៉ុន្មានទេនៅក្នុងជំរុំ ០០៧ នោះ ។ ពីរ ឬ បីសប្តាហ៍ក្រោយមកខាងគ្រួសារថ្មីរបស់គាត់ បាននាំបងថ្លៃស្រីខ្ញុំនោះ ចេញមករស់នៅក្នុងជំរុំ ខៅ-អ៊ី-ដាង នៅក្នុងទឹកដីថៃវិញ ។

នៅក្នុងលិខិតរបស់គាត់នាខែ កុម្ភៈ ១៩៨០ នោះ បងទេពធីតា បានផ្ញើសំបុត្រមកខ្ញុំចេញពីជំរុំថ្មី ខៅ-អ៊ី-ដាងតែម្តង ។ នៅក្នុងសំបុត្រនោះ បងថ្លៃស្រីរបស់ខ្ញុំសំដែងការព្រួយបារម្ភខ្លាចអាជ្ញាធរថៃមិនអនុញ្ញាតឲ្យចេញពីជំរុំនេះ ព្រោះឮពាក្យចចាមអារាមថា ជនភៀសខ្លួននឹងត្រូវរស់នៅក្នុងជំរកសង់អំពីឈើ ដែលអាចជាសញ្ញាថា អ្នកទាំងនោះអាចនឹងត្រូវស្នាក់អាស្រ័យនៅៗក្នុងជំរុំសំរាប់រយៈពេលវែង ។ នេះគ្រាន់តែជាពាក្យចចាមអារាមតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត បងស្រីទេពធីតាឃើញជនភៀសខ្លួន ដែលមានលុយកាក់មានទ្រព្យសម្បត្តិស្តុកស្តម្ភ គេអាចរត់ការចេញទៅប្រទេសទីបីបានភ្លាមៗ ។ ជាមួយគ្នានេះដែរ ទីតាំងជំរុំ ខៅ-អ៊ី-ដាង ក៏ស្ថិតនៅមិនឆ្ងាយពីព្រំដែន ដែលគេអាចឮសម្លេងគ្រាប់ផ្លោង ឬ គ្រាប់កាំភ្លើងនៅពេលប្រយុទ្ធគ្នាបាន ។ ទាំងនេះសុទ្ធតែជាមូលហេតុធ្វើឲ្យបងថ្លៃស្រីខ្ញុំចង់ចេញពីជំរុំនេះឲ្យបានឆាប់ ។ បងទេពធីតា ស្នើឲ្យខ្ញុំទាក់ទងជាមួយមន្ត្រីរបស់រ.ដ.រ.ប.ខនៅប្រទេសថៃ ដើម្បីជួយធ្វើអន្តរាគមន៍ឲ្យគាត់បានចេញពីជំរុំឆាប់ៗ និង ឲ្យបានធ្វើដំណើរទៅរស់នៅឯប្រទេសបារាំងបានជាបន្ទាន់ ។

ក៏ប៉ុន្តែនាសម័យនោះ ខ្ញុំមិនមានបំណងចង់ឲ្យអង្គការ រ.ជ.រ.ប.ខ.មកជាប់ជំពាក់ក្នុងបញ្ហាផ្ទាល់ខ្លួនរបស់ខ្ញុំឡើយ ។ ខ្ញុំគិតថាការចូលមកជួយ រ.ជ.រ.ប.ខ.គឺជាការចូលរួមចំណែកមួយរបស់ខ្ញុំ ដើម្បីរំដោះជាតិ មិនមែនដើម្បីយក រ.ជ.រ.ប.ខ. មកធ្វើការជាប្រយោជន៍ឯកជននោះឡើយ ។ ម្យ៉ាងទៀត ខ្ញុំក៏មិនបានដឹងថាអាចមានថ្នាក់ដឹកនាំណារបស់ រ.ជ.រ.ប.ខ. ដែលអាចមានឥទ្ធិពលជួយដោះស្រាយនាំជនភៀសខ្លួនចេញពីជំរុំថៃបានឡើយ ។ បើពិចារណាឲ្យហ្មត់ចត់ទៅ រ.ជ.រ.ប.ខ. មានបេសកកម្មរំដោះប្រទេស ប្រសិនបើ រ.ជ.រ.ប.ខ. គិតតែពីនាំជនភៀសខ្លួនចេញពីជំរុំ ទៅប្រទេសទីបីនោះ ធ្វើដូចម្តេចអាចនឹងសំរេចបេសកកម្មរបស់ខ្លួនបាន ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំក៏ខិតខំសរសេរសំបុត្រទៅក្រសួងការបរទេសបារាំងសុំឲ្យរដ្ឋាភិបាលបារាំង ជួយធ្វើអន្តរាគមន៍យកគ្រួសារថ្មីរបស់បងថ្លៃស្រីខ្ញុំ បានមករស់នៅឯប្រទេសបារាំង ។ ជាថ្មីទៀត សំបុត្ររបស់ខ្ញុំក៏នៅតែគ្មានចម្លើយ ។ ខ្ញុំមានការពិបាកក្នុងចិត្តជាខ្លាំង ព្រោះខ្ញុំមិនអាចជួយបងទេពធីតាឲ្យបានសំរេចដូចបំណង ។ ខ្ញុំនឹកថាខ្ញុំជាសាច់ញាតិម្នាក់របស់គាត់ដែលនៅរស់ក្នុងប្រទេសបារាំង ដែលគួរតែអាចជួយយកមកបាន ព្រោះខ្ញុំស្គាល់គេស្គាល់ឯងច្រើនណាស់នៅសម័យនោះ ។ ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំក៏មានការខកចិត្តយ៉ាងខ្លាំងណាស់ដែរ ។

នៅក្នុងសំបុត្រមួយនោះ បងទេពធីតាបានរៀបរាប់ថាក្រុមគ្រួសារគាត់ និងក្រុមគ្រួសារខ្ញុំបានធ្វើដំណើរត្រឡប់ទៅស្រុកកំណើតខ្ញុំទាំងអស់គ្នា ក្រោយដែលភ្នំពេញត្រូវដួលរលំភ្លាម ។ ក្នុងចំណោមសំបុត្រជាច្រើនច្បាប់ សំបុត្រមួយច្បាប់បានរៀបរាប់អំពីស្ថានភាពរបស់ក្រុមគ្រួសារគាត់ និង ក្រុមគ្រួសារខ្ញុំ នៅពេលដែលបែកភ្នំពេញភ្លាម ។ បន្ទាប់ពីបានទៅដល់ភូមិស្នាយពលមួយថ្ងៃ ពួកខ្មែរក្រហមបានកោះហៅឪពុកគាត់ និង ឪពុកមារបស់ខ្ញុំដែលជាស្វាមីអ្នកគ្រូសាម៉ុឌី ឲ្យទៅរៀន

សូត្រទាំងយប់ ។ តាំងពីពេលនោះមក ពួកគាត់ក៏បាត់ដំណឹងរហូត ។ នៅពេលនោះបងទេពធីតា និង បងស៊ីនឿនក៏បាននាំទារិកាជាកូនស្រីដែលទើបនឹងកើតបានបួន ឬ ប្រាំថ្ងៃមុននោះ ទៅជាមួយឯស្រុកកំណើតរបស់ខ្ញុំដែរ ។ ដោយសារខ្វះទឹកដោះ និង ខ្វះថ្នាំពេទ្យ ទារិកានោះក៏បាត់បង់ជីវិតទៅ ។ នៅឆ្នាំ ១៩៧៧ ពួកខ្មែរក្រហមបានបញ្ជូនបងប្រុសស៊ីនឿនឲ្យទៅរៀនសូត្រនយោបាយ ហើយក៏ត្រូវពួកខ្មែរក្រហមបញ្ឆោតយកទៅសម្លាប់ចោលទៅ ។ ប៉ុន្មានខែក្រោយមកទៀត ម្ដាយ និង បងស្រីរបស់បងទេពធីតា ក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់យ៉ាងសាហាវព្រៃផ្សៃជាទីបំផុត ។

តាមការរៀបរាប់របស់បងថ្លៃស្រីរបស់ខ្ញុំនោះ ខ្មែរក្រហមជាទូទៅសុទ្ធតែមាននយោបាយកាប់សម្លាប់ប្រជាពលរដ្ឋឯងទាំងអស់ ។ បន្ទាប់ពីរបប ប៉ុល ពត បានដួលរលំ បងថ្លៃស្រីខ្ញុំក៏បានរៀបការជាមួយលោក សេង លាងហាក់ ដែលបានបបួលគាត់ឲ្យមករស់នៅមួយរយៈឯទីក្រុងភ្នំពេញវិញ ។ នៅទីបំផុត អ្នកទាំងពីរក៏នាំគ្នារត់មកជំរុំជនភៀសខ្លួនឯទល់ដែនវិញ ។ មកដល់ទល់ដែនភ្លាម សេង លាងហាក់ ក៏ដាក់ពាក្យសុំទៅរស់នៅសហរដ្ឋអាមេរិក ។ តាមបងទេពធីតាបានឲ្យដឹងថា សេង លាងហាក់ នោះ ជាមនុស្សប្រច័ណ្ឌខ្លាំងណាស់ ព្រោះថាទោះជាធ្លាប់បានរស់នៅយ៉ាងវេទនាក្នុងរបបខ្មែរក្រហមយ៉ាងណាក៏ដោយ ក៏បងថ្លៃស្រីរបស់ខ្ញុំនោះនៅរក្សាសម្រស់ផូរផង់របស់គាត់ដែរ ។ ជាភ័ព្វសំណាងល្អរបស់ពួកគាត់ សហរដ្ឋអាមេរិកក៏ផ្ដល់ទិដ្ឋាការឲ្យទៅរស់នៅជាជនភៀសខ្លួនតទៅ ។

## បាតុកម្មប្រឆាំង ៧ មករា នៅទីក្រុងប៉ារីស

នៅទីក្រុងប៉ារីសសហគមន៍ ខ្មែរភាគច្រើនចាត់ទុកថ្ងៃទី ៧ មករា ជាថ្ងៃនៃការឈ្លានពានរបស់វៀតណាមមកលើទឹកដីកម្ពុជា ដោយមិនបានគិតថាជាថ្ងៃដែល

វៀតណាមមកជួយយកអាសាពីការកាប់សម្លាប់របស់ខ្មែរក្រហមឡើយ ។ ជារៀងរាល់ឆ្នាំ នៅពេលថ្ងៃ ឬ ខួបកំណើត ៧ មករានេះ សមាគមអា ហ្សេ កា អឺ ព្រមទាំងសហគមន៍ខ្មែរឯទៀត តែងសហការគ្នារៀបចំធ្វើបាតុកម្មសំដែងការប្រឆាំងចំពោះកងទ័ពវៀតណាម និង ទាមទារឲ្យកងទ័ពនេះ ដកថយចេញពីប្រទេសខ្មែរ ។ នៅថ្ងៃខួបឆ្នាំទីមួយនោះ នាខែ មករា ឆ្នាំ១៩៨០ បាតុកម្មប្រឆាំងនេះ ប្រព្រឹត្តិនៅចំកណ្តាលទីក្រុងប៉ារីស ក្នុងតំបន់ទេសចរណ៍មួយដ៏សំខាន់ នៅតួអេ ហ្វែល (Tour Eiffel) ។ ពួកបាតុករជួបជុំគ្នាយ៉ាងកុះករ ប្រកបដោយបដាសរសេរ ពាក្យស្លោកជាភាសាខ្មែរ បារាំង និង អង់គ្លេស ប្រឆាំងការឈ្លានពានរបស់វៀតណាម ។ ពួកគេចាប់ផ្តើមថ្លែងសុន្ទរកថាជាបន្តបន្ទាប់ មុននឹងដង្ហែរក្បួនតាមដងវិថីនៃទីក្រុងប៉ារីស ។

ខ្ញុំមានការរំភើបចិត្តជាខ្លាំង ក្នុងការចូលរួមធ្វើបាតុកម្មនេះជាមួយមិត្តភក្តិរបស់ខ្ញុំគឺៈ តិកលីន ខាន់កែវ និង សូរិយាស៊ី ។ សូរិយាស៊ី រៀបចំរថយន្តរបស់គេដោយប្រដាប់គ្រឿងបំពងសំឡេង ដែលមានឧគ្ឃោសនស័ព្ទ(មីក្រូ) និង សម្ភារៈឯទៀតផង ។ នៅពេលដែលសូរិយាស៊ីបររថយន្តរបស់គេ និង មិត្តភក្តិឯទៀតដើរហែរតាមក្រោយចែកខិតប័ណ្ណនោះ ខ្ញុំអង្គុយក្នុងរថយន្តក្បែរសូរិយាស៊ី ស្រែកតាមឧឃោសនស័ព្ទ ឲ្យអ្នកហែរឯទៀតស្រែកបន្ទរតាម ។ ពាក្យស្លោកដែលត្រូវស្រែកនោះមានចាប់ពីពាក្យស្លោកស្នេហាជាតិ ដូចជាដីខ្មែរត្រូវតែខ្មែរនៅ រហូតដល់ពាក្យទាមទារឲ្យបរទេសឈ្លានពានចេញពីទឹកដីខ្មែរ ឬ ពាក្យថ្កោលទោសរបបកុម្មុយនីស្តជាដើម ។ ខ្ញុំខំស្រែកខ្លាំងៗជាប់តាមផ្លូវរហូតដល់ខ្ញុំត្រូវស្អកកនិយាយលែងឮ ឬ ឮ ខ្សាវៗ ។ បាតុករទាំងអស់នាំគ្នាទៅឈប់នៅមុខស្ថានទូតវៀតណាម ដោយចាត់ឲ្យអ្នកតំណាងក្នុងនោះ មានខ្លួនខ្ញុំមួយរូបផង នាំញត្តិទៅជូនមន្ត្រីតំណាងស្ថានទូតនេះ ។

នៅឱកាសធ្វើបាតុកម្មនោះ ខ្ញុំក៏ជួបមិត្តថ្មីម្នាក់ដែលធ្វើដំណើរពីខេត្តខាង

ត្បូងនៃប្រទេសបារាំងមកចូលរួមដែរ ។ មិត្តនោះគឺ ទេព ដារ៉ុង ដែលទើបតែរើផ្ទះពីខេត្តទូលូ (Toulouse) មករស់នៅឯទីក្រុងប៉ារីស ។ នៅទូលូ សមាគម អា ហ្សេ កា អឺ មានសមាជិកសកម្មជាច្រើន ហើយក៏មានសកម្មភាពគាំទ្រយ៉ាងខ្លាំងក្លាណាស់ដែរ ។ មុននេះបន្តិច មានសមាជិកសកម្មម្នាក់ឈ្មោះ ប៊ុន សាយ ទើបតែស្ម័គ្រចិត្តទៅចូលរួមធ្វើការតស៊ូជាមួយលោកតា សឺន សាន ឯប្រទេសថៃ ។ មុនពេល ប៊ុន សាយ ចេញដំណើរទៅនោះ គាត់បានចូលមកលាខ្ញុំឯទីក្រុងស្ដាំង ហើយខ្ញុំក៏មានឱកាសធ្វើបាយជូនជាកិត្តិយស ចំពោះគាត់ដែលមានសេចក្ដីក្លាហាន ហ៊ានលះបង់អ្វីៗគ្រប់យ៉ាងនៅប្រទេសបារាំង ទៅធ្វើការតស៊ូដើម្បីជាតិ ។ ខ្ញុំតែងតែមានការស្រឡាញ់ និង គោរពចំពោះអ្នកស្ម័គ្រចិត្តចេញទៅធ្វើការតស៊ូដើម្បីប្រទេសជាតិជានិច្ច ។

ទេព ដារ៉ុង ជាកូនប្រុសម្នាក់ ក្នុងចំណោមកូនប្រុសៗឯទៀតរបស់លោកឧកញ៉ា ទេព ផន ដែលធ្លាប់កាន់តំណែងជារដ្ឋមន្ត្រីក្រសួងការបរទេសនៅក្នុងរដ្ឋកាលទី១នៃព្រះករុណាសម្ដេច នរោត្តម សីហនុ ។ ក្នុងចំណោមមុខតំណែងជាន់ខ្ពស់ទាំងឡាយ មុខតំណែងជាចៅហ្វាយក្រុងភ្នំពេញ (អភិបាលក្រុង) បានធ្វើឲ្យឧកញ៉ា ទេព ផន ល្បីឈ្មោះជាងគេក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ។ លោកធ្លាប់បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ទៅចូលរួមប្រជុំក្នុងសន្និសីទស្ដីពីឥណ្ឌូចិន នៅទីក្រុងហ្សឺណែវនាឆ្នាំ ១៩៥៤ ។ ឧកញ៉ា ទេព ផន ជាមនុស្សជិតស្និទ្ធជាមួយសម្ដេច ប៉ែន នុត និង លោកតា សឺន សាន ។ លោកក៏ជាសមាជិកស្ថាបនិកមួយរូបដែរនៃសមាគម អា ហ្សេ កា អឺ ។ នៅមុនឆ្នាំ ១៩៧០ ទាំងឧកញ៉ា ទេព ផន ទាំងលោកតា សឺន សាន សុទ្ធសឹងតែជាមន្ត្រីជាន់ខ្ពស់ដែលគេតែងគោរពកោតខ្លាច ព្រោះមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះបរមរាជវាំង ។ គ្រួសារទាំងពីរនេះ រាប់បញ្ចូលទាំងគ្រួសារមួយចំនួនតូចទៀតផង សុទ្ធតែជាត្រកូលអភិជន

ដ៏ខ្ពង់ខ្ពស់ នៅក្នុងប្រទេសកម្ពុជានាសម័យនោះ ។ ក្រោយពីបានចូលរួមក្នុងបាតុកម្មរួច ទេព ដារ៉ុង ក៏តែងចូលរួមប្រជុំជាញឹកញាប់នៅក្នុងសមាគម អា ហ្សេ កា អឺ និង បានរួមចំណែកជួយបំរើការងារដ៏មានប្រយោជន៍ដល់សមាគមនេះតរៀងមក ។

# ពួកយើងនៅទីក្រុងប៉ារីស

នៅសម័យដែលយើងជួបគ្នានោះ ទេព ដារ៉ុង កំពុងប្រកបអាជីវកម្មជាអ្នកធ្វើរូបគំរូ (Modeling Shop) សំណង់ដូចជា៖ រូបផ្ទះវីឡា សាលារៀន ឬ អាគារផ្សេងៗដទៃទៀត ។ គាត់ធ្វើរូបគំរូទាំងនោះតាមប្លង់ ដែលស្ថាបត្យករ (Architect) គូររួចហើយ មុនយកទៅសាងសង់ ។ តាំងពីគាត់ចូលធ្វើការជាអ្នកស្ម័គ្រចិត្តបំរើ អា ហ្សេ កា អឺ មក ទេព ដារ៉ុង ច្រើនតែបិទទ្វារហាងរបស់គាត់ និង ចំណាយពេលវេលាជាច្រើនមកធ្វើការឲ្យសមាគម ពោលគឺគាត់ទុកមុខរបរចិញ្ចឹមជីវិតរបស់គាត់ជាការងារបន្ទាប់បន្សំទៅវិញ ។ ការងារក្នុងសមាគមទាំងនោះ មានដូចជា៖ ចូលរួមប្រជុំនានា ជួយរៀបចំសន្និសីទ ឬ ជូនដំណើរបណ្ឌិត ឆាយ ហាន់ចេង ទៅតាមខេត្តនានានៃប្រទេសបារាំង ។

ជាធម្មតា នៅពេលរួចពីការងារក្នុងក្រុមហ៊ុនស្ទើរតែរាល់ល្ងាច ខ្ញុំតែងទូរស័ព្ទហៅ ដារ៉ុង ឲ្យមកជួបជុំគ្នានៅផ្ទះលោកតា សឺន សាន ជាមួយមិត្តភក្តិឯទៀត ដើម្បីជួយធ្វើការតូចតាចកំប៉ិកកំប៉ុកមួយចំនួននៅក្នុងសមាគមដូចជា៖ វាយអង្គុលីលេខ បិទតែមសំបុត្រ ឬ យកសំបុត្រទៅផ្ញើ ឬ ថតចម្លងឯកសារ ឬ ទូរស័ព្ទទៅណាត់ពេលសុំជួបអាជ្ញាធរបារាំងជាដើម ។ ក្រោយពីពេលដែលយើងបញ្ចប់ការងារក្រៅម៉ោងធ្វើការរបស់យើងនេះហើយ ពួកយើងតែងបបួលគ្នាទៅទទួលទានអាហារពេលល្ងាចនៅភោជនីយដ្ឋានមួយឈ្មោះ "នាគនៅទិសខាងជើង" (Dragon du Nord) ដែលស្ថិតនៅតំបន់ឈ្មោះថា "ស្ថានីយរថភ្លើងទិសខាងជើង" (La Gare

du Nord) ។ ម្ចាស់ភោជនីយដ្ឋាននេះឈ្មោះ សុខ វ៉ាន់ធី ក៏បានក្លាយជាមិត្តជិតស្និទ្ធរបស់ខ្ញុំម្នាក់ទៀត ព្រោះតែខ្ញុំឧស្សាហ៍មកទទួលទានអាហារពេលល្ងាចជាញឹកញាប់ផង និង ធ្លាប់នាំភ្ញៀវជាច្រើននាក់មកភោជនីយដ្ឋានរបស់គាត់ផង ។

សុខ វ៉ាន់ធី ជាអាជីវករដ៏កម្រម្នាក់ ដែលរកទទួលទាន ដោយមិនចាំបាច់ជួលបុគ្គលិកឲ្យមកធ្វើការ ព្រោះថាអ្វីៗគាត់ និង ភរិយាធ្វើស្ទើរតែទាំងអស់ ។ ម្យ៉ាងគាត់ចូលចង្ក្រានធ្វើម្ហូបដោយខ្លួនឯង ឯភរិយារបស់គាត់មានភារៈបំរើភ្ញៀវ និង គិតបញ្ជី ។ តាមពិតទៅ សុខ វ៉ាន់ធី មិនដែលធ្វើម្ហូបម្ហាអ្វីទេកាលគាត់រស់នៅឯប្រទេសកម្ពុជា ។ គាត់មិនមែនជាមេចុងភៅអាជីពនោះឡើយ ។ កាលនៅឯស្រុកខ្មែរគាត់រកទទួលទានខាងផ្នែកសំណង់ ធ្លាប់ដេញថ្លៃបាននូវកុងត្រាសាងសង់វាលយន្តហោះនៅកោះពូលូវ៉ៃ (Poulo Wai) ។

សុខ វ៉ាន់ធី ធ្លាប់បានធ្វើការសិក្សានៅសហរដ្ឋអាមេរិក ហើយបានទទួលបរិញ្ញាបត្រខាងវិស្វកម្ម ។ គាត់ធ្លាប់រៀបការជាមួយស្ត្រីជនជាតិអាមេរិកម្នាក់ ។ ប៉ុន្តែពួកគាត់ត្រូវលែងលះគ្នានៅប៉ុន្មានឆ្នាំ ដែលបានវិលមកប្រទេសកម្ពុជាវិញ ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ។ សុខ វ៉ាន់ធី គេចរួចពីរបប ប៉ុល ពត ហើយបានទទួលសិទ្ធិជ្រកកោនជាជនភៀសខ្លួននៅប្រទេសបារាំង បន្ទាប់ពីរបបសាធារណរដ្ឋរបស់លោកប្រធានាធិបតី លន់ នល់ បានដួលរលំទៅមិនយូរប៉ុន្មាន ។ គាត់មករស់នៅប្រទេសបារាំងជាមួយភរិយាទីពីររបស់គាត់ ដែលធ្លាប់ជាអ្នកទទួលភ្ញៀវនៅក្នុងភ្នាក់ងារធ្វើដំណើររបស់តៃវ៉ាន់មួយនៅភ្នំពេញ ។ នៅទីក្រុងប៉ារីស សុខ វ៉ាន់ធី ទិញបានភោជនីយដ្ឋានមួយ ដែលគាត់យកមកកែឆ្នៃជាភោជនីយដ្ឋានខ្មែរ នៅផ្លូវមួយឈ្មោះម៉ូបើស្ហ៍ (Maubeuge) នៅជិតស្ថានីយរថភ្លើងខាងជើង (La Gare du Nord) ។ ដំបូងឡើយ ខ្ញុំចូលទៅភោជនីយដ្ឋាននេះតែម្នាក់ឯង បន្ទាប់ពីបានអានអត្ថបទក្នុងកាសែតបារាំង ដែលលើកសរសើរពីគុណភាពខ្ពស់នៃម្ហូបអាហាររបស់មេចុងភៅនៃ

ភោជនីយដ្ឋាននោះ ។ គេសរសើរថាម្ហូបមានរសជាតិឆ្ងាញ់ពិសា ឯសេវាបំរើអតិថិជនក៏ល្អ ។

នៅពេលដំបូង សុខ វ៉ាន់ធី មានការភ្ញាក់ផ្អើលជាខ្លាំង ព្រោះឃើញរូបខ្ញុំចូលមកក្នុងភោជនីយដ្ឋានរបស់គាត់ ដែលធម្មតាមានតែអ្នកទេសចរណ៍បរទេស ឬ អតិថិជនជនជាតិបារាំងតែប៉ុណ្ណោះ ។ គាត់មានការចាប់អារម្មណ៍ចំពោះអាកប្បកិរិយារបស់ខ្ញុំ ដែលសំដែងខុសប្លែកពីយុវជនឯទៀត ព្រោះអ្នកទាំងនោះចូលចិត្តនិយាយពីរឿងស្រីស្រា ឬ ដើររាំច្រៀងតាមរង្គសាល ។ ផ្ទុយទៅវិញ ខ្ញុំនិយាយរកគាត់តែអំពីរឿងស្រុកទេស ពីការរំដោះជាតិ និង អំពីការកសាងកម្ពុជាឡើងវិញតែប៉ុណ្ណោះ ។

តាំងពីថ្ងៃដែលយើងបានជួបគ្នាដំបូង សុខ វ៉ាន់ធី និង ខ្ញុំ ក៏បានរាប់អានគ្នាជាមិត្តភក្តិដ៏ជិតស្និទ្ធតរៀងមក ។ ភោជនីយដ្ឋានរបស់គាត់ ក៏ក្លាយជាទីកន្លែងដែលពួកយើងតែងមកជួបជុំគ្នាជាអចិន្ត្រៃយ៍ បន្ទាប់ពីផ្ទះ លោកតា សឺន សាន ។ ក្រោយពេលដែលរ.ជ.រ.ប.ខបានត្រូវប្រកាសជាសាធារណៈរួចមក ពួកយើងនាំគ្នាមកធ្វើការនៅការិយាល័យផ្សាយព័ត៌មានរបស់ រ.ជ.រ.ប.ខ. នៅផ្លូវមួយឈ្មោះ ហ្វ្រេកែល (Passage Fréquel) ក្នុងសង្កាត់លេខ ២០ នៃទីក្រុងប៉ារីស ។ ជាញឹកញាប់ដោយមានគ្នីគ្នាប្រមាណ ២ ឬ ៣ នាក់មកជាមួយក្នុងនោះមាន ទេព ដារ៉ុង ផង ខ្ញុំតែងមកទទួលទានអាហារពេលល្ងាចនៅភោជនីយដ្ឋាន "នាគនៅទិសខាងជើង" នៅម៉ោង ១០ ឬ ១១ យប់ ព្រោះថានៅពេលនោះ ម្ចាស់ហាង សុខ វ៉ាន់ធី រយាលដៃពីអតិថិជនធម្មតារបស់គាត់ ដូច្នេះមានពេលអាចទទួលពួកយើងបានដោយស្រួល ។ ពួកយើងយកកន្លែងគាត់ជាកន្លែងជជែកគ្នារឿងនយោបាយផង និង ជាកន្លែងទទួលទានអាហារផង ។ កាលណាចូលក្នុងភោជនីយដ្ឋាននេះម្តងៗ ពួកយើងមិនដែលចេញទៅវិញមុនម៉ោង ១ យប់ ឬ ក៏ទៀបភ្លឺនៅល្ងាចថ្ងៃសុក្រ ឬ ថ្ងៃ

សៅរ៍ឡើយ ។ សុខ វ៉ាន់ធី ធ្វើមុខម្ហូបណាដែលយើងចង់ទទួលទាន និង បញ្ចេញស្រាក្រហម ឬ ស្រាសបារាំងដែលហាងគាត់មានយកមកឲ្យពួកយើងវាយតម្លៃគុណភាព ឬ វាយតម្លៃរសជាតិ ។

## លោកតាថ្លែងថា សត្រូវនៃសត្រូវ គឺជាមិត្ត

ក្នុងឋានៈពួកយើងជាអ្នកឃោសនាឲ្យមូលហេតុដ៏ឧត្តុង្គឧត្តមមួយ ពួកយើងតែងតែត្រូវការនូវព័ត៌មានខាងផ្នែកយោធា នយោបាយ ឬ ការទូតពីសមរភូមិមុខ ។ ក្នុងខែ មករា ១៩៨០ លោក ថុន អ៊ុក អ្នកនាំពាក្យផ្លូវការរបស់ រ.ជ.រ.ប.ខ.ប្រចាំនៅទីក្រុងប៉ារីសបានធ្វើដំណើរទៅប្រទេសថៃ ហើយបានចូលទៅកាន់តំបន់រំដោះរបស់ រ.ជ.រ.ប.ខ.នៅលើទឹកដីខ្មែរ ។ នៅថ្ងៃ ៥ មករា ១៩៨០ លោក ថុន អ៊ុក បានចូលរួមជាមួយលោកតា សឺន សាន ក្នុងពិធីបញ្ចប់វគ្គសិក្សាលើកទី១នៃកងកម្លាំងពិសេសនៅក្នុងភូមិស្រោចស្រង់ក្រឡ ដែលធ្លាប់បានទទួលរងការវាយប្រហាររបស់កងទ័ពវៀតណាមនៅថ្ងៃ ៨ ធ្នូ ១៩៧៩ ។

លោកតា សឺន សាន ឆ្លៀតឱកាសដែលមានវត្តមានរបស់លោក ថុន អ៊ុក នាពេលបិទវគ្គនោះ បានសង្កត់ធ្ងន់អំពីសារប្រយោជន៍នៃការគាំទ្ររបស់សហគមន៍ខ្មែរនៅបរទេសដល់ចលនាតស៊ូរបស់គាត់ ។ លោកតាប្រធាន រ.ជ.រ.ប.ខ. បានសំដែងការកោតសរសើរដល់យុទ្ធជន រ.ជ.រ.ប.ខ. ដែលបានស្ម័គ្រចិត្តចូលមកបំរើកងកម្លាំងពិសេសហើយក៏ជាលើកទីមួយ ដែលលោកតាបានបង្ហើបជាសាធារណៈឲ្យដឹងនូវចេតនាធ្វើសហការជាមួយកងកម្លាំងទាំងអស់ ដែលកំពុងធ្វើការតស៊ូប្រឆាំងកងទ័ពវៀតណាមដោយរួមទាំងកម្លាំងខ្មែរក្រហមផង ។ លោកតាមានប្រសាសន៍

ថា៖ "សត្រូវនៃសត្រូវរបស់យើងគឺជាមិត្តរបស់យើង"[110] ។ ក្នុងន័យនេះហើយ ដែលយើង អាចដឹងថាលោកតាមានបំណងចូលរួមជាមួយខ្មែរក្រហម ព្រោះថាខ្មែរក្រហមជាសត្រូវស្លាប់រស់របស់វៀតណាម ។ ក៏ប៉ុន្តែការអះអាងនេះក៏ប្រឆាំងនឹងគោលការណ៍ទីពីររបស់រ.ជ.រ.ប.ខ. ដែលថែងថាសត្រូវស្លាប់រស់ទីពីររបស់យើងគឺ របបប្រល័យពូជសាសន៍ខ្មែរក្រហមនេះឯង ។ ដូច្នេះការអះអាងថាសត្រូវនៃសត្រូវជាមិត្តនោះប្រាកដ ពិបាកពន្យល់ និង ទទួលយកបានណាស់ ជាពិសេសចំពោះករណីខ្មែរក្រហមនេះ ។

ប្រទេសចិននៅសម័យនោះ ទំនងជាមហាអំណាចមួយ ដែលប្រឆាំងនឹងវត្តមានកងទ័ពវៀតណាមនៅលើទឹកដីខ្មែរខ្លាំងជាងគេ និង សកម្មជាងគេក្នុងការជំរុញឲ្យមានកងកម្លាំងចម្រុះខ្មែរមួយដ៏រឹងមាំខ្លាំងក្លា ក្នុងការធ្វើសង្គ្រាមយូរអង្វែងប្រឆាំងកងទ័ពដ៏ខ្លាំងពូកែរបស់ក្រុងហាណូយ ។ ប្រទេសដែលគាំទ្រមួយចំនួនអាចបង្ហើបឲ្យថ្នាក់ដឹកនាំរ.ជ.រ.ប.ខ.ដឹងថារណសិរ្សនេះអាចនឹងទទួលជំនួយគ្រប់គ្រាន់តែក្នុងករណីចូលរួមតស៊ូជាមួយខ្មែរក្រហមតែប៉ុណ្ណោះ ។

ទស្សនកិច្ចរបស់លោក ថុន អ៊ុក នៅក្នុងតំបន់រំដោះក្នុងទឹកដីខ្មែរបានបង្កើនឡើងនូវកម្លាំងចិត្តថ្មីថែមទៀតដល់ពួកយើង ដែលជាអ្នកឃោសនា ឲ្យខិតខំបង្កើនការឃោសនាថារ.ជ.រ.ប.ខ.ជាចលនាអ្នកជាតិនិយមពិតៗ ជាចលនាមិនមែនកុម្មុយនីស្តដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ និង មានអ្នកដឹកនាំប្រកបដោយសមត្ថភាព ។ យើងឃោសនាថា យើងមានរដ្ឋបាល និង កងទ័ពត្រឹមត្រូវពិតប្រាកដជាក់ស្តែងនៅលើសមរភូមិ ។ នៅពេលនោះ បើប្រៀបធៀបទៅនឹងសហពន្ធខ្មែរនៅទីក្រុងព្យុងយ៉ាងរបស់សម្តេច សីហនុ រណសិរ្សយើងហាក់ដូចជាមានប្រៀបជាង ។

---

[110] Son Sann, President of the People's National Liberation Front, Speech, at the Closing Ceremony of the Political, Warfare Training and the Graduation of the 1st Group of Special Forces, Khmer Territory, January 5, 1980, KPNLF Bulletin No. 2, February 1980, p. 16.

# ស្ថាប័ន និង សមាជនៃរ.ជ.រ.ប.ខ.

ដោយប្រមើលឃើញជាមុនថា រ.ជ.រ.ប.ខ. អាចដើរតួនាទីដ៏សំខាន់នៅក្នុងអនាគតនៃប្រទេសកម្ពុជា ថ្នាក់ដឹកនាំ រ.ជ.រ.ប.ខ. បានចាប់ផ្តើមគំនិតចាត់តាំងស្ថាប័នសំខាន់ៗនៃចលនាតស៊ូនេះ ។ នៅពេលជាមួយគ្នានោះ រ.ជ.រ.ប.ខ. ក៏ទាមទាររកតួនាទីសំខាន់នៅក្នុងចលនារួបរួមចម្រុះណាមួយក្នុងពេលអនាគត ព្រមជាមួយនឹងការខិតខំស្វែងរកការគាំទ្រដ៏រឹងមាំ និង ច្បាស់លាស់ ។ នៅខែ មីនា ១៩៨០ រ.ជ.រ.ប.ខបានបង្កើតក្រុមប្រឹក្សាព្រឹទ្ធាចារ្យ[111] (Conseil des Sages)ដែលមានសមាសភាពរួមទាំងអតីតនាយករដ្ឋមន្ត្រី២រូបគឺ៖ លោក ស៊ឹម វ៉ា និង លោក ហ៊ុយ គន្ធុល និង អតីតរដ្ឋមន្ត្រី៤រូបគឺ៖ លោក នង គិមនី ចាយ ធុល លឹម គ្រី និង ថុន អ៊ុក ។ លោកឧត្តមសេនីយ សូកាំ ខូយ ដែលឡើងកាន់តំណែងជាប្រធានាធិបតីជំនួសលោក លន់ នល់ នៅថ្ងៃទី ១ មេសា ១៩៧៥ បានចូលរួមក្នុងក្រុមប្រឹក្សាព្រឹទ្ធាចារ្យនេះនៅខែ ធ្នូ ១៩៨០ ។

ដើម្បីបង្កើតនូវមូលដ្ឋាននយោបាយ និង លក្ខណៈស្របច្បាប់របស់ខ្លួនរ.ជ.រ.ប.ខ បានរៀបចំនូវសមាជជាតិលើកទី១នៅខែ មេសា ១៩៨១ នៅលើទឹកដីខ្មែរក្នុងភូមិស្រោចស្រង់ ។ សមាជជាតិនេះ មានគណៈប្រតិភូមកពី ២៤ ខេត្តក្រុងចូលរួម លើកលែងតែខេត្តពីរចេញគឺ៖មណ្ឌលគីរី និង រតនគីរី ។ នៅលើឯកសារនៃវត្តមានគណៈប្រតិភូចូលរួមមានចែងថា៖ "គណៈប្រតិភូមកពីខេត្ត៖កំពត កណ្តាល កោះកុង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ ក្រចេះ កំពង់សោម ជំរុំខៅ-អ៊ី-ដាង ចលនាហនុមាន២៥៧ ចលនារាជសីចតុមុខ តាកែវ ប៉ៃលិន បន្ទាយឆ្មារ បាត់ដំបង

[111] Son Sann, Front National de Libération du Peuple Khmer, Décision No. 80/03/FNL, Territoire Khmer, le 11 mars 1980.

ព្រៃវែង ព្រះវិហារ ពោធិសាត់ ភ្នំពេញ រណសិរ្សខ្មែរអង្គរ០០៧ ស្ទឹងត្រែង ស្វាយរៀង សៀមរាប ឧត្តរមានជ័យ អ្នកភូមិស្រោចស្រង់ និង គណៈប្រតិភូខ្មែរអ៊ីស្លាម" ។ នៅឱកាសបើកសមាជនេះ លោកតាប្រធានបានគូសបង្ហាញនូវចំណុចសំខាន់ៗនៃកម្មវិធីនយោបាយរបស់រ.ជ.រ.ប.ខ. និង បានលើកឡើងចំណុចដ៏សំខាន់ពីរចំណុចពិសេស ដែលទាក់ទងនឹងផលប្រយោជន៍ជាតិគឺ៖[112] ១. លទ្ធភាពនៃការចូលរួមរបស់រ.ជ. រ.ប.ខ. នៅក្នុងរដ្ឋាភិបាលជាតិបណ្តោះអាសន្នមួយ និង ២. គោលជំហររបស់រ.ជ.រ.ប.ខ. ចំពោះអំពើឧក្រិដ្ឋ ដែលពួកខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាពលរដ្ឋខ្មែរ ។ នៅលើចំណុចទី១ លោកតាបានភ្ជាប់ការចូលរួមរបស់រ.ជ.រ.ប.ខ.ណាមួយនៅក្នុងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន ទៅជាមួយនឹងការកាន់កាប់អាសនៈរបស់កម្ពុជានៅអង្គការសហប្រជាជាតិ (អ.ស.ប) ឬ សិទ្ធិជាអ្នកតំណាងស្របច្បាប់នៃកម្ពុជា នៅក្នុងសន្និសីទអន្តរជាតិណាមួយនាពេលខាងមុខ ។

ដោយហេតុថារ.ជ.រ.ប.ខ. បានរៀបចំយុទ្ធសាស្ត្រសំដៅដោះស្រាយវិបត្តិនៅកម្ពុជាតាមផ្លូវនយោបាយ វត្តមានរបស់រ.ជ.រ.ប.ខ. នៅលើឆាកអន្តរជាតិត្រូវបានចាត់ទុកជាអាទិភាពខ្ពស់បំផុតរបស់ចលនារំដោះជាតិនេះ ។ រ.ជ.រ.ប.ខ. មានជំនឿថានឹងមានសន្និសីទអន្តរជាតិមួយ ក្នុងខែ ឬ ឆ្នាំខាងមុខមិនខានឡើយ ។ សន្និសីទនោះ នឹងនាំដល់ការដកកងទ័ពវៀតណាមចេញពីកម្ពុជា ព្រមទាំងនាំឲ្យមានការបោះឆ្នោតជាទូទៅមួយផង ។ នៅក្នុងករណីនេះ បញ្ហាតំណាងស្របច្បាប់នៃប្រទេសកម្ពុជាដើម្បីចូលរួមក្នុងសន្និសីទអន្តរជាតិនោះ ប្រាកដជានឹងត្រូវលើកយកមកពិភាក្សា ។ តើគេនឹងជ្រើសយករបបភ្នំពេញ ដែលមានការទទួលស្គាល់ដោយប្រទេសមួយចំនួនក្នុងប្លុកកុម្មុយនីស្ត ឬ យករបបកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហមឲ្យធ្វើជាតំណាងប្រជាជាតិខ្មែរ? នៅលើចំណុចនេះ ថ្នាក់ដឹកនាំរ.ជ.រ.ប.

[112] Son Sann, Speech delivered at the Opening Session of the Congress, KPNLF Bulletin, Special Issue no. 4, April 1980, pp. 3-11.

ខ. យល់ឃើញថា ប្រសិនបើយើងខឹតខំធ្វើការខាងការទូតឲ្យអន្តរជាតិទទួលស្គាល់ និង ប្រសិនបើកងទ័ពរបស់រ.ជ.រ.ប.ខ.ខឹតខំបង្កើនសមត្ថភាពធ្វើសកម្មភាពយោធាខ្លាំងក្លា ឲ្យក្លាយខ្លួនជាកម្លាំងទីបី ដែលមិនមែនកុម្មុយនីស្តនោះ រ.ជ.រ.ប.ខ. អាចឈរឈ្មោះជាតំណាងប្រជារាស្ត្រ និង ប្រជាជាតិខ្មែរបាននៅលើឆាកអន្តរជាតិ ។ ប្រសិនបើរ.ជ.រ.ប.ខ.ត្រូវបានអន្តរជាតិទទួលស្គាល់ និង អាចតំណាងឲ្យកម្ពុជាបាននោះ រ.ជ.រ.ប.ខ.នឹងបន្តស្ថិតនៅជារណសិរ្សតទៅទៀត ដោយមិនចាំបាច់បង្កើតរដ្ឋាភិបាលឡើយ ។ ក៏ប៉ុន្តែ ប្រសិនបើមានការចាំបាច់ត្រូវបង្កើតរដ្ឋាភិបាលជាតិបណ្តោះអាសន្នណាមួយនោះ រ.ជ.រ.ប.ខ. នឹងបង្កើតឡើងភ្លាមនូវរដ្ឋាភិបាលជាតិនោះ ។ នៅសម័យនោះ ថ្នាក់ដឹកនាំរ.ជ.ប.ខ.គិតត្រឹមតែបង្កើតរដ្ឋាភិបាលជាតិនិយម (A Nationalist Government) ដែលគ្មាន ខ្មែរក្រហមចូលរួម និង ដែលឆ្លុះបញ្ចាំងពីឆន្ទៈនៃប្រជារាស្ត្រខ្មែរភាគច្រើនតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែមានអ្នកគាំទ្រក្នុងមជ្ឈដ្ឋានអន្តរជាតិមួយចំនួន បានលើកទឹកចិត្តឲ្យលោកតា សឺន សាន រួមកម្លាំងជាមួយខ្មែរក្រហម ដើម្បីធ្វើការប្រយុទ្ធប្រឆាំងនឹងកងទ័ពវៀតណាមនៅកម្ពុជា ។ នៅពេលនោះ លោកតាប្រធានរ.ជ.រ.ប.ខ. ត្រូវប្រឈមមុខនឹងជំរើសពីរៈ ជំរើសទី១ ឬមួយត្រូវចូលរួមកម្លាំងជាមួយខ្មែរក្រហម ទើបបានទទួលជំនួយពីខាងក្រៅខ្លះ ។ ជំរើសទី២ ឬមួយបង្កើតរដ្ឋាភិបាលខ្មែរតែឯកឯងដោយគ្មានជំនួយពីក្រៅសោះ ។ ជំរើសទី២នេះ ហាក់ដូចជាមិនអាចទទួលយកបានឡើយ ព្រោះថាបើគ្មានជំនួយទេ រ.ជ.រ.ប.ខ. មិនអាចធ្វើសកម្មភាពអ្វីបានឡើយ ព្រមទាំងអាចនឹងត្រូវរលំរលាយពុំខាន ។

នៅចំពោះមុខសភាពការណ៍បែបនេះ ច្បាស់ណាស់លោកតាប្រធានត្រូវជ្រើសយកជំរើសទី១ ដែលតម្រូវឲ្យមានការចរចាតថ្លៃខ្លះ ។ ដូច្នេះលោកតាប្រធាន រ.ជ.រ.ប.ខ. ក៏យកសមាជជាមូលដ្ឋាននៃយុទ្ធវិធី សំរាប់ការតថ្លៃផ្នែកនយោបាយ

នោះ ។ កាលណាចេញទៅក្រៅ លោកតាតែងមានប្រសាសន៍ថា លោកតានិយាយក្នុងនាមប្រជាពលរដ្ឋ ក្នុងនាមកងទ័ព និង ក្នុងនាមចលនាតស៊ូជានិច្ច ។ ដើម្បីឲ្យអ្នកក្រៅមើលឃើញថា លោកតាពិតជាអ្នកប្រជាធិបតេយ្យមែនៗនោះ លោកតាត្រូវតែធ្វើការពិគ្រោះជាមួយប្រជាពលរដ្ឋ តាមរយៈនៃអង្គសមាជនេះ ។ ជាញឹកញាប់លោកតាតែងរៀបចំជាសមាជ ជាអង្គប្រជុំ ជាសន្និបាត ដើម្បីសុំយោបល់ ឬ សុំការយល់ព្រមជាដើម ។ ជារឿយៗ នៅពេលបើកអង្គប្រជុំ លោកតាតែងបង្ហាញជាមុននូវទិសដៅអ្វី ដែលលោកតាចង់ឲ្យអង្គប្រជុំសម្រេច ឬ អនុម័ត ។ នៅពេលពិគ្រោះយោបល់ លោកតាប្រធានធ្វើការឧទ្ទេសនាមជាមុន រួចស្ដាប់មតិគាំទ្រមួយចំនួន និង ទីបញ្ចប់សុំឲ្យអង្គប្រជុំលើកដៃគាំទ្រ ។ សមាជរបស់ រ.ជ.រ.ប.ខ.នាឆ្នាំ ១៩៨០ នោះ មានសភាពបែបនេះ ។ នៅទីបញ្ចប់លោកតា សឺន សាន បានស្នើឲ្យអង្គសមាជអនុញ្ញាតទុកជាមុន ឲ្យគណៈកម្មាធិការប្រតិបត្តិ រ.ជ.រ.ប.ខ. អាចបង្កើតរដ្ឋាភិបាលជាតិបណ្ដោះអាសន្នមួយ នាពេលខាងមុខដ៏សមស្រប ។ ការស្នើសុំជាមុនឲ្យសមាជិកសន្និបាត ឬ គណៈកម្មការ ប្រគល់សិទ្ធិសំរេចអ្វីមួយ នៅពេលខាងមុខដល់លោកតាប្រធាន ជាសញ្ញាសំគាល់របស់លោកតា នៅក្នុងយុទ្ធវិធីនយោបាយដែលលោកតានឹងប្រើជាប្រចាំសំរាប់ឆ្នាំក្រោយៗជាបន្តបន្ទាប់មកទៀត ។

ទាក់ទងនឹងសមាជជាតិរបស់ រ.ជ.រ.ប.ខ. ឆ្នាំ ១៩៨០ សមាជនេះបានចេញសេចក្ដីសំរេចមួយ ដូចមានចំណុចពីរសំខាន់ៗតទៅ៖ ១. អនុញ្ញាតឲ្យគណៈកម្មាធិការប្រតិបត្តិដែលយើងហៅកាត់ថា "កូម៉ិច" បង្កើតក្នុងករណីចាំបាច់នូវរដ្ឋាភិបាលជាតិបណ្ដោះអាសន្នមួយ ដែលតំណាងឲ្យប្រជាពលរដ្ឋខ្មែរទាំងមូល (ចំណុចទី៥) ២. អនុញ្ញាតឲ្យអ្នកដឹកនាំ រ.ជ.រ.ប.ខ. ប្រាប់ទៅពួកខ្មែរក្រហមថារ.ជ.រ.ប.ខ. មិនចូលរួមក្នុងរណសិរ្សរួបរួមណាមួយជាមួយក្រុមខ្មែរក្រហមទេ ក៏ប៉ុន្តែបញ្ជាក់ថាគោលដៅចម្បងរបស់ រ.ជ.រ.ប.ខ.គឺ រំដោះប្រទេសកម្ពុជា និង ប្រជាពលរដ្ឋខ្មែរពី

ការកាន់កាប់របស់យួនឈ្លានពាន ។ រ.ជ.រ.ប.ខ. នឹងមិនធ្វើការវាយប្រហារទៅលើពួកខ្មែរក្រហមទេ ប្រសិនបើកងទ័ពនៃពួកនេះ មិនធ្វើការវាយប្រហារយើងមុន មិនធ្វើទុក្ខបុកម្នេញប្រជាពលរដ្ឋខ្មែរ និង មិនរាំងរាដល់សកម្មភាពរបស់យើង (ចំណុចទី៦)[113] ។

នៅឆ្នាំ ១៩៨០ នោះ អង្គសមាជបានអនុម័តសេចក្ដីសំរេចមួយចំនួនទាក់ទងនឹងផ្នែកនយោបាយ យោធា សេដ្ឋកិច្ចព្រមទាំងសង្គមកិច្ច និង សាសនា ។ នៅលើចំណុចនយោបាយ អង្គសមាជបានសំរេចផ្ដល់អំណាចពេញទីដល់ រ.ជ.រ.ប.ខ. ដែលដឹកនាំដោយគណៈកម្មាធិការប្រត្តិបត្តិមួយឈ្មោះថា "កូម៉ិច" (COMEX : Comité Exéculif) រហូតដល់រំដោះប្រទេសបានទាំងស្រុង ។ គួររំលឹកថានៅខែ ធ្នូ ១៩៧៩ គណៈកម្មាធិការប្រត្តិបត្តិបានធ្វើការកែសំរួលសមាសភាពខ្លះ ដោយមានបញ្ចូលសមាជិកថ្មី ម្នាក់ដែលទើបរត់ចេញពីភ្នំពេញ មករួបរួមជាមួយ រ.ជ.រ.ប.ខ. ឈ្មោះលោក ហ៊ីង គន្ធុន[114] ។ លោក ហ៊ីង គន្ធុន ត្រូវបានតែងតាំងជាប្រតិភូទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច ។ ក្រោយមកដោយសារលោក ងួន ពីទូរ៉េត បានសុំលាឈប់ការងារឃោសនា បានត្រូវធ្លាក់មកលោក អ៊ឹម ឈូដេត រីឯលោក ព្រុំ វិត ទទួលយកការងារមហាផ្ទៃវិញ ។ ចំណែកលោក កែវ សៅរ៉ុជ (តាដួន) ទទួលបន្ទុកកិច្ចការសាសនា ។ តាមពិតទៅលោក ងួន ពីទូរ៉េត ដែលជាអ្នកសីហនុនិយមច្បាស់លាស់បានលាឈប់នោះ ក៏ប្រហែលជាមើលឃើញថារបៀបរបបការងារដឹកនាំរបស់ រ.ជ.រ.ប.ខ. មិនអាចឲ្យរណសិរ្សនេះរីកចំរើនបានឡើយ ។

សមាជបានថ្កោលទោសរបបភ្នំពេញ ដែលប៉ុនប៉ងរៀបចំធ្វើការបោះឆ្នោតដោយសំអាងថាបោះឆ្នោតដោយមានវត្តមានកងទ័ពបរទេសនៅលើទឹកដីខ្មែរ មិន

---

[113] Resolution, the National Congress of the Khmer People's National Liberation Front, Held in Plenary Session in the Khmer Territory, April 25, 1980, KPNLF Bulletin, Special Issue no. 4, op. cit.
[114] Son Sann, Front National de Libération du Peuple Khmer, Décision No. 79/07/FNL, Territoire Khmer, le 17 Décembre 1979.

អាចយកជាបានការឡើយ (ចំណុចទី៣) ។ ចំណុចសំខាន់ៗឯទៀតនៃសេចក្តីសំរេចរបស់រ.ជ.រ.ប.ខ.នោះមានជាអាទិ៖ សេចក្តីអំពាវនាវដល់អ្នកដឹកនាំខ្មែរគ្រប់ជាន់ថ្នាក់ និង ដល់អ្នកស្នេហាជាតិគ្រប់និន្នាការនយោបាយ រួមទាំងអ្នកដែលបង្ខំចិត្តសហការជាមួយរបបភ្នំពេញផងឲ្យជួយគាំទ្ររ.ជ.រ.ប.ខ.ក្នុងការតស៊ូប្រឆាំងនឹងយួនខាងជើងឈ្លានពាន (ចំណុចទី៤) ។ សមាជសំរេចគាំទ្រដោយឥតសំចៃនូវសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិចុះថ្ងៃទី ១៤ វិច្ឆិកា ១៩៧៩ ដែលបានឆ្លើយតបជាឯកច្ឆ័ន្ទ ចំពោះសំណូមពររបស់ប្រជាពលរដ្ឋខ្មែរទាំងមូលតាមរយៈញត្តិចេញមកពីគ្រប់ខេត្តផ្តល់ដល់អង្គសមាជ (ចំណុចទី៧) និង ស្នើសុំឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិខឹតខំប្រឹងប្រែងគ្រប់យ៉ាង ដើម្បីធ្វើការកោះប្រជុំជាបន្ទាន់នូវសន្និសីទអន្តរជាតិមួយ ស្របតាមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិចុះថ្ងៃទី ១៤ វិច្ឆិកា ឆ្នាំ១៩៧៩ និង តាមសំណូមពររបស់ប្រជារាស្ត្រខ្មែរទាំងមូល (ចំណុចទី៨) សមាជគាំទ្រឥតសំចៃនូវសកម្មភាពការទូតទាំងអស់របស់អាស៊ាន ដោយរាប់ទាំងរបស់គណៈកម្មការអឺរ៉ុប(European Commission) រហូតដល់មានដំណោះស្រាយចុងក្រោយនៃបញ្ហាកម្ពុជា សមស្របតាមសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិចុះថ្ងៃទី ១៤ វិច្ឆិកា ១៩៧៩ (ចំណុចទី៩) និង គាំទ្រផែនការបង្កើតតំបន់សុវត្ថិភាពមួយនៅតាមបណ្តោយព្រំដែនខ្មែរ-ថៃ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិដើម្បីអនុញ្ញាតឲ្យជនភៀសខ្លួនខ្មែរមានសន្តិសុខ និង ទទួលបាននូវជំនួយមនុស្សធម៌ ពីអង្គការក្នុងពិភពលោកបានផង (ចំណុចទី១០) ។ នៅទីបញ្ចប់ សមាជបានធ្វើការថ្កោលទោសរាល់ការប៉ុនប៉ងទាំងឡាយណា ក្នុងការធ្វើឲ្យមានការព្រមព្រៀងជាមួយក្រុងហាណូយ ឬ ក្រុងភ្នំពេញ ដើម្បីធ្វើមាតុភូមិនិវត្តន៍ជនភៀសខ្លួនខ្មែរ ដែលអាចជាការរំលោភសិទ្ធិមនុស្ស និង ផ្ទុយពីសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិចុះថ្ងៃទី ១៤ វិច្ឆិកា ១៩៧៩ (ចំណុចទី១១)״ ។

សេចក្តីសំរេចផ្នែកនយោបាយរបស់សមាជនោះ ក៏មានចែងទៀតថា "ក្រោយពីការបោះឆ្នោតជាទូទៅ ក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិនៅលើទឹកដីខ្មែរទាំងមូលមក សមាជជាតិថ្មីមួយទៀត នឹងសំរេចពីរបបគ្រប់គ្រងប្រទេសរបស់ប្រជាពលរដ្ឋខ្មែរ" ។ នៅសម័យនោះ រាល់ការសំរេចរបស់សមាជត្រូវបានអនុម័តដោយលើកដៃ ។ ដោយឡែក សេចក្តីសំរេចមួយដែលប្រកាសផ្តល់អំណាចពេញទីដល់រ.ជ.រ.ប.ខ. ដឹកនាំដោយគណៈកម្មាធិការប្រតិបត្តិមួយ ឬ កូម៉ិច ដោយមិនបានចែងថាដឹកនាំដោយប្រធាន ក៏ក្លាយទៅជាប្រភព នៃជម្លោះដណ្តើមអំណាចគ្នារវាងប្រធាន និង សមាជិកមួយចំនួននៃគណៈកម្មាធិការប្រតិបត្តិ ឬ កូម៉ិច នៅពេលក្រោយៗមកទៀត ។ នៅឆ្នាំ ១៩៨៣ ដើម្បីកុំឲ្យមានជម្លោះអាចកើតមានបាននោះ លោកតា សឺន សាន បានកោះប្រជុំនូវអង្គសន្និបាតមួយ ដើម្បីឲ្យអង្គសន្និបាតប្រគល់អំណាចពេញទីដល់ប្រធាន តាមវិធីអនុម័តដោយលើកដៃដដែល ។ ម្យ៉ាងទៀត គំនិតដែលថានឹងកោះប្រជុំសមាជថ្មីមួយនៅក្នុងប្រទេសខ្មែរក្រោយពីការបោះឆ្នោតជាទូទៅនោះ ជាគំនិតដែលមិនអាចធ្វើបានគឺជាគំនឹតមិនប្រាកដនិយម ព្រោះថា រ.ជ.រ.ប.ខ. ត្រូវកែប្រែរូបរាងរបស់ខ្លួនឲ្យទៅជាគណបក្សនយោបាយមួយ ដែលមានកម្មវិធីនយោបាយច្បាស់លាស់ រួមទាំង ជំរើសនូវរបបគ្រប់គ្រងរដ្ឋផង ដើម្បីត្រៀមខ្លួនចូលទៅប្រកួតប្រជែងក្នុងការបោះឆ្នោតជាទូទៅដោយសេរីមួយក្នុងពេលខាងមុខ ។

ដោយបានទទួលការលើកសរសើរ ពីសំណាក់បណ្តាញសារព័ត៌មានអន្តរជាតិ ចំពោះជោគជ័យនៃការរៀបចំសមាជជាតិនៅលើទឹកដីខ្មែរ រ.ជ.រ.ប.ខ. បានលេចមុខចេញលើឆាកអន្តរជាតិថា ជាចលនាតស៊ូមួយគួរឲ្យទុកចិត្តបាន ។ តាមរយៈសមាជជាតិនាខែ មេសា ១៩៨០ នោះ អ្នកដឹកនាំទាំងអស់នៃចលនា រ.ជ.រ.ប.ខ. នៅតែរឹងទទឹងចំពោះការប៉ុនប៉ងរបស់ប្រទេសគាំទ្រមួយចំនួន ដែលបង្ខំឲ្យចូល

រួមក្នុងរណសិរ្សរួបរួមជាមួយខ្មែរក្រហម ។ ក៏ប៉ុន្តែបញ្ហាអាសនៈរបស់កម្ពុជានៅអង្គការសហប្រជាជាតិក៏បានក្លាយទៅជាបញ្ហាដ៏ក្តៅគគុក ដែលត្រូវដោះស្រាយជាបន្ទាន់ ហើយក៏ត្រូវបានក្លាយជាទិសដៅនៃការតស៊ូខាងផ្លូវទូតរវាងអ្នកគាំទ្រ និងអ្នកប្រឆាំងកងទ័ពវៀតណាមនៅកម្ពុជា ។ របបភ្នំពេញដែលកើតឡើងដោយមានកងទ័ពវៀតណាមជាបង្អែកយ៉ាងរឹងមាំនោះ កំពុងត្រៀមរៀបចំការបោះឆ្នោតមួយដើម្បីកែប្រែលក្ខន្តិកៈពីរបបមួយ ដែលកើតឡើងដោយសារកម្លាំងកងទ័ពបរទេសមកជារបបមួយ ដែលកើតឡើងដោយសារការបោះឆ្នោតជាសកលទៅវិញ ។

ចំណែកឯពួកខ្មែរក្រហម ដែលមានឈ្មោះល្បីក្នុងពិភពលោកដោយសារការកាប់សម្លាប់ប្រជាពលរដ្ឋខ្លួនឯង ពុំមានសមត្ថភាពការពារអាសនៈរបស់ខ្លួននៅអង្គការសហប្រជាជាតិបានទៀតឡើយ ។ អាសនៈនោះ ពួកខ្មែរក្រហមបានកាន់កាប់តាំងពីឆ្នាំ ១៩៧៥ រហូតមក បន្ទាប់ពីការដួលរលំនៃរបប លន់ នល់ ។

នៅពេលនោះ ដោយសាររ.ជ.រ.ប.ខ. លេចមុខធ្លោឡើងនៅលើឆាកអន្តរជាតិ បានធ្វើឲ្យប្រទេសដែលប្រឆាំងនឹងការលុកលុយរបស់វៀតណាមនៅកម្ពុជា ជាពិសេសប្រទេសចិន ថៃ ស.រ.អា និង ក្រុមប្រទេសអាស៊ានឯទៀត ចាប់ផ្តើមផ្គូផ្គងឲ្យមានការបង្កើតរដ្ឋាភិបាលខ្មែរមួយ ដោយមានលោកតា សឺន សាន ជាអ្នកដឹកនាំ និង ដោយឲ្យមានការរួបរួមជាមួយខ្មែរក្រហម ។ ក៏ប៉ុន្តែ រ.ជ.រ.ប.ខ. នៅតែចចេសរឹងទទឹង ដោយសំអាងថាក្នុងនាមប្រជាពលរដ្ឋខ្មែរ ដែលបានទទួលរងគ្រោះដោយសារខ្មែរក្រហម រ.ជ.រ.ប.ខ. មិនអាចចូលរួមជាមួយពួកប្រល័យពូជសាសន៍នេះបានឡើយ ។ ជំហរនេះក៏បានបញ្ជាក់សាឡើងវិញ នៅក្នុងសមាជឆ្នាំ ១៩៨០ នោះ ។ ជាមួយគ្នានោះ ថ្នាក់ដឹកនាំរ.ជ.រ.ប.ខ.ក៏ប្រមើលមើលមធ្យោបាយគ្រប់យ៉ាងដើម្បីពង្រឹងចលនាតស៊ូនេះ ។

# សម្តេច សីហនុ លាឈប់ពីតំណែងប្រធានសហព័ន្ធខ្មែរ

ចំណែកឯសម្តេច សីហនុ ព្រះអង្គហាក់ដូចជាអន់ព្រះទ័យខ្លះចំពោះជំនួយអន្តរជាតិបន្តិចបន្តួច ដែលទ្រង់ទទួលបានពីមជ្ឈដ្ឋានអន្តរជាតិដែលគាំទ្រព្រះអង្គ។ សម្តេចទ្រង់ស្ថិតនៅចំពោះសភាពការណ៍ប្រឈមពីរយ៉ាងគឺ៖ ម្យ៉ាង ព្រះអង្គមិនត្រូវធ្វើសហការណាមួយជាមួយពួកខ្មែរក្រហមទៀតឡើយ រីឯម្យ៉ាងទៀត ព្រះអង្គក៏មិនត្រូវបណ្តែតបណ្តោយឲ្យលោកតា សឺន សាន ចេញមុខជាអ្នកដឹកនាំចលនាមិនមែនកុម្មុយនីស្តតែម្នាក់ឯងបានឡើយ ។ ក្នុងប៉ុន្មានខែកន្លងមកសម្តេច សីហនុ ទ្រង់តែងតែប្រកាសថា ព្រះអង្គមិនមានបំណងធ្វើការជាមួយពួកឃាតករ ដែលបានកាប់សម្លាប់ប្រជារាស្ត្រតទៅទៀតទេ ។ ជាមួយនោះព្រះអង្គក៏យល់ថាពេលវេលាមិនទាន់មកដល់ទេ សម្រាប់ឲ្យព្រះអង្គទទួលតួនាទីដឹកនាំចលនា រ.ជ.រ.ប.ខ. ដែលបង្កើតឡើងដោយលោកតា សឺន សាន និង ដែលមានមេដឹកនាំយោធាភាគច្រើនសុទ្ធតែជាពួកនាយទាហានពាក់ព័ន្ធក្នុងរដ្ឋប្រហារឆ្នាំ ១៩៧០ ។ នៅសម័យនោះ ក្រុមប្រទេសដែលគាំទ្រចលនាតស៊ូប្រឆាំងវៀតណាម ក៏បានធ្វើការគាបសង្កត់កាន់តែខ្លាំងឡើង ដើម្បីបង្ខំឲ្យ រ.ជ.រ.ប.ខ. រួមកម្លាំងជាមួយពួកខ្មែរក្រហម ទោះបីជាសម្តេច សីហនុ មិនចូលរួមក៏ដោយ ។ មែនទែន សហព័ន្ធខ្មែររបស់សម្តេច ពុំបានធ្វើឲ្យខ្មែរយើងមានការភ្ញាក់ផ្អើលប៉ុន្មានឡើយ ។ ម្យ៉ាងទៀត ក្នុងមួយរយៈពេលដែលព្រះអង្គចេញមកដឹកនាំសហព័ន្ធខ្មែរ ដែលទ្រង់បានបង្កើតនៅទីក្រុងព្យុងយ៉ាងនោះ សម្តេច សីហនុ ពុំទទួលបាននូវការគាំទ្រដុំកំភួនឡើយ ។ ជាមួយនោះ ឥស្សរជននយោបាយខ្មែរដ៏ល្បីល្បាញម្នាក់ដែលធ្លាប់បំរើព្រះអង្គជាយូរមកហើយគឺសម្តេច ប៉ែន នុត បានបែរមកគាំទ្រ រ.ជ.រ.ប.ខ.របស់លោកតា សឺន សាន ទៅវិញ ។ តាមពិតទៅសម្តេច ប៉ែន នុត បានប្រកែកពុំព្រមចូលរួមដឹកនាំចលនា ឬ ស្ថាប័នរបស់អតីតព្រះ

មហាក្សត្រនោះទេ ។ ក្នុងពេលនោះសម្តេច សីហនុ ទ្រង់សំរេចលាឈប់ពីមុខតំណែងប្រធានសហព័ន្ធខ្មែរក្នុងន័យលាឈប់ពីនយោបាយ ។

នៅខែ ឧសភា ១៩៨០ សម្តេចបានផ្ញើសារជាច្រើនច្បាប់ទៅអ្នកគាំទ្ររបស់ព្រះអង្គ ។ នៅក្នុងសារចុះថ្ងៃទី ២០ ឧសភា ១៩៨០ ផ្ញើជូនលោកតា អ៊ិន តាំ សម្តេចបានសំដែងអំណរគុណ ចំពោះភក្តីភាពរបស់លោកតាចំពោះព្រះអង្គ និង បានសុំអភ័យទោស ចំពោះសេចក្តីសំរេចលាលែងពីតំណែងប្រធានសហព័ន្ធខ្មែរអ្នកជាតិនិយមរបស់ព្រះអង្គ ព្រមទាំងទុកលទ្ធភាពឲ្យលោកតា អ៊ិន តាំ ធ្វើការពិចារណាថា តើគួរត្រូវបន្តតំណែងអគ្គលេខាធិការសហព័ន្ធនេះតទៅទៀត ឬ គួរលាឈប់ពីតំណែងអគ្គលេខានេះ[115]? នៅក្នុងសារទូរលេខមួយច្បាប់ទៀតចុះថ្ងៃទី ១៩ ឧសភា ផ្ញើជូនសហការីដ៏ជិតស្និទ្ធរបស់ព្រះអង្គគឺ៖ លោក ខែក វ៉ាន់ឌី លោកវរសេនីយឯក ទឹម ណាំង លោកវរសេនីយឯក ប៊ួ ហ៊ែល និង លោកស្រី ជួន សៅឌី (ឥឡូវនេះជា លោកស្រី សាយ បូរី) សម្តេចបានបង្ហើបឲ្យដឹងពីឧបសគ្គជាច្រើនរបស់ព្រះអង្គ ។ សេចក្តីនៃទូរលេខមានចែងជាអាទិ៍ថា៖[116] "សូមមេត្តាបញ្ជូននូវការរាប់អានរបស់ខ្ញុំ ជូនលោក គង់ ស៊ីលាស់ និង ចលនាមូលីណាកា ជូនលោក អ៊ិន សាខន និង ចលនារណសិរ្សអង្គរ ថ្វាយអ្នកអង្គម្ចាស់ អង្គឌួង សុវណ្ណគីរី និង ចលនារបស់លោក ជូនលោក អ៊ូ សារឿន និង ចលនារំដោះខ្មែរអព្យាក្រឹត្យ ជូនលោកវរសេនីយឯក វ៉ាន់ សៅយុទ្ធ និង រណសិរ្សរំដោះអ្នកជាតិនិយម និង ជូនចលនារំដោះជាតិ និង រណសិរ្សទាំងអស់ដែលបានផ្ញើលិខិត និង ញត្តិគាំទ្រក្នុងរយៈពេលនៃការស្នាក់អាស្រ័យរបស់ខ្ញុំនៅប្រទេសបារាំង ដែលខ្ញុំសូមឆ្លើយតបជូនដូចតទៅ៖ ក្រៀមក្រំ ជាពន់ពេក និង អៀនខ្មាស់ជាទីបំផុត ដោយខ្ញុំពុំបានធ្វើការ

---

[115] Samdech Sihanouk (Telegramme en date du 20 mai 1980 de) à Son Excellece In Tam, Bulletin Mensuel de Documentation no. 4, Juillet 1980.

[116] Samdech Sihanouk (Télégramme en date du 19 mai 1980 de) à Mr. KHEK Vandy, Colonel TIM Naing, Colonel BUOR Hell, Mme CHUON Saodi, Bulletin Mensuel de Documentation no. 4, Juillet 1980.

ជូនអស់លោកឲ្យបានជាវិជ្ជមាន និង ជួយអស់លោកឲ្យជាក់ស្តែងបានដោយហេតុថា៖ ទី១- ខ្ញុំពុំមានទ្រព្យសម្បត្តិធនធានគ្រប់គ្រាន់ ហើយសព្វថ្ងៃរស់នៅបានក៏អាស្រ័យដោយការទទួលឲ្យស្នាក់នៅដ៏សប្បុរសរបស់លោកប្រធានាធិបតី គីម អ៊ិល ស៊ុង នៃប្រទេសកូរ៉េខាងជើងតែប៉ុណ្ណោះ-ស្តុប- ទី២- ការខឹតខំទាក់ទងរបស់ខ្ញុំជាមួយរដ្ឋាភិបាល បារាំង ស.រ.អា និង ចិន ក្នុងការស្វែងរកជំនួយជូនអស់លោក ត្រូវទទួលបរាជ័យទាំងអស់-ស្តុប- ទី៣-ប្រទេសថៃ និង ប្រទេសចិន គេតម្រូវឲ្យអស់លោកចូលរួមទាំងស្រុងជាមួយខ្មែរក្រហម ទើបអស់លោកអាចទទួលជំនួយពីប្រទេសចិនបាន-ស្តុប- ទី៤-ប្រទេសថៃមិនចូលចិត្តខ្ញុំទេ ហើយមិនអនុញ្ញាតឲ្យខ្ញុំជាន់ទឹកដីគេទេ-ស្តុប-ខ្ញុំគោរពអស់លោក គាំទ្រអស់លោកយ៉ាងខ្លាំងក្លាបំផុត ហើយខ្ញុំមានករណីយកិច្ចសូមផ្តល់យោបល់ជូនអស់លោក សូមឲ្យយកតំរាប់តាមឯកឧត្តម សឺន សាន និង រណសិរ្សរបស់គាត់ ឬ បើល្អជាងនេះទៅទៀតចូលរួមជាមួយគាត់ ដើម្បីទទួលបាននូវជំនួយដ៏ចាំបាច់ទាំងឡាយពីប្រទេសចិន ពីប្រទេសថៃ និង ពី សេ អ៊ី អា របស់សហរដ្ឋអាមេរិក-ស្តុប-សូមអស់លោកកុំប្រាប់គេថា អស់លោកធ្វើការតស៊ូ ដើម្បីសីហនុ ព្រោះថាបើធ្វើការតស៊ូដើម្បីសីហនុនោះ អស់លោកប្រាកដជាពុំបានទទួលជំនួយអ្វីពីប្រទេសចិន និង ពុំទទួលការការពារពីរដ្ឋាភិបាលថៃឡើយគឺ ការការពារដែលអស់លោកកំពុងត្រូវការខានពុំបាន-ស្តុប-អស់លោកត្រូវធ្វើការជាមួយ ប្រទេសចិន និង រដ្ឋាភិបាលថៃ បើមិនដូច្នេះទេ អស់លោកនឹងពុំមានមធ្យោបាយ សំរាប់ធ្វើការតស៊ូឡើយ" ។

នៅសម័យនោះពួកយុវជនដូចខ្ញុំយល់ថាសម្តេច សីហនុ មានព្រះទ័យមិននឹងន់សោះ ព្រោះក្នុងកាលកន្លងមក ព្រះអង្គបានដូរព្រះទ័យជាច្រើនដងច្រើនគ្រាមកហើយ ។ ការសំរេចព្រះទ័យរបស់ព្រះអង្គថាដកព្រះកាយចេញពី "នយោបាយ" នោះអាចគ្រាន់តែបង្ហាញនូវការបរាជ័យមួយ ឬ ក៏ជាការគិតគូរដ៏មានល្បិចកលផ្នែក

នយោបាយមួយរបស់ព្រះអង្គតែប៉ុណ្ណោះ ។ តើការគិតគូរផ្នែកនយោបាយរបស់ព្រះអង្គនោះ ជាការគិតគូរដើម្បីយកចំណេញសំរាប់តួព្រះអង្គផ្ទាល់ ឬ ដើម្បីជាផលប្រយោជន៍ដល់មូលហេតុជាតិ? ការវិវត្តផ្នែកនយោបាយនាពេលក្រោយមកទៀតនឹងបញ្ជាក់អំពីធាតុពិតនៃការគិតគូរនយោបាយនេះ ។

តាមពិតតាំងពីព្រះអង្គ បានរំដោះព្រះកាយរួចចេញពីការត្រួតត្រារបស់ពួកខ្មែរក្រហមមក សម្តេច សីហនុ បានបញ្ជូនសញ្ញាមួយចំនួន ដើម្បីម្យ៉ាងឲ្យប្រជារាស្ត្រខ្មែរយល់នូវព្រះទ័យសោកស្តាយ និង ខ្លោចផ្សាជាអនេករបស់ព្រះអង្គ ចំពោះទុក្ខវេទនា និង មហាវិនាសកម្ម ដែលបង្កឡើងដោយពួកខ្មែរក្រហម ព្រោះថាសូម្បីតែសម្តេចព្រះអង្គឯងក៏ត្រូវជាប់បង្ខាំងក្នុងព្រះរាជវាំង ជាអ្នករងគ្រោះដោយរបបប៉ុល ពត ដែរ ។ ម្យ៉ាងទៀត ព្រះអង្គក៏មានបំណង ឲ្យប្រជារាស្ត្រយល់នូវព្រះទ័យស្នេហាជាតិរបស់ព្រះអង្គ ដែលទ្រង់នៅតែដើរតួនាទីក្នុងប្រពៃណីជាប្រមុខរបស់ខ្មែរក្នុងព្រះឋានៈជាអតីតព្រះមហាក្សត្រដែលខ្មែរធ្លាប់គោរពស្មើព្រះអាទិទេពទេនោះ ។ ចំពោះអ្នកដឹកនាំក្រុងហាណូយ ព្រះអង្គបង្ហាញសញ្ញាថា ប្រសិនទទួលយកព្រះអង្គជាដៃគូនោះ ព្រះអង្គនឹងជួយវៀតណាម ឲ្យបញ្ចប់ជម្លោះនៅកម្ពុជាដោយសន្តិវិធី និង មិត្តភាព ។ ចំពោះចលនាតស៊ូ និង សម្ព័ន្ធមិត្ត ដែលកំពុងធ្វើការតតាំងប្រឆាំងក្រុងហាណូយ ព្រះអង្គបង្ហាញសញ្ញាថា ព្រះអង្គអាចនឹងផ្លាស់ប្តូរគោលជំហរពីការតស៊ូប្រឆាំងទៅជាសហការជាមួយក្រុងហាណូយវិញក៏បាន ប្រសិនបើចលនាតស៊ូ និង សម្ព័ន្ធភាពទាំងនោះមិនយកចិត្តទុកដាក់ចំពោះព្រះអង្គទេនោះ ។

## ពេលនោះលោកតា ដើរតួឯក

ដោយធ្វើជាមិនយល់ ឬ ដោយមានចេតនាកេងយកចំណេញផងក៏មិនដឹង លោកតា សឺន សាន បានចាប់យកពាក្យអំពាវនាវរបស់សម្តេច សីហនុ ចំពោះអ្នក

គាំទ្រ ដែលព្រះអង្គណែនាំឲ្យមកចូលរួមជាមួយរ.ជ.រ.ប.ខ.ជាការគាំទ្រពិតប្រាកដរបស់សម្តេច ។ នៅរដូវក្តៅនាឆ្នាំ ១៩៨០ លោកតា សឺន សាន បានត្រឡប់មកកាន់ទីក្រុងប៉ារីសវិញ ។ វត្តមានរបស់លោកតាបានលើកទឹកចិត្តដល់ពួកយើងយ៉ាងខ្លាំងអស្ចារ្យ ព្រោះថានៅពេលដែលគ្មានតួអង្គសម្តេច សីហនុ នៅក្នុងឆាកនយោបាយខ្មែរ លោកតា សឺន សាន បានលេចធ្លោឡើងជាអ្នកដឹកនាំអ្នកជាតិនិយមតែម្នាក់គត់ ដែលគួរឲ្យទុកចិត្តបាន ។

ខ្ញុំបានចំណាយពេលស្ទើរតែទាំងអស់របស់ខ្ញុំ ចូលរួមក្នុងក្រុមអ្នកជំនួយការរបស់លោកតា ដើម្បីរៀបចំកម្មវិធីប្រជុំការងារ ឬ សន្និសីទកាសែត ឬ ធ្វើទស្សនកិច្ចទៅតាមសហគមន៍ខ្មែរទូទាំងប្រទេសបារាំង ។ នៅថ្ងៃទី ១០ កក្កដា ១៩៨០ លោកតា សឺន សាន បានអញ្ជើញទៅធ្វើបទអន្តរាគមន៍នៅចំពោះមុខសាស្ត្រាចារ្យ និង និស្សិតនៃសាលាយោធាបារាំង (Ecole Militaire) ដែលនៅក្នុងឱកាសនោះលោកតាបានធ្វើការថ្កោលទោសពួកកុម្មុយនីស្តអាស៊ីមានខ្មែរក្រហម និង ក្រុងហាណូយ ។ លោកតាថ្កោលទោសខ្មែរក្រហម ចំពោះអំពើប្រល័យពូជសាសន៍ឯងដែលគេមិនដែលឃើញមានសោះ នៅក្នុងប្រវត្តិសាស្ត្រពិភពលោក ។ លោកតាថ្កោលទោស ចំពោះក្រុងហាណូយ ដែលលោកតាចោទថា កំពុងបន្តអំពើប្រល័យពូជសាសន៍ តាមរយៈការកេងប្រវ័ញ្ចជំនួយអន្តរជាតិ តាមរយៈអំពើលួចប្លន់ តាមរយៈអំពើគំរាមកំហែងដល់ប្រាសាទអង្គរ តាមរយៈការដាក់ឲ្យប្រើនូវប្រាក់ "រៀលក្លែងក្លាយ" តាមរយៈការដាក់បង្ខំឲ្យប្រើនូវរដ្ឋធម្មនុញ្ញខុសច្បាប់ តាមរយៈការរៀបចំនូវការបោះឆ្នោតមិនត្រឹមត្រូវ តាមរយៈការបង្កើតតុលាការបដិវត្ត និង ការដាក់គុកតាមរបៀប ប៉ុល ពត ។ លោកតា សឺន សាន ថ្លែងក្នុងឱកាសនោះថា ប្រសិនបើចលនា រ.ជ.រ.ប.ខ. បានទទួលជំនួយគ្រប់គ្រាន់ដើម្បីបោះជំហានទៅមុខ និង ដើម្បីបំរើ ការពារប្រជាពលរដ្ឋខ្មែរនោះ រ.ជ.រ.ប.ខ.នឹងបានទទួលការគាំទ្រកាន់តែខ្លាំង

ឡើងពីប្រជាពលរដ្ឋ នាំឲ្យប្រជាពលរដ្ឋខ្មែរអាចក្រោកឈរឡើង និង ឈប់សហការជាមួយក្រុងហាណូយតទៅទៀត ។ លោកតាប្រធានថ្លែងថា៖ "វៀតណាម នឹងជួបការលំបាកផ្ទៃក្នុងកាន់តែធ្ងន់ធ្ងរឡើង ហើយពួកគេនឹងទទួលយកនូវសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិចុះថ្ងៃទី ១៤ វិច្ឆិកា ១៩៧៩ ដែលក្នុងនោះតម្រូវឲ្យក្រុងហាណូយដកកងទ័ពរបស់ខ្លួនឲ្យអស់ពីកម្ពុជា ដើម្បីឲ្យប្រជារាស្ត្រខ្មែរសំដែងឆន្ទៈរបស់ខ្លួនដោយសេរី" ។ លោកតាប្រធានចង់និយាយថា ប្រសិនបើ រ.ជ.រ.ប.ខ. ទទួលជំនួយគ្រប់គ្រាន់ពីប្រទេសលោកសេរី ចលនានេះអាចនឹងធ្វើជាគំរូគេក្នុងការតស៊ូប្រឆាំងកុម្មុយនីស្តសំរាប់តំបន់នានាឯទៀតនៅក្នុងពិភពលោក ។ ក្នុងន័យនេះ លោកតាមានប្រសាសន៍តាមពាក្យបុរាណខ្មែរថា៖ "ភ្លើងឆេះពីសំរាម" សំរាមរបស់ពួកយុទ្ធជនសេរីមូចាហេឌីន (Mujaheddin) អាហ្គានីស្ថាន នឹងបង្កើតជាភ្លើងអគ្គីភ័យក្នុងតំបន់មជ្ឈឹមបូព៌ា រីឯសំរាម រ.ជ.រ.ប.ខ. នឹងបង្កើតជាអគ្គីភ័យនៅកម្ពុជា ។ ដូច្នេះ "សូមប្រទេសលោកសេរីមេត្តាជួយយើងខ្ញុំ និង សូមជួយយើងខ្ញុំជាបន្ទាន់"[117] ។

ដើម្បីបង្ហាញថាលោកតាជាអ្នកដឹកនាំអ្នកជាតិនិយម ដែលបានទទួលបានការគាំទ្រពីខ្មែរគ្រប់និន្នាការនយោបាយនោះ លោកតា សឺន សាន បានសំអាងទៅលើសេចក្តីប្រកាសគាំទ្រពីសម្តេច សីហនុ (ទ្រង់ថ្លែងក្នុងខែ ឧសភា ១៩៨០) និង លោកសេនាប្រមុខ លន់ នល់ ។ លោកតាថ្លែងថា៖ "សម្តេចសីហនុ និង លោកសេនាប្រមុខ លន់ នល់ បានសុំឲ្យយុទ្ធជនអ្នកជាតិនិយមទាំងអស់ចូលរួមជាមួយ រ.ជ. រ.ប.ខ. ។ ក្នុងនាមយុទ្ធទាំងនោះ ខ្ញុំសូមសំដែងអំណរគុណដល់ឥស្សរជនជាន់ខ្ពស់ទាំងពីររូបនេះ" ។

---

[117] Son Sann, Conférence sur les Perspectives Cambodgiennes, A l'Ecole Militaire, le 10 Juillet 1980, Bulletin du Front National de Libération du Peuple Khmer no. 7, Juillet 1980, pp. 9-13.

# ជំរុំ រ.ជ.រ.ប.ខ. រងការវាយប្រហារ

នៅក្នុងពេលដែល រ.ជ.រ.ប.ខ. កំពុងស្វែងរកជំនួយអន្តរជាតិ កងទ័ពក្រុងហាណូយ បានសាកល្បងវាយបំផ្លាញកងកម្លាំងយោធានៃចលនាអ្នកជាតិនិយម ។ នៅថ្ងៃទី ២៣ មីនា ១៩៨០ ពួកគេវាយប្រហារមកលើភូមិសុខសាន្ត ដោយបានបាញ់កាំភ្លើងធំធុន ១០៥ មម និង ១២២ មម ដែលក្នុងនោះត្រូវបានចោទប្រកាន់ថាមានបង្កប់ទៅដោយជាតិឧស្ម័នធ្វើឲ្យប្រជាពលរដ្ឋស៊ីវិលភ័យស្លន់ស្លោ ហើយត្រូវជំលៀសចេញទៅនៅក្នុងតំបន់ផ្សេងដែលមានសុវត្ថិភាពជាង ។ ចាប់ពីថ្ងៃទី ២៥ ទៅ ២៧ មេសា ១៩៨០ កងទ័ពវៀតណាមវាយប្រហារជាថ្មីទៀតទៅលើភូមិសុខសាន្ត នៅចំពេលដែលរ.ជ.រ.ប.ខ. កំពុងធ្វើសមាជជាតិរបស់ខ្លួនក្នុងតំបន់មួយផ្សេងពីទីនោះ ។ រ.ជ.រ.ប.ខ. បានធ្វើការថ្កោលទោសការវាយប្រហារនេះថាជាការបន្តអំពើប្រល័យពូជសាសន៍ ដែលប្រព្រឹត្តឡើងដោយពួកវៀតណាមខាងជើងទៅលើប្រជារាស្ត្រខ្មែរ ។ ឆ្លៀតក្នុងឱកាសនោះ រ.ជ.រ.ប.ខ. ក៏អំពាវនាវសុំជំនួយបន្ថែម ។ នៅសម័យនោះ រ.ជ.រ.ប.ខ. បានធ្វើការថ្លឹងថ្លែងពាក្យពេចន៍ណាស់ ដោយប្រើតែពាក្យ កងទ័ពវៀតណាមខាងជើង ព្រោះជាកងទ័ពកុម្មុយនីស្ត និង មិនចេញឈ្មោះកងទ័ពរបស់លោក ហេង សំរិន - ហ៊ុន សែន ទេ ដោយចង់បង្ហាញឲ្យឃើញថាសង្គ្រាមសម័យនោះ មិនមែនជាសង្គ្រាមរវាងខ្មែរ និង ខ្មែរនោះឡើយ ។

សេចក្តីប្រកាសរបស់រ.ជ.រ.ប.ខ.បានថ្លែងជាអាទិថា៖ "រ.ជ.រ.ប.ខ. មានមោទនភាពចំពោះកងកម្លាំងរបស់ខ្លួន ហើយមិនខ្លាចនឹងប្រកាសជាថ្មីម្តងទៀតថា រ.ជ.រ.ប.ខ.មិនខ្វះអ្នកស្ម័គ្រចិត្តកាន់អាវុធ ដែលមានសេចក្តីក្លាហាន និង ការប្តេជ្ញាចិត្តដ៏រឹងមាំដូចយុទ្ធជននៅសុខសាន្តនោះឡើយ ។ អ្វីដែលខ្វះខាតគឺ កាំភ្លើង និង ជាពិសេស គ្រាប់រំសេវ ។ សូមមេត្តាផ្តល់ដល់ រ.ជ.រ.ប.ខ. នូវកាំភ្លើង និង គ្រាប់រំសេវ

ទាំងនោះឲ្យបានចំនួនគ្រប់គ្រាន់ ។ រ.ដ.រ.ប.ខ. នឹងមានលទ្ធភាពបង្កវិបត្តិកាន់តែធ្ងន់ធ្ងរឡើងដល់កងទ័ពឈ្លានពានវៀតណាមខាងជើង ដើម្បីបានស្រោចស្រង់ជាតិសាសន៍ និង ប្រជាជាតិខ្មែរ" ។

ការវាយប្រហារដោយកងទ័ពវៀតណាមប្រមាណជាង ៣០០០ នាក់ទៅលើភូមិខ្មែរដ៏សុខសាន្តមួយបានបង្កក្តីលំបាកដល់ រ.ដ.រ.ប.ខ. ក៏ប៉ុន្តែជាមួយគ្នានោះក៏បានបង្ហាញថា ចលនានេះបានក្លាយជាកម្លាំងមួយ ដែលកងទ័ពវៀតណាមត្រូវតែទទួលស្គាល់ និង បំផ្លាញចោលឲ្យបាន ។ នៅពេលដែលការវាយប្រហារដោយកម្លាំងមានសភាពកាន់តែខ្លាំងក្លាឡើង យើងក៏ចាប់ផ្តើមឮពាក្យស្តីពីការចរចាបញ្ចប់សង្គ្រាមដែរ ទោះបីជាភាគីនីមួយៗមានយុទ្ធសាស្ត្រផ្សេងៗគ្នាក៏ដោយ ។ តាមការស្នើធ្វើការចរចាជាមួយប្រទេសអាស៊ាន ក្រុងហាណូយមានបំណងស្វែងរកការទទួលស្គាល់ជាអន្តរជាតិជូនដល់របបក្រុងភ្នំពេញ ដែលបានឡើងកាន់អំណាចបន្ទាប់ពីការដួលរលំនៃរបបប៉ុលពត ។

ពីថ្ងៃទី ១៧ ដល់ ១៨ កក្កដា រដ្ឋមន្ត្រីនៃប្រទេសវៀតណាម លាវ និង កម្ពុជា (រដ្ឋាភិបាល ហេង សំរិន នៅភ្នំពេញ) បានជួបប្រជុំគ្នានៅទីក្រុងវៀងច័ន្ទ ។ ដោយមានការគាំទ្រពីប្រទេស លាវ និង វៀតណាម រដ្ឋាភិបាល ហេង សំរិន បានលើកសំណើដើម្បី "កាត់បន្ថយភាពតានតឹង និង ដើម្បីកែប្រែព្រំប្រទល់ថៃ-កម្ពុជាឲ្យទៅជាព្រំប្រទល់មួយប្រកបដោយសន្តិភាព និង មិត្តភាព" ។ ក៏ប៉ុន្តែពួកយើងនៅទីក្រុងបាងកកវាយតម្លៃថា រដ្ឋមន្ត្រីនៃប្រទេសទាំងបីនិយាយពីបញ្ហាជនភៀសខ្លួន ដើម្បីឲ្យរបបភ្នំពេញបានទទួលការទទួលស្គាល់ពីអន្តរជាតិ ។ សំណើនោះមានជាអាទិ៍៖ "ការបង្កើតតំបន់គ្មានកងទ័ព នៅតំបន់ទល់ដែនចន្លោះប្រទេសកម្ពុជា និង ថៃ និង បង្កើតគណៈកម្មការចម្រុះ ដើម្បីអនុវត្តកិច្ចព្រមព្រៀងជានាសន្តិភាព និង ស្ថេរភាពនៅតំបន់ទល់ដែន -ការចរចាដើម្បីឲ្យជនភៀសខ្លួនទៅតាំងទីឲ្យ

ឆ្ងាយពីទល់ដែន ដើម្បីជៀសវាងការប៉ះអាវុធគ្នា -ដកអាវុធពីកងទ័ព ប៉ុល ពត និង កងកម្លាំង "ប្រតិកិរិយា" ទាំងអស់ និង បញ្ជូនពួកគេទាំងនេះទៅក្នុងជំរុំដោយឡែក -ចែកជំនួយអន្តរជាតិដល់ខាងក្នុងប្រទេសកម្ពុជា មិនមែននៅតាមទល់ដែនគឺចែក ជំនួយតាមកិច្ចព្រមព្រៀងរវាងអង្គការអន្តរជាតិជាមួយរដ្ឋាភិបាល ហេង សំរិន នៅ ភ្នំពេញ ។

# ពួកបរទេសថា លោកតាក្បាលរឹង

តាំងតែពីពេលដែលបានត្រូវប្រកាសជាសាធារណៈនាខែ តុលា ១៩៧៩ រ.ជ.រ.ប.ខ. បានរងនូវការគាបសង្កត់ពីសំណាក់អ្នកគាំទ្រអន្តរជាតិរបស់ខ្លួន ជាពិសេសពីប្រទេសចិន និង ប្រទេសថៃ ឲ្យចូលរួមជាមួយខ្មែរក្រហម ។ ថ្នាក់ដឹកនាំ រ.ជ.រ.ប.ខ.តែងតែប្រកាសឲ្យដឹងជាសាធារណៈនូវបំណងរបស់ រ.ជ.រ.ប.ខ. ក្នុងការបង្កើតរដ្ឋាភិបាលមួយ ដែលមានមុខមាត់សមរម្យគ្រាន់បើជាងខ្មែរក្រហមហើយ តែងតែប្រកែកពុំព្រមចូលរួមជាមួយពួកប្រល័យពូជសាសន៍នេះជានិច្ច ។ ទាំងនេះធ្វើឲ្យប្រទេសថៃដាក់ការគាបសង្កត់ទៅលើ រ.ជ.រ.ប.ខ.។ ការគាបសង្កត់ធ្ងន់ធ្ងរបែបជាទណ្ឌកម្ម តែងតែធ្វើឡើងដោយក្រុមយោធាថៃ ។ ជារួមការគាបសង្កត់នោះ មានការកាត់ផ្តាច់ជំនួយផ្នែកស្បៀងអាហារ ថ្នាំពេទ្យ និង គ្រាប់រំសេវ នៅពេលណាដែលអនុសាសន៍ទាំងឡាយរបស់ក្រុមយោធាទាំងនោះ មិនត្រូវបានអនុវត្តទាំងស្រុង ។

តាំងពីខែ កុម្ភៈ ដល់ មិថុនា ១៩៨០ លោកតា សឺន សាន ដែលពួកបរទេសឲ្យឈ្មោះថាជាអ្នកនយោបាយក្បាលរឹង (Stubborn politician) បានទប់ទល់មិនព្រមធ្វើតាមការគាបសង្កត់របស់ក្រុមយោធាថៃដែលបង្ខំឲ្យធ្វើសម្ព័ន្ធភាពជាមួយខ្មែរក្រហម ។ លោកតាបានធ្វើឲ្យពួកថៃមិនសប្បាយចិត្ត ធ្វើឲ្យពួកគេផ្តាច់ស្បៀងទាំងស្រុងដល់ រ.ជ.រ.ប.ខ. ។ នៅពេលនោះ កងទ័ពរបស់ រ.ជ.រ.ប.ខ. ស្ថិតនៅក្នុង

សភាពការណ៍មួយ ដែលស្ទើរតែដាច់ពោះទាំងអស់ទៅហើយ ។ ការចេញដំណើររបស់លោកតា សឺន សាន ទៅទ្វីបអឺរ៉ុប នៅរដូវក្តៅនាឆ្នាំ ១៩៨០ មានគោលដៅឲ្យលោកតាមានសេរីភាព បន្ថែមលើសកម្មភាពស្វែងរកជំនួយពីលោកខាងលិចផង និង ឲ្យលោកតាស្ថិតក្រៅពីការគាបសង្កត់របស់ថៃផង ។ ក្នុងខែ កញ្ញា ១៩៨០ នៅពេលដែលលោកតាសួរទៅសហការីជាសមាជិកកូម៉ិចថា តើពេលវេលាសមស្របឬនៅ ដើម្បីឲ្យលោកតាវិលត្រឡប់កាន់មូលដ្ឋានវិញ? នៅក្នុង ចម្លើយចុះថ្ងៃទី ៤ តុលា ១៩៨០ លោក នាង ជិនហន អគ្គលេខាធិការ លោក ហ៊ីង គន្ធុន សមាជិកកូម៉ិច លោកឧត្តមសេនីយ ដៀន ដែល នាយសេនាធិការកងទ័ពបានឆ្លើយថា៖[118] "គណៈកម្មាធិការប្រតិបត្តិ កូម៉ិច និង ជំរុំ ទាំងអស់ចង់បានលោកប្រធានត្រឡប់មកវិញណាស់ ។ ពួកយើងនឹកលោកប្រធានណាស់ ។ ក៏ប៉ុន្តែក្នុងកាលៈទេសៈបច្ចុប្បន្នជាការល្អបំផុត ប្រសិនបើលោកប្រធានអាចបន្តធ្វើការ ដោយចល័ត ឬ ធ្វើទំនាក់ទំនង ឬ ចាត់ការពីខាងក្រៅ ព្រោះនៅឯនោះ លោកប្រធានមានសេរីភាពជាង និង មានលទ្ធភាពទទួលជោគជ័យច្រើនជាង ។ សភាពការណ៍ ដែលយើងធ្លាប់ជួបប្រទះពីខែ កុម្ភៈ រហូតខែ មិថុនា ១៩៨០ (ថៃផ្តាច់ស្បៀង) យើងនៅចងចាំជានិច្ច ។ ការខំប្រឹងប្រែងរបស់យើងខ្ញុំ ធ្វើឡើងដើម្បីឲ្យសំរេចនូវការណែនាំដ៏ខ្ពង់ខ្ពស់របស់លោកប្រធានក្នុងដំណើរឆ្ពោះទៅមុខ" ។ សូមបញ្ជាក់ថា ចាប់ពីខែកុម្ភៈ ដល់ខែ មិថុនា ១៩៨០ យោធាថៃបានកាត់ផ្តាច់ស្បៀងដល់កងទ័ព រ.ជ.រ.ប.ខ.។ ក្នុងសារនេះ ក៏មានរាយការណ៍ជូនលោកតាប្រធានអំពីការប៉ុនប៉ងទាក់ទងជាមួយសហភាពសូវៀត តាមរយៈអ្នកកាសែតអូស្ត្រាលីម្នាក់ឈ្មោះ ណែល ដេវីស (Neil Devis) ។ លោក ណែល ដេវីស (Neil Devis) បានផ្តល់ព័ត៌មានអំពីការគិតគូរថ្មីរបស់សហភាពសូវៀត ក្នុងការដោះស្រាយបញ្ហាកម្ពុជា ។ អ្នក

[118] Neang Chin Han, Hing Kunthon, Dien Del, Note d'Information du 4 Octobre 1980.

កាសែតរូបនេះ បានទទួលរងគ្រោះរហូតដល់ស្លាប់ ដោយសារគ្រាប់កាំភ្លើងដែលទាហានបាញ់គ្នា នៅពេលកំពុងថតយកព័ត៌មានផ្ទាល់ក្នុងរដ្ឋប្រហារយោធាថៃ នៅទីក្រុងបាងកកនាឆ្នាំ ១៩៨៥ ។

## ក្រុមកូម៉ិច ជ្រើសរើសសមាជិកថ្មី

ទោះបីជាគាត់ស្ថិតនៅក្រោមការគាបសង្កត់ឲ្យរួមរួបជាមួយខ្មែរក្រហមក្តី ក៏លោកតា សឺន សាន ត្រូវមានការប្រុងប្រយ័ត្នចំពោះសកម្មភាពរបស់សហការីនៅក្នុងរង្វង់កូម៉ិចដែរ ដែលនៅក្នុងនោះមានសមាជិកសំខាន់ៗខ្លះ ចាប់ផ្តើមបង្កើតឥទ្ធិពលផ្ទាល់ខ្លួនទៅលើចលនានេះជាបណ្តើរៗទៅហើយ ។ នៅក្នុងពេលអវត្តមានរបស់ប្រធាន រ.ជ.រ.ប.ខ. ក្រុមកូម៉ិច បានជ្រើសរើសសមាជិកថ្មីម្នាក់ នៅទីក្រុងបាងកក ឈ្មោះលោក ហ្គាហ្វា ពាងម៉េត អតីតអនុព័ន្ធសារព័ត៌មានរបស់ស្ថានទូតខ្មែរប្រចាំទីក្រុងវ៉ាស៊ិនតោន សហរដ្ឋអាមេរិក ដែលជាបញ្ញវន្តម្នាក់ជិតស្និទ្ធជាមួយលោក លន់ ណុន ប្អូនប្រុសដ៏ល្បីឈ្មោះរបស់លោក លន់ នល់ អតីតប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ ។ សម័យនោះ យើងហៅបញ្ញវន្តរូបនេះត្រឹមតែឈ្មោះ ហ្គាហ្វា តែប៉ុណ្ណោះ ។ តាមឯកសារផ្ទៃក្នុងរបស់ រ.ជ.រ.ប.ខ. ដែលខ្ញុំរកឃើញនៅពេលក្រោយៗមក គេបានរាយការណ៍ថា នៅពេលដែលលោក លន់ ណុន ស្លាប់នៅឆ្នាំ ១៩៧៥ ហ្គាហ្វា បានទាក់ទងស្នេហា ជាមួយប្រពន្ធរបស់លោក លន់ ណុន ទោះបីជា ហ្គាហ្វា មានប្រពន្ធសញ្ជាតិអាមេរិករួចហើយក៏ដោយ ។ ក៏ប៉ុន្តែតាមទ្រឹស្តីរបស់ រ.ជ.រ.ប.ខ. នាពេលនោះដែលថា អ្វីដែលកន្លងមកហើយត្រូវតែបំភ្លេចចោលទៅនោះ លោក ហ្គាហ្វា ក៏ត្រូវបានអនុញ្ញាតឲ្យចូលជាសមាជិក រ.ជ.រ.ប.ខ. ហើយត្រូវបានបង្ហាញជូនលោកតា សឺន សាន តាមសារចុះថ្ងៃទី ៤ តុលា ១៩៨០[119] ។

[119] Neang Chin Han, Hing Kunthon, Dien Del, Note d’Information, op. cit.

សមាជិកគណៈកម្មាធិការប្រតិបត្តិកូម៉ិចនៅបាងកក អបអរសាទរចំពោះ ហ្គាហ្វា និង លើកសរសើរថាហ្គាហ្វាជាសមាសភាពមួយដ៏ឆ្នើម ព្រោះមានសញ្ញាប័ត្របណ្ឌិតផ្នែកនយោបាយមកពីសហរដ្ឋអាមេរិកផង ។ សារនោះបានជំរាបលោកតា សឺន សាន ថា ហ្គាហ្វា នឹងទៅធ្វើការជាមួយលោកឧត្តមសេនីយ ដៀន ដែលនៅក្នុងតំបន់កណ្តាលជាការសាកល្បង ។ នៅសម័យនោះ រ.ជ.រ.ប.ខ. ចែកចេញជាបីតំបន់ ។ តំបន់នីមួយៗស្ថិតនៅក្រោមការទទួលខុសត្រូវនៃនាយទាហានមួយរូបគឺ៖ តំបន់កណ្តាលស្ថិតនៅក្រោមលោកឧត្តមសេនីយ ដៀន ដែល តំបន់ខាងជើង លោកវរសេនីយឯក អ៊ឹម ឈូដេត និង តំបន់ខាងត្បូងនៅក្រោមលោកវរសេនីយទោ ព្រុំ វិត ។ សូមបញ្ជាក់ថាឋានន្តរសក្តិឧត្តមសេនីយ ឬ វរសេនីយទាំងនោះ ជាឋានន្តរសក្តិចាស់តាំងសម័យសាធារណរដ្ឋខ្មែរមកម្ល៉េះ ។

## ការិយាល័យផ្សាយព័ត៌មាន រ.ជ.រ.ប.ខ. នៅក្រៅប្រទេស

ជាមួយគ្នានោះដែរ រ.ជ.រ.ប.ខ. ក៏បានបង្កើតការិយាល័យផ្សាយព័ត៌មាននៅអឺរ៉ុប សហរដ្ឋអាមេរិក និង ជប៉ុន ។ នៅទីក្រុងឡុងដ៍នៃប្រទេសអង់គ្លេសការិយាល័យផ្សាយព័ត៌មានបានត្រូវដឹកនាំដោយលោក ប៉ែន វ៉ន[120] ដែលជាអតីតមន្ត្រីនៃធនាគារជាតិខ្មែរ ធ្លាប់ធ្វើការក្រោមបង្គាប់លោកតា សឺន សាន កាលលោកតាកាន់តំណែងជាអគ្គទេសាភិបាលក្នុងទសវត្សរ៍ឆ្នាំ១៩៥០-១៩៦០ ។ ឯសមាជិកឯទៀតនៃការិយាល័យផ្សាយព័ត៌មាននៅប្រទេសអង់គ្លេសនោះមានជាអាទិ៍៖ បណ្ឌិត ឡៅ ម៉ុង ហៃ បណ្ឌិត ប៊ិច ប៊ុន ថាត បណ្ឌិត ហេង ផល្លាសម្បត្តិ លោក នៅ កាណុន

[120] Son Sann, Front National de Libération du Peuple Khmer, Décision no. 80/05/FNL, Territoire Khmer, le 9 Octobre 1980.

លោក ម៉ឹង ភោគ លោក ជា ប៊ុននី លោក អ៊ឹង ប៊ុន គួង និង លោក តាន់ មៀន ។

ចំណែកឯការិយាល័យប្រចាំសហរដ្ឋអាមេរិក ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់លោកវរសេនីយឯកកងទ័ពអាកាស សង្វារ ជីឡូប៉េស[121]និង មានសមាជិកមួយចំនួនដូចជា៖ លោកស្រី ណុប ប៉ារ៉ាមូន លោក សុខ សុវណ្ណគុណ លោក ភោគ សូផាត និង លោក ព្រុំ ហ៊ន ជាដើម ។

ការិយាល័យប្រចាំទីក្រុងប៉ារីស ប្រទេសបារាំង បានត្រូវបង្កើតជាផ្លូវការដោយមានលោកតា លឹម គ្រី អតីតរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សម័យសម្តេច សីហនុ ជាប្រធាន ។ សូមរំលឹកថា ការិយាល័យប្រចាំក្រុងប៉ារីសនេះ ត្រូវបានទទួលស្គាល់ដោយគណៈកម្មាធិការប្រតិបត្តិ កូម៉ិច ជាផ្លូវការនៅខែ តុលា ១៩៨១ តែប៉ុណ្ណោះ ទោះបីជាការិយាល័យនេះ បានបើកទ្វារធ្វើការតាំងតែពីខែ តុលា ១៩៧៩ មកម្ល៉េះ ។ មេដឹកនាំ រ.ជ.រ.ប.ខ. មួយចំនួនដែលមានឥទ្ធិពលនៅក្នុងកូម៉ិច នៅទីក្រុងបាងកក មានការអល់អែកក្នុងការទទួលស្គាល់សមាសភាពការិយាល័យនេះ ព្រោះគេយល់ឃើញថាសមាសភាពនោះសុទ្ធតែជាមនុស្សជិតស្និទ្ធជាមួយលោកតា សឺន សាន ជាជាងមានភក្តីភាពចំពោះអង្គការ ឬ ស្ថាប័នដឹកនាំរបស់ រ.ជ.រ.ប.ខ. ដែលមានឈ្មោះថា កូម៉ិច ។

តាមការរៀបចំរចនាសម្ព័ន្ធរបស់ការិយាល័យផ្សាយព័ត៌មាន ប្រចាំនៅទីក្រុងប៉ារីសនេះ លោកតា លឹម គ្រី[122] ជាប្រធាន ដែលមានឧបការី និង ទីប្រឹក្សាមួយចំនួន ក្នុងនោះខ្លួនខ្ញុំជាឧបការីទទួលបន្ទុកកិច្ចការរដ្ឋបាល ។ សហសេវិកមួយចំនួនទៀត ដែលមានការទទួលខុសត្រូវផ្នែកផ្សេងៗគ្នានោះមាន៖ លោក នេត គួន

[121] Son Sann, Front National de Libération du Peuple Khmer, Décision no. 80/07/FNL, Territoire Khmer, le 31 Décembre 1980.
[122] Son Sann, Front National de Libération du Peuple Khmer, Décision no. 81/03/FNL, Territoire Khmer, le 12 Octobre 1981.

លោក សំ សុខ លោកស្រី លាង គឹមសេង និង លោក ចាយ សេរីវុធ ។ លោក សាយ បូរាណ មន្ត្រីតុលាការដ៏មានសមត្ថភាព ដែលគេរកបានដោយកម្រនៅកម្ពុជា ធ្លាប់ធ្វើជាអគ្គលេខាធិការនៃការិយាល័យនេះ បន្តជួយធ្វើការងារក្នុងឋានៈជាទីប្រឹក្សា ។

## សម្តេច សីហនុ ត្រៀមចូលរួមជាថ្មីជាមួយខ្មែរក្រហម

គ្រាន់តែមួយខែបន្ទាប់ពីព្រះអង្គប្រកាសឈប់ធ្វើនយោបាយសម្តេច សីហនុ បានប្តូរព្រះទ័យព្រះអង្គជាថ្មីម្តងទៀតនៅខែ មិថុនា ១៩៨០ ដោយព្រះអង្គប្រកាសថា ព្រះអង្គត្រៀមព្រះកាយចូលរួមជាមួយពួកខ្មែរក្រហម ។ សម្តេចស្នើថា ព្រះអង្គនឹងបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នបង្រួបបង្រួមគណបក្សជាច្រើន ជាមួយខ្មែរក្រហម ក្នុងនោះក៏មានអ្នកតំណាង រ.ជ.រ.ប.ខ.ដែរ ប្រសិនបើពួក រ.ជ.រ.ប.ខ. ចង់ចូលរួម ។ ជាមួយនោះ ក៏មានរួមទាំងអ្នកគាំទ្ររដ្ឋាភិបាល ហេង សំរិន នៅភ្នំពេញផង ប្រសិនបើមានអ្នកខ្លះចង់ចូលរួម ដោយសម្តេចដាក់លក្ខខណ្ឌឲ្យពួកខ្មែរក្រហម ក្លាយខ្លួនមកត្រឹមតែគណបក្សនយោបាយ មិនឲ្យនៅជារដ្ឋាភិបាលដែលមានកងទ័ពតទៅទៀតឡើយ ។ សំណើនេះមានតម្លៃស្មើការរំលាយកម្លាំងយោធារបស់ខ្មែរក្រហមដែរ ។ នៅក្នុងសេចក្តីសម្ភាសន៍ផ្តល់ដល់ទស្សនាវដ្តីប្រចាំសប្តាហ៍ញូវស្វីក (Newsweek) សម្តេចបានប្រកាសឲ្យដឹងជាថ្មីម្តងទៀតនូវសំណើរបស់ព្រះអង្គ ។

នោះក៏គាប់ជួនចំពេលដែលលោកនាយករដ្ឋមន្ត្រីចិន ហ្សាវ ហ្ស៊ីយ៉ាង (Zao Ziyang) ទៅធ្វើទស្សនកិច្ចនៅប្រទេសថៃ និង ជួបសន្ទនាអំពីបញ្ហាកម្ពុជាជាមួយលោកនាយករដ្ឋមន្ត្រីថៃ ប្រេម ទិនស៊ុឡាណន្ត (Prem Tinsulanonda) ក្នុងខែ កុម្ភៈ ១៩៨១ ។ នៅពេលនោះ ប្រទេសថៃ និង ចិន កំពុងសម្លឹងរកមធ្យោ

បាយកោះប្រជុំសន្និសីទអន្តរជាតិមួយស្តីពីកម្ពុជា ដូចមានចែងក្នុងសេចក្តីសំរេចទាំងឡាយរបស់អង្គការសហប្រជាជាតិ ។ សូមបញ្ជាក់ថា នៅថ្ងៃទី ២២ តុលា ១៩៨០ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីសំរេចថ្មីមួយទៀត ដែលមានខ្លឹមសារដូចសេចក្តីសំរេចចុះថ្ងៃទី ១៤ វិច្ឆិកា ១៩៧៩ នោះដែរ ។ នៅថ្ងៃទី ១ កុម្ភៈ ១៩៨១ លោកនាយករដ្ឋមន្ត្រីចិន ហ្សាវ ហ្ស៊ីយ៉ាង បានបញ្ជាក់ពីគោលជំហររបស់រដ្ឋាភិបាលចិន ពាក់ព័ន្ធនឹងការតស៊ូខ្មែរ បន្ទាប់ពីត្រូវបានក្រុមប្រទេសអាស៊ានគាបសង្កត់ ឲ្យចិនជួយជំរុញឲ្យមានការផ្លាស់ប្តូររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ។ ចិនត្រៀមខ្លួនដើម្បីគាំទ្ររដ្ឋាភិបាលថ្មីដែលនឹងត្រូវដឹកនាំដោយលោកតា សឺន សាន ឬ សម្តេច សីហនុ ។

សេចក្តីបញ្ជាក់របស់លោកនាយករដ្ឋមន្ត្រីចិននេះ ជាសញ្ញាភ្លើងខៀវឲ្យមានការផ្លាស់ប្តូររដ្ឋាភិបាលខ្មែរក្រហមថ្មី ក៏ប៉ុន្តែការដែលចិនមិនបានបញ្ជាក់ឲ្យច្បាស់ថា រដ្ឋាភិបាលថ្មីនោះ ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់វរជនខ្មែរណាមួយច្បាស់លាស់ទេគឺ សម្តេច សីហនុ ឬ លោកតា សឺន សាន ។ ភាពមិនច្បាស់លាស់នេះ បានក្លាយទៅជាយុទ្ធវិធីដ៏ល្អមួយសំរាប់ពួកខ្មែរក្រហម យកទៅប្រើនៅពេលពួកគេធ្វើការចរចា ឬ តថ្លៃជាមួយសម្តេចសីហនុ និង ជាមួយលោកតា សឺន សាន ។ យុទ្ធវិធីនោះគឺ បើលោកតា សឺន សាន តឹងតែងពេក គេលួងលោមសម្តេច សីហនុ ឬ បើសម្តេចតឹងតែងពេក គេទៅយកចិត្តទុកដាក់ជាមួយលោកតា សឺន សាន ម្តងវិញ ។

ពួកខ្មែរក្រហមសំគាល់ឃើញថា លោកតា សឺន សាន ជាមនុស្សតឹងរ៉ឹងរឹងរូស ចំណែកឯសម្តេច សីហនុ មានជំហរទន់ភ្លន់ស្រួលធ្វើការជាមួយជាង នៅក្នុងរដ្ឋាភិបាលចម្រុះណាមួយនាពេលអនាគត ។ ដូច្នេះ ពួកខ្មែរក្រហមប្រើល្បិច ធ្វើឲ្យអ្នកដឹកនាំមិនមែនកុម្មុយនីស្តទាំងពីររូបប្រកួតប្រជែងគ្នា ។ ប្រសិនបើលោកតា

សឺន សាន នៅតែប្រកែកពុំព្រមចូលជាមួយពួកខ្មែរក្រហម ពួកនេះនឹងទៅចរចាជាមួយសម្ដេច សីហនុ ដែលទ្រង់ត្រៀមចូលរួមជាមួយខ្មែរក្រហមរួចជាស្រេច ។ គោលការណ៍ត្រីភាគីនិយម បានក្លាយទៅជាយុទ្ធវិធីមួយនៃការរៀបចំរដ្ឋាភិបាលចម្រុះថ្មីនៃពួកខ្មែរក្រហម ។

## មូលហេតុមិនចូលគ្នានៃក្រុម សឺន សាន និង សីហនុ

តាមការស្រាវជ្រាវ និង វិភាគក្រោយៗមក ទើបខ្ញុំអាចយល់ដឹងថា ហេតុអ្វីបានជាលោកតា សឺន សាន និង សម្ដេច សីហនុ ដែលជាមេដឹកនាំខ្មែរមិនមែនកុម្មុយនីស្ត មិនអាចចូលរួមក្នុងចលសនាតស៊ូតែមួយបាន ។ តាមពិតទៅ បន្ទាប់ពីបានរំដោះព្រះអង្គចេញពីពួកខ្មែរក្រហម ប៉ុល ពត រួចមក នាដើមឆ្នាំ ១៩៧៩ នោះ សម្ដេចឪ ឬ សម្ដេចតានៃយើងព្រះអង្គមានបំណងដកព្រះកាយទៅគង់នៅ ស.រ.អា ឬ នៅប្រទេសបារាំងឯណោះទេ ។ ក៏ប៉ុន្តែដោយសារប្រទេសទាំងពីរនេះ មិនបានឆ្លើយតបតាមសំណើរបស់ព្រះអង្គ និង ដោយមានការទទូចពីមេដឹកនាំចិន តេង ស៊ាវពីង សម្ដេច សីហនុ ក៏ព្រមយាងត្រឡប់ទៅគង់នៅប្រទេសចិនវិញនាដើមឆ្នាំ ១៩៧៩ ដូចខ្ញុំបានសរសេរខាងលើរួចហើយ ។

ចំណុចសំខាន់ដែលសម្ដេច សីហនុ មិនទាន់ចូលរួមសកម្មភាពនយោបាយណាមួយនាពេលនោះ ព្រោះព្រះអង្គកំពុងព្រួយព្រះទ័យយ៉ាងខ្លាំងចំពោះការបាត់បង់កូនចៅជាទីស្រឡាញ់របស់ព្រះអង្គ ដែលមេដឹកនាំចិនសន្យាថានឹងខឹតខំរកឲ្យឃើញ ។ ម្យ៉ាងទៀត សម្ដេចក៏ប្រហែលជារង់ចាំប្រតិកម្មរបស់វៀតណាម ក្នុងការស្វែងរកការចរចាគ្នាមួយ បន្ទាប់ពីព្រះអង្គផ្ញើលិខិតបីច្បាប់ទៅជូនលោកនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង នៃប្រទេសវៀតណាមក្នុងខែ តុលា ១៩៧៩ នោះ ។ ជាមួយគ្នានោះ ទំនងជាដើម្បីបើកផ្លូវឲ្យមានការចរចានេះ សម្ដេច សីហនុ ក៏បានស្នើឲ្យទុក

អាសនៈកម្ពុជាឲ្យនៅទំនេរ ទាំងនៅអង្គការសហប្រជាជាតិ ទាំងនៅក្នុងចលនាមិនចូលបក្សសម្ព័ន្ធ ដែលគ្រោងប្រជុំនៅទីក្រុងឡាហាវ៉ាននៅប្រទេសគុយបា ។ តាមពិត គោលជំហរទុកកៅអីកម្ពុជាឲ្យនៅទំនេរ ជាគោលជំហរដែលរដ្ឋាភិបាលភ្នំពេញចង់បាន ដែលផ្ទុយពីគោលជំហររបស់ចិន អាស៊ាន ខ្មែរក្រហម និង ពួកយើងនៅក្នុងក្រុមលោកតា សឺន សាន ។ ជាមួយនិងគោលជំហរទុកកៅអីកម្ពុជាឲ្យនៅទំនេរ សម្តេច សីហនុ ក៏សុំឲ្យមានការដកអាវុធពីគ្រប់ក្រុមខ្មែរប្រដាប់អាវុធទាំងអស់ ជាពិសេសពីក្រុមខ្មែរក្រហម ហើយដើម្បីជាការដោះដូរជាមួយការដកកងទ័ពវៀតណាមទាំងអស់ចេញពីកម្ពុជា ព្រះអង្គសុំឲ្យមានកងកម្លាំងអន្តរជាតិរក្សាសន្តិភាព ឬ ជាអក្សរកាត់ហៅថា អាយ ភី ខេ អេហ្វ (IPKF: International Peace Keeping Forces) មកប្រតិបត្តិការធ្វើជាប៉ូលីស និង ការពារប្រជាពលរដ្ឋខ្មែរនៅកម្ពុជាក្នុងរយៈពេលយ៉ាងតិច ៥ ឆ្នាំ ។ គោលជំហររបស់ព្រះអង្គនេះ ធ្វើឲ្យប្រទេសចិនមិនសប្បាយចិត្ត ហើយចិនក៏ចាប់ផ្តើមលើកសរសើរក្រុមលោកតា សឺន សាន ដែលព្រះអង្គរាប់បញ្ចូលក្នុងចង្កោមខ្មែរខៀវ ឬ ខ្មែរសេរីដោយរាប់ទាំងពួក លន់ នល់ ផង[123] ។

នៅសម័យនោះ ប្រទេសចិនមានគោលជំហរប្រឆាំងវៀតណាមយ៉ាងដាច់ខាត ពង្រឹងកងទ័ពខ្មែរក្រហមឲ្យរឹងមាំតាមការផ្តល់ជំនួយយោធា និង ប្រឆាំងរាល់ការប៉ុនប៉ងណាមួយក្នុងការដកអាវុធពួកនេះ ។ ចំណែកឯខាងការទូត ចិនត្រូវរកវិធីការពារកៅអីកម្ពុជាប្រជាធិបតេយ្យនៅអង្គការសហប្រជាជាតិ កុំឲ្យធ្លាក់ទៅរដ្ឋាភិបាលភ្នំពេញ ។ ដូច្នេះចិនត្រូវជួយរៀបចំមុខមាត់ថ្មីឲ្យរដ្ឋាភិបាលខ្មែរក្រហមមានលក្ខណៈសមរម្យស្អាតបាត ដែលអន្តរជាតិអាចទទួលយកបាន ដោយរកវិធីទាញយកមេដឹកនាំខ្មែរមិនមែនកុម្មុយនីស្តដូចជាលោកតា សឺន សាន ជាដើមឲ្យមកចូល

[123] Norodom Sihanouk, A Sad Deterioration of My Relationship with the People's Republic of China, the Cup to the Dregs, a handwritten manuscrit published on www.norodomsihanouk.info p.6.

រួមជាមួយពួកខ្មែរក្រហម ។ នៅពេលដែលសម្តេច សីហនុ ធ្វើឲ្យចិនមិនសប្បាយចិត្ត ដោយសារគោលជំហររបស់ព្រះអង្គមិនដាច់ខាត ក្នុងការប្រឆាំងវៀតណាម ព្រមទាំងចង់ឲ្យមានការដកអាវុធពីពួកខ្មែរក្រហមផងនោះ ចិនដោយមានកិច្ចសហការពីប្រទេសអាស៊ាន ជាពិសេសថៃ និង សិង្ហបុរីផង ក៏លើកលោកតា សឺន សាន ឲ្យលេចធ្លោឡើងថា ជាមេដឹកនាំខ្មែរមិនមែនកុម្មុយនីស្តតែមួយគត់ដែលគួរជាទីទុកចិត្ត និង ជាទីសង្ឃឹមរបស់ចលនាតស៊ូប្រឆាំងវៀតណាម ។ នៅពេលនោះ លោកតា សឺន សាន ក៏នឹកថា ចិន និង អាស៊ាន លែងត្រូវការសម្តេច សីហនុ ទៀតហើយ ៗក៏ដើរតួនាទីដឹកនាំផ្តាច់មុខតែម្នាក់ឯងតែម្តង ។ មិនតែប៉ុណ្ណោះកូនចៅលោកតាក៏ធ្វើយុទ្ធនាការវាយប្រហារសម្តេច តាមពាក្យសំដី ដែលធ្វើឲ្យព្រះអង្គខ្វាល់ជាខ្លាំង ។

សម្តេចសរសេរក្នុងសៀវភៅរបស់អង្គថា៖ "ក្នុងឆ្នាំ ១៩៧៩-១៩៨០ លោក សឺន សាន វាយប្រហារខ្ញុំតាមពាក្យសំដី និង ចោទប្រកាន់នៅចំពោះមុខសារព័ត៌មានអន្តរជាតិ និង ជនភៀសខ្លួនខ្មែរថា ខ្ញុំសម្ងំនៅស្ងៀមឈរនៅមាត់ច្រាំងយករួចខ្លួន នៅពេលដែលនាវាកម្ពុជាកំពុងលិចលង់" ។ លោក សឺន សាន អះអាងថាខ្លួនគាត់ៗមិនញញើតនិងលោតចូលក្នុងទន្លេ ជាមួយអ្នកដើរតាមគាត់ដែលគាត់ហៅថាប្រជាពលរដ្ឋខ្មែរ ដើម្បីជួយយកអាសាកម្ពុជា[124] ។ នៅពេលដែលលោកតា សឺន សាន កំពុងបញ្ចេញមុខមាត់លើឆាកអន្តរជាតិជាមេដឹកនាំខ្មែរមិនមែនកុម្មុយនីស្តតែមួយគត់ ដែលបានទទួលការគាំទ្រពីប្រទេសចិន និង ក្រុមអាស៊ានឲ្យត្រៀមដឹកនាំរដ្ឋាភិបាលថ្មីរបស់កម្ពុជាប្រជាធិបតេយ្យ សម្តេច សីហនុ ក៏យល់ថាគេកំពុងផាត់ព្រះអង្គពីឆាកនយោបាយ ។ ព្រះអង្គក៏សំដែងមតិជាសាធារណៈថា បើយកលោក សឺន សាន មកឲ្យដើរតួសំខាន់ជំនួសព្រះអង្គ អ្នកដែលបានចំណេញគឺវៀតណាម

[124] Norodom Sihanouk, Following the Historical Inter-Cambodian Summit of Singapore, Sihanouk's Enemies Lay into Him Tooth and Nail, The Cup to the Dregs, op. cit, p.4.

ព្រោះថា ប្រសិនបើគេឲ្យប្រជាពលរដ្ឋខ្មែរជ្រើសរើសរវាង សឺន សាន និង របប ហេង សំរិន គេនឹងរើសយករបប ហេង សំរិន តែបើឲ្យជ្រើសរើសរវាង សីហនុ និង របប ហេង សំរិន គេនឹងរើសយក សីហនុ ដោយគ្មានបង្អែបង្អង់ឡើយ ។ សម្តេចផ្សព្វផ្សាយថាតាមព័ត៌មាន ដែលព្រះអង្គបានទទួលតាមរយៈអ្នកកាសែតលោកខាងលិច ប្រជារាស្ត្រខ្មែរភាគច្រើននៅក្នុងប្រទេសនៅតែមានភក្តីភាពចំពោះព្រះអង្គជានិច្ច ទោះជាមានការឃោសនាបន្ទុះបង្អាប់ ឬ បន្ទាបបន្ថោកបំផ្លាញព្រះកិត្តិនាមព្រះអង្គជាច្រើនឆ្នាំដោយពួកបច្ចាមិត្រយ៉ាងណាក៏ដោយ[125] ។

តាមពិត ប្រទេសចិនមិនបានបោះបង់សម្តេច សីហនុ ទេ គេគ្រាន់តែលើកដំកើងលោកតា សឺន សាន មួយរយៈដើម្បីបង្កប្រតិកម្មឲ្យព្រះអង្គស្ទុះចូលមកសហការជាមួយខ្មែរក្រហមវិញតែប៉ុណ្ណោះ ។ នៅខែ វិច្ឆិកា ១៩៨០ នៅក្នុងជំនួបរវាងមេដឹកនាំចិន តេង ស៊ាវពីង ជាមួយលោកនាយករដ្ឋមន្ត្រី លី ខ្វាន់ យូ នៃប្រទេសសិង្ហបូរី មេដឹកនាំទាំងពីរបានពិភាក្សា និង ឯកភាពគ្នាលើគោលការណ៍នៃការបង្កើតរដ្ឋាភិបាលថ្មីមួយនៃកម្ពុជាប្រជាធិបតេយ្យ ។ គោលការណ៍នោះមាន ៣ ចំណុចគឺ៖ ១. គ្រប់ការប្រឹងប្រែងទាំងឡាយត្រូវធ្វើឡើង ដើម្បីឲ្យមានសម្ព័ន្ធភាពនៃកម្លាំងតស៊ូនានា ឆ្ពោះទៅបង្កើតរដ្ឋាភិបាលនៃរណសិរ្សរួបរួមមួយ ដឹកនាំដោយសម្តេច សីហនុ ឬ លោក សឺន សាន ។ រដ្ឋាភិបាលនេះត្រូវតែរាប់បញ្ចូលទាំងកងកម្លាំងនៃគណបក្សកុម្មុយនីស្តផង (ពួក ប៉ុល ពត) ។ ការប្រើឈ្មោះកម្ពុជាប្រជាធិបតេយ្យ ឬ មិនប្រើឈ្មោះកម្ពុជាប្រជាធិបតេយ្យ អាចលើកយកមកសិក្សាតទៅទៀត ។ អ្នកតំណាងកម្ពុជាប្រជាធិបតេយ្យចូលរួមក្នុងរដ្ឋាភិបាលចម្រុះត្រូវតែទទួលបាននូវការយល់ព្រមពីភាគីនានា ក៏ប៉ុន្តែបេក្ខជនត្រូវតែសម្រេចជ្រើសរើសឡើង

[125] Norodom Sihanouk, To Eliminate Me to Son Sann's Advantage Would Only Help the Viets..., Editorial - BMD November – December 1981, handwritten manuscript, published on www.norodomsihanouk.info. May 14, 2004.

ដោយភាគីកម្ពុជាប្រជាធិបតេយ្យខ្លួនឯង ។ គ្មាននរណាអាចបង្គាប់បញ្ជាភាគីនេះបានឡើយ- ២. អាស៊ាន ស.រ.អា និង ប្រទេសឯទៀតអាចប្រឹងប្រែងរួមគ្នាដើម្បីបង្កើតឲ្យមានកងទ័ពមិនមែនកុម្មុយនីស្តមួយនៅកម្ពុជា ។ ក៏ប៉ុន្តែលក្ខខណ្ឌជាមុននោះ តម្រូវឲ្យកងទ័ពនេះ ប្រកាន់គោលជំហរដាច់ខាតប្រឆាំងវៀតណាម និង របបហេង សំរិន ក្នុងការប្រយុទ្ធដើម្បីថែរក្សាឯករាជ្យជាតិ និង ដើម្បីរំដោះជាតិ ព្រមទាំងតម្រូវឲ្យកងទ័ពនេះ ជៀសវាងកុំសមគំនិតជាមួយវៀតណាម និង របបអាយ៉ងហេង សំរិន ដើម្បីប្រឆាំងបក្សកុម្មុយនីស្តកម្ពុជា (ខ្មែរក្រហម) ។ កងទ័ពមិនមែនកុម្មុយនីស្តនេះ អាចស្ថិតនៅក្រោមបញ្ជាសម្តេច សីហនុ ឬ លោក សឺន សាន ។ គ្រប់បញ្ហារាប់ទាំងបញ្ហាបុគ្គលិក ឬ យុទ្ធជនផង កងទ័ពនេះត្រូវដោះស្រាយដោយខ្លួនឯង ។ យ៉ាងណាក៏ដោយមិនត្រូវធ្វើអ្វីទាំងអស់ដែលធ្វើឲ្យទន់ខ្សោយដល់កម្លាំងតស៊ូទាំងអស់ដែលកំពុងកើតមាននៅពេលបច្ចុប្បន្ន- ៣. ប្រទេសចិនបានប្រកាសយ៉ាងច្បាស់លាស់រួចថា បន្ទាប់ពីកងទ័ពវៀតណាមដកចេញពី កម្ពុជាអស់ហើយ ទាំងប្រព័ន្ធនយោបាយ ទាំងឈ្មោះប្រទេស ទាំងថ្នាក់ដឹកនាំនៃកម្ពុជា នឹងត្រូវសម្រេចដោយប្រជាជនកម្ពុជាខ្លួនឯង តាមរយៈការបោះឆ្នោតមួយ ដោយសេរី និងតាមបែបប្រជាធិបតេយ្យក្រោមការត្រួតពិនិត្យរបស់អន្តរជាតិ ។ ប្រទេសចិនគ្មានបំណងបង្កើតរដ្ឋជារណបរបស់ខ្លួនណាមួយ នៅទីណាមួយក្នុងពិភពលោកនោះឡើយ ។ គោលការណ៍បីចំណុចនេះ បញ្ជាក់យ៉ាងច្បាស់ថា ចិន និង សិង្ហបូរីបានព្រមព្រៀងគ្នារួចហើយ ដើម្បីរៀបចំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យថ្មីដឹកនាំដោយឥស្សរជនមិនមែនកុម្មុយនីស្ត ក្នុងលក្ខខណ្ឌដែលមិនឲ្យខូចខាតទាល់តែសោះដល់កម្លាំងខ្មែរក្រហម ទាំងកម្លាំងនយោបាយ ទាំងកម្លាំងទ័ព ។ ភាគីទាំងពីរបានទុកលទ្ធភាពឲ្យអាស៊ាន ស.រ.អា និង ប្រទេសលោកខាងលិចជួយបង្កើតកងទ័ពខ្មែរមួយទៀត ដែលជាកងទ័ពមិនមែនកុម្មុយនីស្ត ក៏ប៉ុន្តែកងទ័ពនេះ មិនត្រូវ

ប្រឆាំងកងកម្លាំងរបស់ខ្មែរក្រហមជាដាច់ខាត ។ ជាការច្បាស់ណាស់ គោលនយោបាយចិន មិនត្រឹមតែការពារខ្មែរក្រហមកុំឲ្យរលំរលាយប៉ុណ្ណោះទេ តែថែមទាំងនាំមេដឹកនាំខ្មែរមិនមែនកុម្មុយនីស្ត មកជួយពង្រឹងខ្មែរក្រហមទៀតផង ។ ចំណុចជាយុទ្ធវិធីនោះគឺ គេមិនបានកំណត់ឲ្យច្បាស់ថាតើតួអង្គមួយណា សម្តេច សីហនុ ឬ លោកតា សឺន សាន ដែលត្រូវដឹកនាំរដ្ឋាភិបាលថ្មី និង បញ្ជាកងទ័ពមិនមែនកុម្មុយនីស្ត? យុទ្ធវិធីនេះធ្វើឲ្យមេដឹកនាំទាំងពីររូបប្រណាំងប្រជែងគ្នា ដើម្បីដណ្តើមតួនាទីដឹកនាំ ព្រោះថាមេដឹកនាំណា ដែលមានភាពទន់ភ្លន់ជាងគេ មេដឹកនាំនោះនឹងមានឧត្តមភាព ។ លើសពីនេះទៅទៀត ថ្នាក់ដឹកនាំចិននៅតែព្យាយាមអូសទាញសម្តេច សីហនុ ឲ្យយាងចូលមកសហការជាមួយខ្មែរក្រហមវិញ ទោះបីជាជួនកាល ពួកគេមិនពេញចិត្តចំពោះគោលជំហរនយោបាយខ្លះៗរបស់ព្រះអង្គយ៉ាងណាក៏ដោយ ។

សម្តេច សីហនុ បានពន្យល់អំពីមូលហេតុ ដែលនាំព្រះអង្គឲ្យសុខចិត្តវិលមកសហការជាមួយខ្មែរក្រហមនោះថា មួយគឺដើម្បីបានជំនួយមកជួយកងទ័ពសីហនុនិយម និង មួយទៀតគឺ ព្រះអង្គមិនអាចបោះបង់ចោលមហាមិត្តចិន ដែលបានជួយគាំទ្រព្រះអង្គយ៉ាងខ្លាំងក្លាក្នុងឆ្នាំ ១៩៧០-១៩៧៥ ក្នុងសង្គ្រាមប្រឆាំងពួក លន់ នល់ ។ ព្រះអង្គបានរំលឹកថា ស្ត្រីកំពូលចិន ដែលព្រះអង្គគោរពយ៉ាងខ្លាំងគឺ លោកជំទាវភរិយាសពនាយករដ្ឋមន្ត្រី ជូ អេនឡាយ តែងទូលព្រះអង្គឲ្យបំភ្លេចទុក្ខសោករបស់ព្រះអង្គ ដែលកើតឡើងដោយសារការបាត់បង់កូនចៅជាទីស្រឡាញ់របស់ព្រះអង្គ ដើម្បីអាចប្រមូលឋាមពលមកធ្វើការរំដោះប្រទេសជាតិ ព្រោះព្រះអង្គ ប្រាកដជាទ្រង់ជ្រាបថាតើឧត្តមប្រយោជន៍របស់ប្រទេសជាតិនៅទីណា[126]។ ចិនក៏ប្រាកដជាបានទូលសម្តេចឲ្យទ្រង់ជ្រាបអំពីខ្លឹមសារនៃជំនួប តែង

[126] Norodom Sihanouk, The Leading Role of People's Republic of China and Asean in the Process of Building Up Democratic Kampuchea's CGDK, The Cup to the Dregs, op. cit, p.12.

ស៊ារពីង - លី ខ្វាន់ យូ ជាពិសេសចំណុចទាំង៣នៃគោលការណ៍ខាងលើ ។ ដូច្នេះនៅពេលសម្តេច សីហនុ សម្រេចព្រះទ័យយាងចូលមកសហការជាមួយខ្មែរក្រហមវិញ ព្រះអង្គយល់ច្បាស់ណាស់នូវអ្វីដែលព្រអង្គអាចធ្វើបាន ។

## លោកតាមិនអាចបង្រួបបង្រួមអ្នកជាតិនិយម

អស់រយៈពេលជាយូរមកហើយ ដែលថ្នាក់ដឹកនាំ រ.ជ.រ.ប.ខ. បានយល់ដឹងអំពីផលវិបាកនៃគោលការណ៍ត្រីភាគីនិយមនេះ ហើយបានព្យាយាមជៀសវាងគេចចេញ ។ មេដឹកនាំ រ.ជ.រ.ប.ខ. បានព្យាយាមបង្រួបបង្រួមយុទ្ធជនអ្នកជាតិនិយមមិនមែនកុម្មុយនីស្តឲ្យរួបរួមគ្នាប្រយុទ្ធក្រោមទង់តែមួយរបស់រ.ជ.រ.ប.ខ.។ មែនទែនទៅ ស្ទើរតែទាំងអស់នៃចលនាប្រដាប់អាវុធនៅលើសមរភូមិ បានមកសំដែងភក្តីភាពចំពោះ រ.ជ.រ.ប.ខ. និង បានចូលរួមក្នុងសមាជជាតិរ.ជ.រ.ប.ខ. ដែលប្រព្រឹត្តិទៅក្រោមអធិបតីភាពលោកតា សឺន សាន ក្នុងទឹកដីខ្មែរពីថ្ងៃទី ២៤-២៥ មេសា ១៩៨០ រួចទៅហើយ ។ ក៏ប៉ុន្តែ នៅមានចលនាមួយចំនួន នៅរក្សាឯករាជភាពរបស់ខ្លួន ឬ សំដែងភាពទោរទន់ទៅរកសម្តេច សីហនុ ។ ចលនាទាំងនោះមានចលនាមូលីណាកាដឹកនាំដោយ លោក គង់ ស៊ីលាស់ ក្រោយមកបន្ទាប់ពីលោក គង់ ស៊ីលាស់ ចូលមរណភាពយ៉ាងចម្លែកនាខែ សីហា ១៩៨០ បានត្រូវដឹកនាំដោយលោក ញ៉ែម សុផុន និង ចលនាឈ្មោះរណសិរ្សខ្មែរអង្គររបស់លោក អ៊ិន សាខន ។

នៅខែ មករា ១៩៨១ លោកតា សឺន សាន បានមកជួបជាមួយលោក ញ៉ែម សាផុន ចំនួនពីរដងនៅក្នុងជំរុំនងចាន់ ដោយសង្ឃឹមថាអ្នកដឹកនាំមូលីណាកានឹងចូលរួមជាមួយរ.ជ.រ.ប.ខ. ។ ក៏ប៉ុន្តែ នៅទីបំផុត ការខំប្រឹងប្រែងរបស់លោកតាប្រធានរ.ជ.រ.ប.ខ.ក៏ក្លាយជាអាសាឥតការ ព្រោះលោក ញ៉ែម សុផុន បាន

នាំចលនារបស់គាត់ទៅចូលជាមួយសម្តេច សីហនុ ។ មូលីណាកាក៏បានក្លាយជាធ្នឹងខ្នងដ៏រឹងមាំនៃកងទ័ពសីហនុនិយម ។ ដោយមានការគាំទ្រផ្នែកយោធានេះ សម្តេច សីហនុ ក៏បានបង្កើតចលនាផ្ទាល់របស់ព្រះអង្គ ដែលមានឈ្មោះថា ហ្វ៊ុន ស៊ិន ប៉ិច (FUNCINPEC) (រណសិរ្សរួបរួមជាតិដើម្បីកម្ពុជា ឯករាជ្យ អព្យាក្រឹត្យ សន្តិ និង សហប្រតិបត្តិការ) ជាអក្សរកាត់ចេញពីភាសាបារាំង ។ ហ្វ៊ុន ស៊ិន ប៉ិច បានត្រូវប្រកាសបង្កើតនៅទីក្រុងព្យុងយ៉ាងកូរ៉េខាងជើង ក្នុងខែ មីនា ១៩៨១ ។ ចូលរួមក្នុងរណសិរ្សនេះមានចលនា ៣ គឺ៖ មូលីណាកា ឧត្តរទិស និង ឃ្លាំងមឿង[127] ។ គួរចាប់អារម្មណ៏ថាចលនាឃ្លាំងមឿងមានទាំងនៅក្នុង ហ្វ៊ុន ស៊ិន ប៉ិច មានទាំងនៅក្នុង រ.ជ.រ.ប.ខ. ។ ម្យ៉ាងទៀត អ្នកតស៊ូចាស់ៗដូចជា៖ តាម៉ុាំង តាលួត លោក ទូន ចាយ លោក ជា ឈុត ជាដើម សុទ្ធតែជាយុទ្ធមិត្តស្លាប់រស់ជាមួយគ្នា ទោះបីជាពួកគេស្ថិតនៅក្នុងរណសិរ្សទីទៃៗពីគ្នាក៏ដោយ ។ ហេតុដូច្នេះហើយ ទើបលោកឧត្តមសេនីយ ដៀន ដែល បានផ្តាំផ្ញើឲ្យលោកតា សឺន សាន ពិនិត្យឲ្យបានហ្មត់ចត់ថា តើអ្នកណាខ្លះដែលស្មោះស្ម័គ្រច្បាស់លាស់ជាមួយ រ.ជ.រ.ប.ខ. មុននឹងផ្តល់អាវុធឲ្យនៅពេលដែលលោកឧត្តមសេនីយរូបនេះ បង្ខំចិត្តលាតំណែងជានាយអគ្គសេនាធិការ ក.ជ.រ.ប.ខ. បន្ទាប់ពីមានឃាតកម្មលើតាលួត នៅថ្ងៃទី ១១ ខែ តុលា ១៩៨២ ។

គួរកត់សំគាល់ថា ការខំប្រឹងប្រែងបង្រួបបង្រួមប្រមែប្រមូលយុទ្ធជនអ្នកជាតិនិយមមិនមែនកុម្មុយនីស្តរបស់មេដឹកនាំរ.ជ.រ.ប.ខ. ហាក់ដូចជាបានទទួលការលើកទឹកចិត្តពីបណ្តាប្រទេសអាស៊ាន ។ នៅពេលមកដល់ទីក្រុងបាងកក នៅថ្ងៃទី ១ មករា ១៩៨១ លោក រ៉ាឆារ៉ាតណាម (Rajaratnam) ឧបនាយករដ្ឋមន្ត្រីនៃប្រទេសសិង្ហបូរី បានប្រកាសជាសាធារណៈថារដ្ឋាភិបាលសិង្ហបូរីអបអរសាទរគំនិត

---

127 Norodom Sihanouk, The Birth of Funcinpec-The First Summit of the Three Khmer Anti-Vietnamese Colonialist Leaders and the “Dragon Lady”, the Cup to the Dregs, op. cit, p.9

ដែលឲ្យលោកតា សឺន សាន ជាអ្នកដឹកនាំចលនាតស៊ូប្រឆាំងនឹងការកាន់កាប់ប្រទេសកម្ពុជាដោយកងកម្លាំងបរទេស ។ ជាមួយគ្នានេះដែរ លោក កាឡូស្សរ៉ូមុឡូស (Calos Romulos) រដ្ឋមន្ត្រីក្រសួងការបរទេសហ្វីលីពីន ក៏បានបញ្ជាក់ជូនលោករដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន អ៊ីតូ (Ito) ថាក្រុមប្រទេសអាស៊ាន អាចនឹងទទួលស្គាល់លោកតា សឺន សាន ។ តាមពិតទៅ ដូចមានចែងរួចហើយខាងលើថា ចិន និង អាស៊ាន តាមរយៈជំនួប តេង ស៊ាវពីង-លី ខ្វាន់ យូ កាលពីខែ វិច្ឆិកា ១៩៨០ កន្លងទៅ បានព្រមព្រៀងគ្នាឲ្យសម្តេច សីហនុ ឬ លោកតា សឺន សាន ជាអ្នកដឹកនាំរដ្ឋាភិបាលថ្មីនៃកម្ពុជាប្រជាធិបតេយ្យ មិនមែនឲ្យលោកតា សឺន សាន តែម្នាក់ឯង ដោយបំភ្លេចចោលសម្តេច សីហនុ នោះទេ ។

ដោយសារការអះអាងមិនអស់សេចក្តីរបស់លោកឧបនាយករដ្ឋមន្ត្រី រ៉ាធារ៉ាតណាម នៃប្រទេសសិង្ហបូរី និង លោក កាឡូស្សរ៉ូមុឡូស រដ្ឋមន្ត្រីក្រសួងការបរទេសហ្វីលីពីននេះហើយ ដែលធ្វើឲ្យលោកតា សឺន សាន យល់ច្រឡំនឹកស្មានថាសម្តេច សីហនុ បាត់ការគាំទ្រពីចិន និង អាស៊ាន អស់ទៅហើយ ។ ដូច្នេះលោកតាក៏ចេះតែបន្តដើរតួឯកតែម្នាក់ឯង លើឆាកអន្តរជាតិ ដែលធ្វើឲ្យសម្តេច សីហនុ រឹតតែអាក់អន់ព្រះទ័យថែមទៀតចំពោះ រ.ជ.រ.ប.ខ. និង អ្នកដឹកនាំនៃចលនាតស៊ូនេះ ។

## លោកតាថ្លែងថា ដើម្បីបត់ស្តាំ ត្រូវសៀរឆ្វេងបន្តិច

នៅខែ មេសា និង ឧសភា ១៩៨១ លោកតា សឺន សាន ធ្វើដំណើរទៅសហរដ្ឋអាមេរិក បន្ទាប់មកលោកតាធ្វើដំណើរទៅពិគ្រោះយោបល់ជាមួយសហគមន៍ខ្មែរអ្នកគាំទ្ររ.ជ.រ.ប.ខ. លើបញ្ហាចូលរួមក្នុងរដ្ឋាភិបាលចម្រុះ ដើម្បីការពារអា

សនៈកម្ពុជានៅអង្គការសហប្រជាជាតិ ។ នៅក្នុងសន្និបាតមួយរបស់ រ.ជ.រ.ប.ខ. ក្នុងក្រុងអាលីងតុន (Arlington) សហរដ្ឋអាមេរិក លោកតាប្រធានថ្លែងថាៈ "ប្រជារាស្ត្រខ្មែរមានការភ័យខ្លាចខ្មែរក្រហម ។ នៅពេលដែលគេដឹងថាសម្ដេចសីហនុ សំរេចថាចូលរួមជាមួយខ្មែរក្រហម ពួកគេមានក្ដីបារម្ភចំពោះសេចក្ដីសំរេចរបស់សម្ដេចណាស់ ដូច្នេះមានប្រជារាស្ត្រមួយចំនួន ក៏នាំគ្នាទៅគាំទ្រកងទ័ពវៀតណាមទៅវិញ[128]។ ចំណែកពួកខ្មែរក្រហម គេមិនត្រូវអនុញ្ញាតឲ្យពួកនេះវិលត្រឡប់មកកាន់អំណាចវិញឡើយ" ។ បន្ថែមលើនេះ លោកតាប្រធានបានបង្ហើបជាសាធារណៈលើកដំបូងឲ្យដឹងថាមានប្រទេសមួយចំនួន បានឲ្យរ.ជ.រ.ប.ខ.ចាត់វិធានការដើម្បីទៅដណ្ដើមយកអាសនៈកម្ពុជានៅអង្គការសហប្រជាជាតិ ។ លោកតា សឺន សាន បានជំរាបអង្គសន្និបាតថាមានរដ្ឋាភិបាលនៃប្រទេសជាមិត្តមួយចំនួនបានស្នើឲ្យរ.ជ.រ.ប.ខ.បង្កើតរដ្ឋាភិបាលថ្មី ដោយមានការចូលរួមខ្លះពីពួកខ្មែរក្រហមគឺ រដ្ឋាភិបាលថ្មីដែលមានលោកតា សឺន សាន ជាប្រមុខ ។ លោកតាបានថ្លែងថាឆ្លើយទៅសំណើរបស់ខ្មែរក្រហម ដែលស្នើឲ្យលោកតាចូលរួមក្នុងរដ្ឋាភិបាលខ្មែរក្រហមថ្មីនោះ លោកតាទាមទារឲ្យខ្មែរក្រហមប្រគល់ក្រសួងទាំងអស់ឲ្យមកលោកតា បើមិនដូច្នេះទេ សូមឲ្យពួកខ្មែរក្រហមយកក្រសួងទាំងអស់នោះសំរាប់ខ្មែរក្រហមខ្លួនឯងចុះ ។ លោកតាបានជំរាបអង្គសន្និបាតថា គាត់ធ្វើដំណើរមកដល់ផ្លូវបត់ហើយ ។ លោកតានឹងធ្វើការបត់បែនគឺ ផ្លាស់ប្ដូរពីមិនចូលរួមជាមួយខ្មែរក្រហម មកត្រឹមចូលរួមដោយមានលក្ខខណ្ឌជាមួយខ្មែរក្រហមវិញ ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ លោកតាធានាថា រ.ជ.រ.ប.ខ. នឹងមិនបត់ឆ្វេងជាដាច់ខាតគឺ រ.ជ.រ.ប.ខ.នឹងបត់ទៅស្ដាំយ៉ាងពិតប្រាកដ ។ លោកតាប្រធានមានប្រសាសន៍ថា "ដើម្បីបត់ស្ដាំឲ្យបាន

---

[128] សឺន សាន, ប្រសាសន៍ថ្លែងក្នុងឱកាសមហាសន្និបាតនៃប្រជាពលរដ្ឋនៅសហរដ្ឋអាមេរិក, រ ជ រ ប ខ ខែកក្កដា ១៩៨១ ទំព័រ ៣-៩ ។

ស្រួល កុំឲ្យក្រឡាប់ ត្រូវតែបត់ស្ដាំដោយសៀរឆ្វេងបន្តិច" ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គោលបំណងរបស់លោកតាគឺធ្វើយ៉ាងណាដើម្បីពង្រឹងរ.ជ.រ.ប.ខ.។ ការបង្កើតរដ្ឋាភិបាលចម្រុះជាមួយខ្មែរក្រហម គ្រាន់តែជាវិធីដើម្បីរក្សាកៅអីរបស់កម្ពុជានៅអង្គការសហប្រជាជាតិ និង ដើម្បីពង្រឹងកម្លាំងរបស់ រ.ជ.រ.ប.ខ. តែប៉ុណ្ណោះ ។

# ចូលទ្រុងខ្លា លោកតាសុំដំបងមួយ

បន្ទាប់ពីទស្សនកិច្ចនៅសហរដ្ឋអាមេរិក លោកតា សឺន សាន បានវិលត្រឡប់ទៅប្រទេសបារាំងវិញ ។ បន្ថែមលើទស្សនកិច្ច នៅប្រទេសអាឡឺម៉ង់នាខែឧសភា លោកតាប្រធានបានធ្វើទស្សនកិច្ចនៅប្រទេស ហុល្លង់នៅថ្ងៃទី ១៦ មិថុនា ដែលនៅទីនោះ លោកតាបានជួបជាមួយលោកប្រធាននាយកដ្ឋានកិច្ចការអាស៊ី និង អូសេអានីនៃក្រសួងការបរទេស ។ លោកតា សឺន សានបានជំរាបគូសន្ទនានូវលក្ខខណ្ឌរបស់លោកតាក្នុងការចូលរួមដឹកនាំរដ្ឋាភិបាល "កម្ពុជាប្រជាធិបតេយ្យ" ថ្មីមួយដើម្បីការពារកៅអីកម្ពុជាប្រជាធិបតេយ្យនេះ នៅអង្គការសហប្រជាជាតិ[129] ។ លក្ខខណ្ឌនោះមានជាអាទិ៖ -ក្រសួងចំនួនភាគច្រើនដាច់ខាតត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវនៃក្រុមអ្នកជាតិនិយម (គឺពួកអ្នកមិនមែនកុម្មុយនីស្ត)-មេដឹកនាំដ៏ល្បីឈ្មោះរបស់ខ្មែរក្រហម មិនត្រូវអនុញ្ញាតឲ្យចូលក្នុងរដ្ឋាភិបាលចម្រុះនេះឡើយ (ឧទាហរណ៍៖ ប៉ុល ពត នួន ជា តាម៉ុក អៀង សារី ជាដើម) - ចំណុចចុងក្រោយ - រ.ជ.រ.ប.ខ.ត្រូវតែមានកម្លាំងមាំទាំគ្រប់គ្រាន់ ។ ចំពោះចំណុចចុងក្រោយនេះ លោកតាប្រធានរ.ជ.រ.ប.ខ.បានសុំថា៖ ឲ្យផ្ដល់ជំនួយមនុស្សធម៌ជា

---

[129] ទស្សនកិច្ចរបស់លោក សឺន សាន ប្រធាន រ.ជ.រ.ប.ខ. នៅប្រទេសប៉េអ៊ីបា កាលពីថ្ងៃទី១៦ មិថុនា ១៩៨១, ព្រឹត្តិបត្រ រ. ជ. រ. ប. ខ. ខែ កក្កដា ១៩៨១ ទំព័រ ១៨-១៩ ។

បន្ទាន់ដល់ប្រជារាស្ត្រស៊ីវិលចំនួន ១០០០០០ នាក់ ផ្តល់ជំនួយផ្នែកការទូត និង នយោបាយ ដើម្បីឲ្យរ.ជ.រ.ប.ខ.រឹតតែមានសកម្មភាពខ្លាំងក្លាឡើង ព្រមទាំងសុំជំនួយហិរញ្ញវត្ថុឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យរ.ជ.រ.ប.ខអាចបំពេញការងារដោយជោគជ័យ ។ ចំពោះលក្ខខណ្ឌទាំងនេះ លោកតា សឺន សាន មានប្រសាសន៍ថា៖ "បើអស់លោកឲ្យខ្ញុំចូលក្នុងទ្រុងខ្លា សូមប្រគល់ដំបងមកឲ្យខ្ញុំផង" ។ ជាការពិតណាស់ ព្រោះថាបើគ្មានដំបងទេ លោកតានឹងត្រូវ "ខ្លា" ខ្មែរក្រហម "ធី" ជាចំណីមិនខានឡើយ ។

## លោកតាប្រកាសថា ខ្ញុំស្ម័គ្រចិត្តចេញទៅតស៊ូ

នៅក្នុងការស្នាក់នៅទ្វីបអឺរ៉ុប លោកតា សឺន សាន បានសម្លឹងរកអ្នកមានសមត្ថភាព ដើម្បីរើសយកទៅធ្វើការជាសហការីផ្ទាល់របស់លោកតា ក្នុងវិស័យសំខាន់ៗដូចជា៖ ការទូត ហិរញ្ញវត្ថុ និង យោធា ដើម្បីត្រៀមខ្លួនជួយធ្វើការនៅពេល ដែលលោកតាអាចនឹងទទួលតំណែងជាន់ខ្ពស់ក្នុងរដ្ឋាភិបាលថ្មី ដែលនឹងត្រូវបង្កើតឡើង នាពេលខាងមុខ ។ ថ្មីៗមុននេះ លោកតាប្រធានទើបតែបានទទួលការគាំទ្រ ដ៏វិសេសពីសម្តេច ប៉ែន នុត ដែលជាកល្យាណមិត្តដ៏ច្បាស់លាស់ជាយូរមកហើយរបស់លោកតា ។ សម្តេច ប៉ែន នុត បានបញ្ជូនកូនប្រុសទាំងបួនរូបរបស់សម្តេចឲ្យមកបំរើ រ.ជ.រ.ប.ខ. ។ បុត្ររបស់សម្តេច ប៉ែន នុត ទាំងបួននាក់នោះគឺ៖ លោក ប៉ែន ថុល លោក ប៉ែន ថាល់ លោក ប៉ែន ញ៉ាច និង លោក ប៉ែន ធុឡា ។ បុត្រទាំងបួននាក់នោះ បានទៅរស់នៅផ្សេងៗពីគ្នាបន្ទាប់ពីបានរួចចេញពីរបប ប៉ុល ពត មក ដោយលោក ប៉ែន ថុល នៅប្រទេសជប៉ុន លោក ប៉ែន ញ៉ាច និង លោក ប៉ែន ធុឡា ទៅនៅប្រទេសកាណាដា ឯលោក ប៉ែន ថាល់ នៅប្រទេសបារាំង ។ លោក ប៉ែន ថាល់ ដែលប្រហែលជាកូនសំណព្វចិត្តរបស់សម្តេច ប៉ែន នុត បាន

ស្ម័គ្រចិត្តចូលបំរើ រ.ជ.រ.ប.ខ. នៅសមរភូមិមុខនាពេលខាងមុខ ។ ចាប់ពីបានស្ម័គ្រចិត្តមក គាត់ចាប់ផ្តើមបង្ហាញមុខបណ្តើរៗនៅពេលមានអង្គប្រជុំខ្លះរបស់ រ.ជ.រ.ប.ខ. នៅទីក្រុងប៉ារីស មុននឹងចេញដំណើរជាស្ថាពរទៅសមរភូមិមុខ ។

ក្នុងចំណោមសហសេវិករបស់ខ្ញុំទាំងឡាយ នៅប្រទេសបារាំង លោកតា សឺន សាន បានសម្លឹងយកលោក សាយ បូរាណ ជាជំនួយការរបស់លោកតា ។ លោក សាយ បូរាណ កាលនោះអាយុប្រហែលជា ៤០ ឆ្នាំ នៅលីវ មានចំណេះចេះដឹងជ្រៅជ្រះ និង ជាមនុស្សមានការអត់ធ្មត់ក្នុងការងារ ។ លោក សាយ បូរាណ ធ្លាប់ធ្វើការទាំងយប់អធ្រាត ដើម្បីបោះពុម្ពផ្សាយព្រឹត្តិប័ត្រ រ.ជ.រ.ប.ខ. ។ ជួនកាលគាត់មិនទាំងវិលទៅផ្ទះវិញផង នៅពេលជាប់ដៃក្នុងការងារ ។ គាត់សម្រាកក្នុងការិយាល័យរ.ជ.រ.ប.ខ. នៅប៉ារីសតែម្តង ។ នៅពេលដែលលោកតាប្រធានជ្រើសរើសរូបគាត់ឲ្យទៅបំរើការងារឯសមរភូមិមុខនោះ លោក សាយ បូរាណ មិនបានប្រកែក ឬ ឆ្លើយតបឲ្យច្បាស់លាស់ថា ពេលណាគាត់អាចឈប់ធ្វើការនៅឯប្រទេសបារាំង និង ទៅធ្វើការផ្ទាល់ជាមួយលោកតានោះទេ ។ តាមពិតលោក សាយ បូរាណ ជាមនុស្ស ដែលខ្ញុំមានការជិតស្និទ្ធជាងគេនៅទីក្រុងប៉ារីសនេះ ព្រោះស្ទើរតែរាល់ល្ងាចនៅពេលយើងបញ្ចប់ការងារក្រៅម៉ោងធ្វើការ នៅឯការិយាល័យរ.ជ.រ.ប.ខ.រួចហើយ យើងតែងនាំគ្នាទៅទទួលទានអាហាររួមគ្នា ជួនកាលនៅភោជនីយដ្ឋានរបស់លោក សុខ វ៉ាន់ធី ឬ ភោជនីយដ្ឋានចិនផ្សេងៗទៀត មិនសូវខានឡើយ ។ លោក សាយ បូរាណ បានដឹងច្បាស់ណាស់នូវមនោសញ្ចេតនាអ្នកជាតិនិយមរបស់ខ្ញុំ ។ ប្រហែលជាលោក សាយ បូរាណ ជំរាបរឿងខ្ញុំដល់លោកតា សឺន សាន ថាខ្ញុំស្ម័គ្រចិត្តបោះបង់ចោលការងារខ្ញុំឯស្រុកបារាំង ដើម្បីទៅបំរើ រ.ជ.រ.ប.ខ.ឯសមរភូមិមុខ បានជានៅក្នុងអង្គប្រជុំមួយនៃសមាជិក រ.ជ.រ.ប.ខ. លោកតា សឺន សាន បានប្រកាសជាសាធារណៈថា រូបខ្ញុំបានស្ម័គ្រចិត្តទៅធ្វើការជាមួយលោកតានៅឯសមរ

ភូមិមុខ ដែលធ្វើឲ្យខ្ញុំស្រឡាំងកាំង ព្រោះខ្ញុំមិនដែលនិយាយរឿងនេះផ្ទាល់ជាមួយលោកតាប្រធានម្តងណាឡើយ ។ ម្យ៉ាងទៀត ខ្ញុំក៏មិនដែលបាននិយាយអំពីបំណងរបស់ខ្ញុំ ក្នុងការវិលទៅមាតុប្រទេសវិញជាមួយកូនប្រសារលោកតាប្រធាន លោកបណ្ឌិត ឆាយ ហាន់ចេង ជាមុនផងទេ ។

ដោយសារលោកតាប្រកាសជាសាធារណៈ នៅចំពោះមុខសមាជិក រ.ជ.រ.ប.ខ. រាប់រយនាក់យ៉ាងនេះ ខ្ញុំក៏គ្មានសំដែងអ្វីក្រៅពីការយល់ព្រមដោយតុណ្ហីភាពតែប៉ុណ្ណោះ ។ មែនទែនទៅ ការចេញដំណើរទៅកាន់សមរភូមិមុខធ្វើជាយុទ្ធជនដើម្បីសេរីភាព ជាបំណងដែលខ្ញុំប៉ងប្រាថ្នាយូរមកហើយ ។ តាំងពីពេលនោះមក ការស្រមៃចង់វិលត្រឡប់មកកាន់មាតុភូមិខ្មែរវិញរបស់ខ្ញុំ ក៏ចាប់ផ្តើមលេចចេញជារូបរាងឡើងបន្តិចម្តងៗ ។ តាមគំរោង ខ្ញុំនឹងត្រូវចេញដំណើរពីទីក្រុងប៉ារីសទៅក្រុងបាងកក ដោយរួមដំណើរជាមួយលោក ប៉ែន ថាល់ ។ ក៏ប៉ុន្តែ ពួកយើងមិនទាន់ត្រូវចេញដំណើរភ្លាមទេ ពួកយើងត្រូវចេញទៅតាមខេត្ត ជួបប្រជុំជាមួយសមាជិកអ្នកគាំទ្ររបស់យើងក្នុងប្រទេសបារាំង ដើម្បីលាគ្នាអស់ជាច្រើនខែទៀតសិន ។

## ក្រុមកូម៉ិច បង្កើតបញ្ហាចំរូងចំរាស់ថ្មី

នៅចន្លោះពេលនេះ នៅតំបន់ដែលរ.ជ.រ.ប.ខ.កាន់កាប់ ក៏កើតមានបញ្ហាចំរូងចំរាស់ជាថ្មីទៀត ក្នុងពេលអវត្តមានរបស់លោកតា សឺន សាន ។ ដោយសារសមាជិកខ្លះនៃគណៈកម្មាធិការប្រតិបត្តិកូម៉ិច បានរើសសមាជិកថ្មីម្នាក់ទៀតមកពីប្រទេសបារាំងដែរ ឈ្មោះលោក ឱក សិរីសោភក្តិ ឲ្យចូលមកធ្វើការក្នុងរណសិរ្ស ។ លោក សោភក្តិ បានចេញពីប្រទេសបារាំង នៅថ្ងៃទី ២២ មេសា ១៩៨១ ហើយនៅថ្ងៃទី ១១ ឧសភា ១៩៨១ បានត្រូវអនុញ្ញាតឲ្យចូលតំបន់កណ្តាល ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់លោកឧត្តមសេនីយ ដៀន ដែល ។ សោភក្តិ និង

សមាជិកថ្មីមួយចំនួនទៀត ដែលទើបតែរត់ចេញមកពីតំបន់កាន់កាប់ដោយរដ្ឋាភិបាល ហេង សំរិន ឬ ដែលទើបចេញពីជំរុំជនភៀសខ្លួន បានត្រូវចាត់ឲ្យធ្វើពិធីសច្ចាប្រណិធានជាយុទ្ធជន រ.ជ.រ.ប.ខ. ក្រោមអធិបតីភាពលោកឧត្តមសេនីយ ដៀន ដែល និង លោក ហ៊ីង គន្ធុន នៅថ្ងៃទី ១០ មិថុនា ១៩៨១ ។ វត្តមានរបស់ សោភក្តិ នៅក្នុងសមរភូមិមុខ អាចជាសញ្ញាដ៏ល្អមួយដល់ជនភៀសខ្លួន ឬ មន្ត្រីរបស់ រ.ជ.រ.ប.ខ. ឲ្យដឹងថា រ.ជ.រ.ប.ខ. មានការគាំទ្រយ៉ាងខ្លាំងក្លាពីសហគមន៍ខ្មែរនៅបរទេស ដូច្នេះពួកគេមិនត្រូវរត់ទៅបរទេសទេ ។ រត់ទៅបរទេសធ្វើអ្វី បើមានយុវជនបញ្ញវ័ន្តនៅបរទេសនាំគ្នាចូលបំរើ រ.ជ.រ.ប.ខ. យ៉ាងនេះទៅហើយនោះ ។

ក៏ប៉ុន្តែ ករណីរបស់ សោភក្តិ បានក្លាយទៅជាប្រធានបទនៃការចំរូងចំរាស់ខ្វែងគំនិតគ្នា មិនទុកចិត្តគ្នាក្នុងផ្ទៃក្នុងនៃថ្នាក់ដឹកនាំរបស់រ.ជ.រ.ប.ខ. ទៅវិញ ។ ជាពិសេស រវាងថ្នាក់ដឹកនាំនៅបាងកក ទល់ដែន និង អ្នកជិតស្និទ្ធជាមួយលោកតា សឺន សាន នៅប្រទេសបារាំង ។ ប្រការដែលមិនប្រក្រតីនោះគឺ សោភក្តិ ដែលរស់នៅឯប្រទេសបារាំងនេះ ពុំបានទាក់ទងជាមុនជាមួយការិយាល័យរ.ជ.រ.ប.ខ. នៅទីក្រុងប៉ារីស មុននឹងធ្វើដំណើរទៅជួបថ្នាក់ដឹកនាំនៅឯប្រទេសថៃ ។ តាមធម្មតា អ្នកតំណាងរ.ជ.រ.ប.ខ. នៅទីក្រុងប៉ារីស ត្រូវណែនាំឲ្យថ្នាក់ដឹកនាំនៅបាងកកស្គាល់សមាជិកថ្មីនោះជាមុនៗនឹងគេអនុញ្ញាត ឲ្យចូលទៅស្គាល់ទីស្នាក់ការកណ្តាល រ.ជ.រ.ប.ខ. ឬ ចូលទៅក្នុងតំបន់រំដោះរបស់រ.ជ.រ.ប.ខ.។ លោក សិរីសោភក្តិ ធ្វើដំណើរដល់ទីហាមឃាត់ទាំងនោះ ដោយគ្មានការអនុញ្ញាត ឬ ដឹងឮជាមុនពីលោកតា សឺន សាន សោះឡើយ ។

កាលសម័យនោះ សម្រាប់អ្នករស់នៅឯបរទេស ការចេញដំណើរទៅចូលរួមក្នុងរណសិរ្សជួរមុខ អាចចាត់ទុកជាកិត្តិយសខ្ពង់ខ្ពស់ណាស់ ព្រោះអ្នកទាំងនោះអាចចាត់ទុកជាមនុស្សរកបានដោយកម្រ ។ ម្យ៉ាងដោយសារពួកគេភាគច្រើនមិន

អាចធ្វើបាន ព្រោះជាប់ជំពាក់ក្នុងការរស់នៅចិញ្ចឹមជីវិតប្រចាំថ្ងៃ ឬ ជាប់ជំពាក់ក្នុងគ្រួសារ ម្យ៉ាងទៀត ដោយត្រូវឆ្លងកាត់ការជ្រើសរើសពិនិត្យពិច័យយ៉ាងហ្មត់ចត់ណាស់ ជាពិសេសអ្នកដែលចេញពីសហរដ្ឋអាមេរិក ឬ អឺរ៉ុប ។ សមាជិករ.ជ.រ.ប.ខ.ទាំងអស់ មានការគោរពកោតស្ញប់ស្ញែងចំពោះអ្នកស្ម័គ្រចិត្តទៅធ្វើពលីកម្មគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុជាតិនៅសមរភូមិមុខនេះណាស់ ។ ពួកយើង នៅទីក្រុងប៉ារីសកាលពីមុនក៏ធ្លាប់ស្គាល់ សោភក្តិ ច្បាស់លាស់ដែរតែស្គាល់ក្នុងឋានៈជាអ្នកប្រណាំងប្រជែងគ្នា មិនមែនស្គាល់ក្នុងឋានៈជាអ្នកគាំទ្រដ៏ស្មោះស្ម័គ្រចំពោះ រ.ជ.រ.ប.ខ.នោះទេ ។

លោក ឱក សិរីសោភក្តិ ធ្លាប់ធ្វើការយ៉ាងសកម្មក្នុងសមាគម ឬ ក្រុមនយោបាយ ដែលពួកយើងធ្លាប់ស្គាល់ថា ជាអ្នកប្រណាំងប្រជែងយ៉ាងចេញមុខជាមួយ រ.ជ.រ.ប.ខ. ។ ដូច្នេះការដែល សិរីសោភក្តិ លេចមុខទៅជាយុទ្ធជនស្ម័គ្រចិត្តរបស់ រ.ជ.រ.ប.ខ.នៅលើសមរភូមិនោះ បានធ្វើឲ្យសមាជិករ.ជ.រ.ប.ខ.មួយចំនួននៅប្រទេសបារាំង មានការខកចិត្ត និង អាក់អន់ចិត្ត ហើយគិតថាមិនគួរគេអនុញ្ញាតឲ្យអ្នកក្រៅ ចូលទៅក្នុងបេះដូងរ.ជ.រ.ប.ខ.យ៉ាងស្រួលៗដូច្នេះសោះ ។ គួរកត់សំគាល់ថានៅក្នុងតំបន់រំដោះ សោភក្តិ បានខិតខំសរសេរអត្ថបទចុះផ្សាយក្នុងព្រឹត្តិប័ត្រ រ.ជ.រ.ប.ខ. កោតសរសើររ.ជ.រ.ប.ខ. ដោយរៀបរាប់ពីជោគជ័យជាច្រើនរបស់ រ.ជ.រ.ប.ខ. រួមមានការរៀបចំជាភូមិស្រុក ប្រកបដោយរបៀបរៀបរយ និង ការខិតខំអប់រំបណ្តុះបណ្តាលដល់យុទ្ធជន ទាំងទាហានទាំងស៊ីវិលឲ្យមានសមត្ថភាពខ្ពស់ក្នុងការតស៊ូដើម្បីរំដោះជាតិ ។ ក៏ប៉ុន្តែ នៅចុងខែ កក្កដា ១៩៨១ សោភក្តិ បានវិលត្រឡប់មកទីក្រុងប៉ារីសវិញ ដោយបានបង្ហាញហេតុផលថា៖[130] រៀបចំក្រុម

[130] ឱក សិរី សោភក្តិ, លិខិតជូនចំពោះលោកប្រធាន សឺន សាន ប្រធានរណៈសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ - សមរភូមិមុខ - ក្រេតីយ៍ ថ្ងៃទី ១ មេសា ឆ្នាំ ១៩៨២ ។

គ្រួសារឲ្យស្រួលបួលសិន ដើម្បីអាចឲ្យទៅរស់នៅជាយូរអង្វែងក្នុងជួរ.ជ.រ.ប.ខ.ត ទៅ -ធ្វើជាសាក្សី ចំពោះមុខសហគមន៍ខ្មែរនៅប្រទេសបារាំង ឲ្យដឹងពីការពិតនៃសកម្មភាពរបស់រ.ជ.រ.ប.ខ.នៅក្នុងប្រទេសកម្ពុជា ជាពិសេស សោភក្តិ មានបំណងសុំឲ្យរ.ជ.រ.ប.ខ. ដាក់ទិសដៅឃោសនាតម្រង់ទៅក្រុមយុវជន ដើម្បីអូសទាញអ្នកទាំងនោះ ឲ្យជួយគាំទ្ររ.ជ.រ.ប.ខ.ឲ្យបានច្រើនថែមទៀត ។ ហេតុផលចុងក្រោយលោក សោភក្តិ វិលមកប្រទេសបារាំងវិញនោះគឺ ចង់កែសម្រួលករណីរបស់ខ្លួនជាមួយនឹងការិយាល័យរ.ជ.រ.ប.ខ. នៅទីក្រុងប៉ារីសនេះ ជាពិសេស ដើម្បីកែលំអទំនាក់ទំនងផ្ទាល់ជាមួយលោកតា សឺន សាន និង សហការីរបស់លោកតាផង ។ តាមពិតទៅ សោភក្តិ មិនមែនជាមនុស្ស ដែលអាចចូលទៅជិតលោកតាបានស្រួលៗនោះទេ ហើយក៏មិនមែនអាចជាមនុស្សជំនិតរបស់លោកតាបានឡើយ ។ ក៏ប៉ុន្តែ សោភក្តិ មានទំនាក់ទំនងល្អ និង ជិតស្និទ្ធជាមួយសមាជិកសំខាន់ៗនៃគណៈកម្មាធិការប្រតិបត្តិ ឬ កូម៉ិច ដូចជា៖ លោក នាង ជិន ហាន អគ្គលេខាធិការ លោក ហ៊ឹង គន្ធុន និង លោកឧត្តមសេនីយ ដៀន ដែល ជាដើម ។

ករណីរបស់លោក សិរីសោភក្តិ បានបង្ហាញឲ្យឃើញថាការិយាល័យ រ.ជ.រ.ប.ខ. ប្រចាំទីក្រុងប៉ារីស ដែលស្ថិតនៅក្រោមឥទ្ធិពលរបស់អ្នកគាំទ្រ ឬ សមាជិកគ្រួសារលោកតា សឺន សាន មិនបានគ្រប់គ្រងផ្តាច់មុខទៅលើបណ្តាញទាំងអស់ ដែលអាចផ្តល់ការគាំទ្រដ៏ឧត្តុង្គឧត្តមដល់រ.ជ.រ.ប.ខ.នោះទេ ។ ផ្ទុយទៅវិញករណីនេះបញ្ជាក់ថាសមាជិកសំខាន់ៗនៅក្នុងថ្នាក់ដឹកនាំរបស់ រ.ជ.រ.ប.ខ. មិនមែនសុទ្ធតែធ្វើការតែជាមួយលោកតា សឺន សាន ឬ ជាមួយមនុស្សជំនិតរបស់លោកតានៅប៉ារីសនោះទេ ពួកគេក៏មានបណ្តាញរបស់គេ ដែលអាចជួយពង្រឹងឥទ្ធិពលរបស់រណសិរ្សផង និង ឥទ្ធិពលផ្ទាល់របស់ពួកគេផង ។ ម្យ៉ាងទៀត ករណីនេះសឲ្យឃើញថា រ.ជ.រ.ប.ខ. មិនមែនជារបស់ផ្តាច់មុខរបស់លោកតា សឺន សាន ឯការគ្រប់គ្រងព័ត៌

មានមកពីវណ្ណសិរ្សរបស់កូនប្រុសារលោកតា ក៏មិនប្រាកដជាមានផលប្រយោជន៍ប៉ុន្មានដែរ ព្រោះថាអ្នកក្រៅគេក៏អាចទទួលព័ត៌មានផ្ទាល់ពីទីស្នាក់ការកណ្តាលរ.ជ.រ.ប.ខ.បានដែរ ។ តែយ៉ាងណាក៏ដោយ ក៏ករណីលោក ឱក សិរីសោភក្តិ នេះត្រូវបានគណៈកម្មាធិការប្រតិបត្តិ ឬ កូមិុច លើកយកមកពិភាក្សានៅពេលក្រោយៗមកទៀត ។

## សន្និសីទអន្តរជាតិមួយស្តីពីកម្ពុជា

តាំងពីពេលដំបូងនៃជម្លោះនៅកម្ពុជានោះមក អង្គការសហប្រជាជាតិតែងតែថែរក្សាគោលជំហរដ៏ទៀងទាត់របស់ខ្លួន ស្របតាមសេចក្តីសំរេចរបស់មហាសន្និបាត ដែលតម្រូវឲ្យមានការកោះប្រជុំសន្និសីទអន្តរជាតិមួយស្តីពីកម្ពុជា ដើម្បីស្វែងរកកិច្ចព្រមព្រៀងលើការដកកងទ័ពវៀតណាមចេញពីទឹកដីខ្មែរ និង វិធានការទាំងឡាយ ដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ការគោរពសិទ្ធិមនុស្សជាពិសេស ដើម្បីរៀបចំការបោះឆ្នោតជាទូទៅមួយក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ ។ មហាសន្និបាតអង្គការសហប្រជាជាតិ បានចេញសេចក្តីសំរេចពីរលើករួចមកហើយគឺ ក្នុងខែ វិច្ឆិកា ១៩៧៩ និង ក្នុងខែ តុលា ១៩៨០ ។ នៅខែ មិថុនា ១៩៨១ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បានចេញសំណើតាមផ្លូវទូត ដើម្បីស្ទាបស្ទង់ដល់ប្រទេសសមាជិកទាំងអស់ថាតើពេលវេលាអាចសមស្រប ឬ នៅ? ដើម្បីកោះប្រជុំសន្និសីទអន្តរជាតិនោះ[131] ។

នៅថ្ងៃទី ១៨ មិថុនា ១៩៨១ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បានអញ្ជើញប្រទេសសមាជិកឲ្យចូលរួមប្រជុំ នៅទីស្នាក់ការអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉កនៅថ្ងៃទី ១៣ ខែ កក្កដា ១៩៨១ ។ ប្រទេសវៀតណាម និង

[131] Nations Unies, Rapport de la Conférence Internationale sur le Kampuchea, New York, 1981.

កម្ពុជាប្រជាធិបតេយ្យ បានត្រូវអញ្ជើញឲ្យចូលរួមក្នុងឋានៈជាភាគីជាប់ជំពាក់ក្នុងជម្លោះ ។ កម្ពុជាប្រជាធិបតេយ្យតំណាងដោយខ្មែរក្រហម បានចូលរួមប្រជុំ ក៏ប៉ុន្តែវៀតណាម មិនបានចាត់តំណាងឲ្យចូលរួមទេ ។ ប្រទេសសមាជិកទាំងអស់ចំនួន ៧៩ ប្រទេសបានចាត់តំណាងឲ្យចូលរួម ។ នៅសម័យប្រជុំពេញអង្គលើកដំបូង ប្រតិភូប្រទេសសឹង្ហបូរី បានស្នើសុំឲ្យក្រុមនយោបាយខ្មែរបីក្រុមចូលរួមប្រជុំគឺៈ ១. រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ.) ២. ហ្វ៊ុន ស៊ិន ប៉ិច (Funcin pec) ៣. គណបក្សប្រជាជនបដិវត្តន៍កម្ពុជា ឬ (រដ្ឋាភិបាល ហេង សំរិន)ឲ្យចូលរួមប្រជុំ តែមិនឲ្យមានសិទ្ធិបោះឆ្នោត ។ សន្និសីទបានព្រមឲ្យរ.ជ.រ.ប.ខ. និង ហ្វ៊ុន ស៊ិន ប៉ិច ចូលរួមតាមសំណើ ក៏ប៉ុន្តែបដិសេធមិនព្រមឲ្យតំណាងរដ្ឋាភិបាល ហេង សំរិន ចូលប្រជុំឡើយ[132] ។ តាមសំណើរបស់ហ្វីលីពីន ដោយមានការគាំទ្រពីប្រទេសសេណេហ្គាល់ (Senegal) អូស្ត្រាលី (Australia) វ៉េណេហ្ស៊ុយអេឡា (Venezuela) ប៊ែលហ្ស៊ិក (Belgique) អង្គសន្និសីទបានជ្រើសតាំងលោករដ្ឋមន្ត្រីក្រសួងការបរទេសអូទ្រីស វីល្លីបាដ ប៉ា (Willibard Pahr) ជាប្រធានសន្និសីទ ។ សន្និសីទនេះ បានចេញសេចក្តីប្រកាសអះអាងជាថ្មីនូវភាពមិនអាចរំលោភបាននៃរដ្ឋសមាជិកទាំងអស់ទៅលើ ឯករាជភាព អធិបតេយ្យភាព និងបូរណភាពទឹកដី ដោយគូសបញ្ជាក់នូវកាតព្វកិច្ចរបស់រដ្ឋសមាជិកទាំងអស់ ក្នុងការគោរពសិទ្ធិនៃប្រទេសជិតខាង ។ សេចក្តីប្រកាសនេះ បានថ្កោលទោសប្រទេសវៀតណាម ដែលបានលុកលុយ និង កាន់កាប់ទឹកដីកម្ពុជា និង កត់សំគាល់នូវផលវិបាកធ្ងន់ធ្ងរ ដែលអាចកើតមាន ដោយសារភាពតានតឹងនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍ ។ តាំងពីពេលដែលបានចូលរួមប្រជុំក្នុងសន្និសីទនេះ ចលនាអ្នកជាតិ

[132] Nations Unies, Rapport de la Conférence Internationale sur le Kampuchea, op. cit.

និយមទាំងពីរគឺរ.ជ.រ.ប.ខ.របស់លោកតា សឺន សាន និង ហ៊្វុន ស៊ិន ប៉ិច របស់សម្តេច សីហនុ  បានស្ថិតនៅជារណសិរ្សពីរដោយឡែកពីគ្នាជារៀងរហូត ។

## ជំនួប សឺន សាន - សីហនុ

នៅថ្ងៃទី ៣ សីហា ១៩៨១ លោកតា សឺន សាន ទៅគាល់សម្តេច សីហនុ នៅព្រះដំណាក់នាក្រុង មូហ្សាំង (Mougins) ឯតំបន់មាត់សមុទ្រភាគខាងត្បូងនៃប្រទេសបារាំង ។ ជំនួយការ និង ទីប្រឹក្សាដ៏ជិតស្និទ្ធទាំងឡាយរបស់លោកតា ផ្តល់យោបល់ឲ្យលោកតាប្រធាន  ប្រកាន់គោលជំហររឹងប៉ឹងនៅចំពោះព្រះភក្តិអតីតព្រះប្រមុខរដ្ឋ ព្រោះថាលោកតានាពេលនោះ មិនមែនជាមនុស្សសាមញ្ញធម្មតាដូចពេលមុនទៀតទេ  ដោយសារលោកតាទទួលបានតួនាទីជាអ្នកដឹកនាំដែលមានការទទួលស្គាល់រួចទៅហើយ  នៅក្នុងចលនាតស៊ូប្រឆាំងវៀតណាម ចំណែកសម្តេច សីហនុ ទ្រង់គង់ជាបុគ្គលឯកជនតែប៉ុណ្ណោះ[133] ។ នាសម័យនោះ ជនភៀសខ្លួនខ្មែរមួយចំនួនបានសម្លឹងឃើញលោកតា សឺន  សាន ដូចជានាយករដ្ឋមន្ត្រីជាប់ឆ្នោតរួចទៅហើយ  នៅរង់ចាំតែចូលកាន់តំណែងតែប៉ុណ្ណោះ  បន្ថែមលើតួនាទីជាប្រធានចលនាអ្នកជាតិនិយម រ.ជ.រ.ប.ខ.ដែលមានប្រទេសមួយចំនួនទទួលស្គាល់ផង ។ តាមពិតគោលបំណងរបស់លោកតា  សឺន  សាន  គឺ  ចង់បានការគាំទ្រជាសាធារណៈរបស់សម្តេច សីហនុ ក្នុងការខឹតខំរបស់លោកតា ដើម្បីប្រមែប្រមូលនិងច្របាច់បញ្ចូលគ្នាតែមួយនូវកងកម្លាំងអ្នកជាតិនិយមនានា  ។  ធ្វើយ៉ាងនេះ  ដើម្បីជៀសវាងនូវទ្រឹស្តី "ត្រីភាគីនិយម" (Tripartism) នៅពេលដែលត្រូវបង្កើតរដ្ឋាភិបាលចម្រុះជាមួយខ្មែរ

---

[133] នេះជាការវាយតំលៃសភាពការណ៍ខុស  ព្រោះតាមការព្រមព្រៀងគ្នារវាងលោក  គេង  ស៊ាវពីង  និង  លី  ខ្វាន់  យូ បានចែងថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យថ្មីនឹងត្រូវដឹកនាំដោយ សម្តេច សីហនុ ឬ លោក សឺន សាន មិនមែន សឺន សាន តែម្នាក់ឯងនោះទេ ។

ក្រហម ។ បន្ទាប់ពីជំនួបជាមួយសម្តេច សីហនុ លោកតា សឺន សាន បានផ្សព្វផ្សាយជាសាធារណៈថា សម្តេចបានគាំទ្រការខឹតខំប្រឹងប្រែងរបស់លោកតាក្នុងការបង្កើតរដ្ឋាភិបាលចម្រុះ ដែលតំណាងឲ្យកម្លាំងចលនាតស៊ូទាំងអស់ប្រឆាំងនឹងការលុកលុយ និង ការកាន់កាប់ប្រទេសខ្មែរដោយកងទ័ពវៀតណាម ។ មេដឹកនាំទាំងពីររូប បានសម្តែងទស្សនៈថា ពួកខ្មែរក្រហមនឹងវិលមកកាន់អំណាចវិញ នៅពេលដែលកងទ័ពវៀតណាមដកចេញពីកម្ពុជា ។ ទាំងនោះជាគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរចំពោះប្រជារាស្ត្រខ្មែរ ដែលប្រឆាំងដាច់ខាតនឹងការវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍ឯងនេះ ។ នៅក្នុងជំនួបនោះ លោកតា សឺន សាន បានទូលសម្តេចអំពីលក្ខខណ្ឌ ដែលតម្រូវឲ្យមានការធានាជាមុនពីមហាប្រទេសនានាដល់អាយុជីវិតរបស់ប្រជារាស្ត្រខ្មែរ[134] ។ លោកតាប្រធានបានស្នើសុំកុំឲ្យសម្តេច សីហនុ បង្កើតរណសិរ្សថ្មីមួយទៀត ប្រសិនបើសម្តេចគាំទ្រការខឹតខំរបស់លោកតា ។ ក៏ប៉ុន្តែសម្តេច សីហនុ នាពេលនោះមិនបានត្រៀមព្រះអង្គ ដើម្បីបោះបង់រណសិរ្សថ្មីរបស់ព្រះអង្គឈ្មោះ ហ៊្វុន ស៊ិន ប៉ិច នោះឡើយ ។ សម្តេចបានបំភ្លឺថា ព្រះអង្គគាំទ្រការខឹតខំរបស់លោកតា សឺន សាន តែក្នុងករណីណា ដែលលោកតាទទួលស្គាល់រណសិរ្ស ហ៊្វុន ស៊ិន ប៉ិច របស់ព្រះអង្គតែប៉ុណ្ណោះ ។

ត្រឡប់មកកាន់មូលដ្ឋានវិញ លោកតា សឺន សាន បានចាប់ផ្តើមធ្វើការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ដែលរស់នៅក្រោមការគ្រប់គ្រងរបស់រ.ជ.រ.ប.ខ. ។ ពីថ្ងៃទី ២៤ ទៅ ២៥ សីហា ១៩៨១ លោកតាអញ្ជើញទៅភូមិស្រោចស្រង់នៅបន្ទាយអំពិល ដែលជាទីបញ្ជាការកងទ័ពរ.ជ.រ.ប.ខ.រួចទៅជំរុំនងចាន់ និង រិទ្ធី

---

[134] សឺន សាន, សេចក្តីប្រកាស ចំពោះមុខសារព័ត៌មាននានា ក្រោយពីការជួបសន្ទនាជាមួយ សម្តេច ន. សីហនុ, ព្រឹត្តិបត្រ រ ជ រ ប ខ ខែ កញ្ញា ១៩៨១ ទំព័រ ១៦ ។

សែន ។ នៅក្នុងអង្គប្រជុំសាធារណៈទាំងឡាយ លោកតាប្រធានបានពន្យល់ថាវិបត្តិនៅកម្ពុជា អាចនឹងត្រូវដោះស្រាយបានតាមដំណោះស្រាយនយោបាយ ដែលនឹងកើតចេញពីសន្និសីទអន្តរជាតិមួយ ។ ដូច្នេះ លោកតាស្នើសុំការយល់ព្រមជាមុនពីសំណាក់ប្រជាពលរដ្ឋនូវវិធានការ និង លក្ខខណ្ឌដែលនឹងត្រូវលើកឡើងក្នុងការបង្កើតរដ្ឋាភិបាលចម្រុះ ។ លោកតាស្នើថា៖ "សូមបងប្អូនមេត្តាលើកដៃ ប្រសិនបើបងប្អូនយល់ព្រមលើចំណុចខាងក្រោម៖ ១. មិនអនុញ្ញាតឲ្យមានការបង្កើតរណសិរ្សថ្មីអ្វីក្រៅពីរ.ជ.រ.ប.ខ.ទៀតឡើយ ។ (លោកតាចង់សំដៅថាមិនត្រូវឲ្យមានការបង្កើត ហ៊្វុន ស៊ិន ប៉ិច ថែមលើ រ.ជ.រ.ប.ខ.ទៀតទេ) ២. សុំ ឲ្យបន្ថែមកម្លាំងដល់ រ.ជ.រ.ប.ខ. ឲ្យស្មើនឹងកម្លាំងខ្មែរក្រហម ឬ ៣. ក្នុងករណីដែលមានការបង្កើតរដ្ឋាភិបាលចម្រុះជាមួយខ្មែរក្រហមសមាជិក រ.ជ.រ.ប.ខ. ត្រូវតែទទួលបានកៅអីច្រើនជាងគេ និង សំខាន់ៗជាងគេ ៤. ក្នុងពេលអនាគត ប្រសិនបើមានឧបសគ្គណាមួយកើតឡើងតើសមាជិក រ.ជ.រ.ប.ខ. ត្រូវការឲ្យលោកតាបន្តបេសកកម្មដឹកនាំតទៅទៀតឬទេ? " សំណួរទាំង៤ចំណុចខាងលើនេះ សុទ្ធតែត្រូវ បានសំរឹតសំរាំងឡើង ដើម្បីឲ្យចម្លើយគាំទ្រតបមកវិញនោះបានក្លាយជាលក្ខខណ្ឌដែលលោកតានឹងយកទៅប្រើ នៅក្នុងពេលចរចាបង្កើតរដ្ឋាភិបាលចម្រុះនាពេលខាងមុខ ។ ឆ្លើយតបចំពោះសំណួរទាំងបួនចំណុច អ្នកចូលរួមក្នុងអង្គប្រជុំទាំងឡាយសុទ្ធតែបានលើកដៃគាំទ្រទាំងអស់ ។

## ជំនួប សឺន សាន- សីហនុ- ខៀវ សំផន នៅ សឹង្ហបុរី

នៅទីបញ្ចប់ ប្រទេសចិន និង អាស៊ាន បានស្រុះស្រួលគ្នារៀបចំឲ្យអ្នកដឹកនាំខ្មែរប្រឆាំងវៀតណាមទាំងបីរូប បានជួបពិភាក្សាគ្នានៅប្រទេសសឹង្ហបុរី ក្នុងខែកញ្ញា ១៩៨១ ។ អ្វីដែលលោកតា សឺន សាន ចង់ជៀសចេញនោះគឺទ្រឹស្តី "ត្រីភាគី

និយម″ នៅទីបំផុតក៏ពុំអាចគេចរួច ។ នៅថ្ងៃទី ៤ កញ្ញា ១៩៨១ នៅក្នុងប្រទេសសឹង្ហបុរី សម្តេច សីហនុ លោកតា សឺន សាន និង លោក ខៀវ សំផន បានជួបជុំគ្នា និង ចុះហត្ថលេខាលើសេចក្តីប្រកាសរួមមួយ ដែលក្នុងនោះមេដឹកនាំទាំងបីបានព្រមព្រៀងគ្នាលើចំណុចពីរសំខាន់ក្រៅពីការគាំទ្រសេចក្តីថ្លែងការណ៍ និង សេចក្តីសម្រេចរបស់សន្និសីទអន្តរជាតិស្តីពីកម្ពុជា ព្រមទាំងអំពាវនាវឲ្យបណ្តាប្រទេសដែលស្នេហាសន្តិភាពទាំងអស់គាំទ្រសេចក្តីថ្លែងការណ៍ និង សេចក្តីសំរេចទាំងនេះ[135] ។ ចំណុចសំខាន់ទាំងពីរនោះគឺ៖ ១. សំដែងបំណងបង្កើតរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ក្នុងគោលដៅបន្តការតស៊ូប្រយុទ្ធគ្រប់រូបភាព ដើម្បីរំដោះប្រទេសកម្ពុជាចេញពីអំពើឈ្លានពានរបស់វៀតណាម ២. បង្កើតគណៈកម្មការចំពោះកិច្ច ដើម្បីសិក្សាអំពីគោលការណ៍ និង បែបបទដែលអាចនាំទៅសម្រេចគោលដៅរដ្ឋាភិបាលចម្រុះខាងលើ ។

បន្ទាប់ពីមានការចុះហត្ថលេខាលើសេចក្តីប្រកាសរួមនេះមក មានការព្រមព្រៀងគ្នាជាមួយរដ្ឋមន្ត្រីការបរទេសនៃប្រទេសថៃ សឹង្ហបុរី និង ម៉ាឡេស៊ីថា រដ្ឋាភិបាលចម្រុះត្រីភាគីកម្ពុជាប្រជាធិបតេយ្យថ្មីនេះ នឹងត្រូវបង្កើតឡើងក្នុងពេលឆាប់ៗ ដោយមានលោកតា សឺន សាន ជានាយករដ្ឋមន្ត្រី ហើយក្នុងឋានៈជានាយករដ្ឋមន្ត្រីចាត់តាំងនេះ ( Prime Minster-designated ) លោកតាត្រូវដឹកនាំគណៈប្រតិភូខ្មែរទៅចូលរួមមហាសន្និបាតអង្គការសហប្រជាជាតិឲ្យទាន់ពេលវេលា ។ យោងតាមសេចក្តីប្រកាសរួមនេះដែរ មេដឹកនាំទាំង៣រូបបានចាត់តាំងតំណាងរៀងៗខ្លួនឲ្យចូលរួមក្នុងគណៈកម្មការចំពោះកិច្ច (Adhoc-Committee) ដែលក្នុងនោះ ខាងសម្តេច សីហនុ មាន៖ លោកតា អ៊ិន តាំ លោក បួរ ហ៊ែល និង លោក ចក់ សារឿន

[135] HRH Samdech Norodom Sihanouk, HE Mr. Son Sann, HE Mr. Khieu Samphan, Singapore, Joint Statement, 2-4 September 1981.

ឯខាងលោកតា សឺន សាន មានៈ[136] លោក ហ៊ីង គន្ធុន លោក នាង ជិនហន និង លោក ហ្គាហ្វា ពាងម៉េត ឯចំណែកខាងលោក ខៀវ សំផន មានៈ លោកស្រី អៀង ធីរិទ្ធ លោក សួង ស៊ីខឿន និង លោក ពេជ ប៊ុនរ៉េត ។

# តស៊ូមតិគ្នាក្នុងគណៈកម្មការចំពោះកិច្ច

គណៈកម្មការចំពោះកិច្ចនេះបានជួបប្រជុំជាលើកទី១ នៅថ្ងៃទី ១៣ កញ្ញា ១៩៨១ នៅទីក្រុងបាងកកប្រទេសថៃ និង បានប្រជុំជាបន្តបន្ទាប់នៅថ្ងៃទី ១៨-២២, ២៦ និង ២៨ កញ្ញា ១៩៨១ ដោយពុំបានឈានដល់ការព្រមព្រៀងគ្នាណាមួយឡើយ ។ បើតាមលោកតា អ៊ិន តាំៗបានឲ្យដឹងថា សម្តេច សីហនុ បានណែនាំឲ្យអ្នកតំណាងព្រះអង្គ នៅឲ្យស្ងៀមក្នុងអង្គប្រជុំ មិនចាំបាច់បញ្ចេញមតិអ្វីទាំងអស់ ហើយចាំតែគាំទ្ររាល់ការស្រុះស្រួលឬព្រមព្រៀងណាមួយរវាងរ.ជ.រ.ប.ខ. និង ខ្មែរក្រហមគឺ បានន័យថាឲ្យតែភាគីទាំងពីរស្រុះស្រួលគ្នា ខាងភាគីសម្តេចចាំតែគាំទ្រតែប៉ុណ្ណោះ ។ គោលជំហររបស់សម្តេចនេះជាវិធីដ៏ស្រួលបំផុត ដោយសារព្រះអង្គបានជ្រាបអស់ហើយនូវមូលដ្ឋាននៃកិច្ចព្រមព្រៀងរវាង ចិន និង អាស៊ាន តាមរយៈជំនួប តេង ស៊ាវពីង-លី ខ្វាន់ យូ កាលពីខែ វិច្ឆិកា ១៩៨០ ។

នៅថ្ងៃទី ២ តុលា ឆ្នាំ ១៩៨១[137] លោកតា សឺន សាន បានផ្ញើអនុស្សារណៈមួយទៅជូនក្រសួងការបរទេសថៃ ដើម្បីសរុបសភាពការណ៍នៃការចរចារបស់គណៈកម្មការចំពោះកិច្ចជូនម្ចាស់ផ្ទះជ្រាប ។ អនុស្សារណៈនោះ បានពន្យល់ពីគោលជំហរខ្វែងគ្នារវាង រ.ជ.រ.ប.ខ. និង ខ្មែរក្រហម ។ ខាង រ.ជ.រ.ប.ខ.ឈរលើគោលការណ៍ថារដ្ឋាភិបាលចម្រុះមានលក្ខណៈជាអន្តរកាលតែប៉ុណ្ណោះ ។ ឯទស្សន

[136] Son Sann, Décision, Singapour, le 5 Septembre 1981.

[137] Front National de Libération du Peuple Khmer, Memorandum Presented by Mr. Son Sann, President of the KPNLF to the Ministry of Foreign Affairs of the Royal Govenement of Thailand, October 2, 1981

ទានរបស់រដ្ឋាភិបាលចម្រុះនេះ ត្រូវផ្តោតលើការស្វែងរកជាប្រចាំនូវដំណោះស្រាយនយោបាយ ។ រដ្ឋាភិបាលចម្រុះនេះ ត្រូវមានស្ថាប័នផ្ទាល់របស់ខ្លួនដែលមានអំណាចពេញទី ដែលមិនត្រូវចំណុះឲ្យអង្គការណាមួយក្នុងរង្វង់រដ្ឋនៃរបបខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យនោះឡើយ ។ម្យ៉ាងទៀត លោកតាក៏បានរៀបរាប់ពីគោលជំហររបស់ខ្មែរក្រហមដែរ ដែលទាមទារថារដ្ឋាភិបាលថ្មី គ្រាន់តែជារដ្ឋាភិបាលបន្តពីរដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ ដែលមានទស្សនទានជាការតស៊ូតាមកម្លាំងទ័ពដ៏លើសលប់ ហើយរាល់រចនាសម្ព័ន្ធ កម្មវិធីនយោបាយ ស្ថាប័ន និង របៀបរបបដំណើរការទាំងឡាយ ត្រូវតែបន្តពីរបបខ្មែរក្រហមទាំងអស់តទៅទៀត ។ ម្យ៉ាងទៀតក្រុមខ្មែរក្រហមបានទទូចថា រដ្ឋាភិបាលចម្រុះត្រូវមានមូលដ្ឋានលើប្រព័ន្ធត្រីភាគីនិយម ក្នុងនោះភាគីនីមួយៗមានភាពស្មើគ្នា ឯការសំរេចទាំងឡាយត្រូវអនុវត្តតាមការយល់ព្រមជាឯកច្ឆ័ន្ទ ឬ កុងសង់ស៊ីស (Consensus) ។

រ.ជ.រ.ប.ខ រក្សាគោលជំហរថា ទាំងសមាសភាព ទាំងរចនាសម្ព័ន្ធ ទាំងដំណើរការរបស់រដ្ឋាភិបាលចម្រុះថ្មី ត្រូវតែមានវិធានការ និង នីតិវិធី ពិសេសដែលឆ្លើយតបទៅនឹងសភាពការណ៍នៃប្រទេសដែលកំពុងស្ថិតនៅក្នុងសង្គ្រាម ជាពិសេសក្នុងពេលមួយរយៈ ដើម្បីឲ្យរដ្ឋាភិបាលនេះអាចប្រមែប្រមូល និង ពង្រីកកម្លាំងភាគីទាំងអស់ក្នុងការតស៊ូរំដោះជាតិ ។ រ.ជ.រ.ប.ខ ស្នើថាគ្រប់សកម្មភាពរបស់រដ្ឋាភិបាលត្រូវគោរព និង អនុវត្តតាមសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិ និង សេចក្តីប្រកាសរបស់សន្និសីទអន្តរជាតិស្តីពីកម្ពុជាចុះថ្ងៃទី ១៧ កក្កដា ១៩៨១ នៅទីក្រុងញីវយ៉ក ។

នៅថ្ងៃទី ៤ តុលា ១៩៨១[138] គណៈកម្មការចំពោះកិច្ច បានជួបប្រជុំគ្នាជាថ្មីម្តងទៀត ។ ម្តងនេះ ខាងភាគីខ្មែរក្រហម បានសង្កត់ធ្ងន់ទៅលើគោលការណ៍ ៤

---

[138] Translation (into English) of the Official Record of the Sixth Ad Hoc Meeting held on October 4, 1981 under the Presidency of Mme. Ieng Thirith of Democratic Kampuchea.

ចំណុចៈ ១-រដ្ឋាភិបាលចម្រុះត្រូវតែឈរលើគោលជំហរមហាសាមគ្គីពិតប្រាកដ ២-រដ្ឋាភិបាលនេះត្រូវឈរលើគោលការណ៍ត្រីភាគី ។ ទាំងរចនាសម្ព័ន្ធ ទាំងសមាសភាពត្រូវយកភាពតំណាងស្មើគ្នាជាធំ ៣-រាល់បញ្ហាសំខាន់ៗ ត្រូវដោះស្រាយតាមការសំរេចជាឯកច្ឆ័ន្ទ នៅក្នុងរដ្ឋាភិបាល ៤-និរន្តរភាព ឬ ការបន្តរបស់រដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង និរន្តរភាពឬការបន្តជារដ្ឋសមាជិកនៃអង្គការសហប្រជាជាតិរបស់កម្ពុជាប្រជាធិបតេយ្យ ជាលក្ខណៈស្របច្បាប់នៃរដ្ឋាភិបាលចម្រុះនេះ ។ គោលការណ៍ទាំងនេះ ទាត់ចោលទាំងអស់នូវសំណើរបស់ភាគី រ.ជ.រ.ប.ខ. ។ អ្នកតំណាងរ.ជ.រ.ប.ខ. (ខាងលោកតា សឺន សាន) បានស្នើសុំរក្សាសិទ្ធិឆ្លើយតបចំពោះចំណុចទាំងបីដំបូងរបស់ខ្មែរក្រហម ព្រោះចំណុចទាំងនេះ ទាក់ទងនឹងបញ្ហាការចាត់តាំងតួនាទីរបស់នាយករដ្ឋមន្ត្រី និង សមាសភាពរបស់រដ្ឋាភិបាលចម្រុះ ។ ចំណែកឯចំណុចទីបួនរបស់ខ្មែរក្រហមទាក់ទងនឹងនិរន្តរភាព នៃរដ្ឋកម្ពុជាប្រជាធិបតេយ្យនោះ តំណាងលោកតា សឺន សាន បានសុំឲ្យក្រុមនេះ ផ្តល់ព័ត៌មានឲ្យបានទូលំទូលាយថា តើស្ថាប័នរបស់រដ្ឋកម្ពុជាប្រជាធិបតេយ្យនោះ មានរូបរាងភិនភាគ បែបបទ របៀបរបប ជាក់ស្តែងយ៉ាងដូចម្តេចខ្លះ? សូមបញ្ជាក់ថាក្នុងការចរចាគ្នាលើកនេះ ក៏ដូចជាលើកមុនៗដែរ ដូចមានក្នុងកំណត់ហេតុនៃកិច្ចប្រជុំស្រាប់ តំណាងរបស់សម្តេច សីហនុ យល់ព្រមតាមពួកខ្មែរក្រហមទៅលើគ្រប់ចំណុច រួមទាំងទុកឲ្យខាង រ.ជ.រ.ប.ខ. នៅឯកោម្នាក់ឯង ដែលជាកត្តាធ្វើឲ្យគោលជំហរចរចានៃភាគីនេះមានភាពទន់ខ្សោយជាទីបំផុត ។ នៅជាមួយគ្នានោះ ខាងក្រុមខ្មែរក្រហម ក៏យកឥរិយាបថរបស់សម្តេច សីហនុ មកធ្វើការគាបសង្កត់ឲ្យ រ.ជ.រ.ប.ខ. បន្ទន់គោលជំហររបស់ខ្លួន ។ កលវិធីបែបនេះ ត្រូវបានក្រុមខ្មែរក្រហមយកមកប្រើប្រកបដោយជោគជ័យ ។ នៅក្នុងប្រព័ន្ធត្រីភាគីនិយម បើគេបូកខ្មែរក្រហមជាមួយសម្តេច សីហនុ គេនឹងបានពីរភាគីទល់នឹងមួយភាគី (ខ្មែរក្រហម +

សម្តេច សីហនុ = ២ភាគី ទល់នឹងភាគី រ.ដ.រ.ប.ខ.) ។ ផ្ទុយទៅវិញ បើគ្មានក្រុមសម្តេច សីហនុ ទេគឺ ក្នុងប្រព័ន្ធទ្វេភាគីនិយមវិញនោះ ខ្មែរក្រហមប្រាកដជាត្រូវតែទល់ផ្ទាល់ជាមួយរ.ដ.រ.ប.ខ. មួយទល់ និង មួយតែប៉ុណ្ណោះ ។ ដោយសារមានប្រៀបបែបនេះ ទើបក្រុមខ្មែរក្រហមទទូចទាមទារយកប្រព័ន្ធត្រីភាគីនិយមមកជាមូលដ្ឋាននៃការចរចាបង្កើតរដ្ឋាភិបាលចម្រុះ ។ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏ រ.ដ.រ.ប.ខ. នៅតែចចេសរឹងរូសទប់ទល់នឹងប្រព័ន្ធត្រីភាគីនិយមនេះ ។ ដូច្នេះគោលបំណងនៃការបង្កើតរដ្ឋាភិបាលចម្រុះឲ្យបានទាន់ពេលវេលា សំរាប់ចូលប្រជុំមហាសន្និបាតប្រចាំឆ្នាំរបស់អង្គការសហប្រជាជាតិក៏ត្រូវបរាជ័យ ។ តាមពិតទៅទាំងខាងខ្មែរក្រហម ទាំងខាងភាគីសម្តេច សីហនុ សុទ្ធតែបានយល់ដឹងនូវគោលការណ៍ដែលបានព្រមព្រាងគ្នារួចហើយរវាងលោក តេង ស៊ាវពីង និង លោក លី ខ្វាន់ យូ ។ ដូច្នេះ មានតែខាងលោកតា សឺន សាន ទេ ដែលមិនបានយល់ដឹងទាំងស្រុង ហើយក៏ចេះតែទាមទារដោយឥតបានផលអ្វីទាំងអស់ ។

ក្នុងរយៈពេលនៃការចរចាបង្កើតរដ្ឋាភិបាលចម្រុះ លោកតាប្រធាន រ.ដ.រ.ប.ខ. នៅតែទាមទារយ៉ាងទៀងទាត់សុំឲ្យមានការផ្តល់ជំនួយ និង ឲ្យរ.ដ.រ.ប.ខ.បានទទួលកៅអីក្នុងគណៈរដ្ឋមន្ត្រីចំនួនភាគច្រើនដាច់ខាត និង ជំទាស់មិនឲ្យមេខ្មែរក្រហម ដែលល្បីឈ្មោះជាមេធំៗនៃរបបដែលកាប់សម្លាប់ប្រជារាស្ត្រឯងចូលក្នុងរដ្ឋាភិបាលថ្មីចម្រុះនេះឡើយ[139] ។ អ្វីដែល រ.ដ.រ.ប.ខ. ស្នើនោះគឺការសុំឲ្យបង្កើតក្រុមប្រឹក្សាជាតិមួយ ដែលមានសម្តេច សីហនុ ជាប្រធាន ដែលក្នុងឋានៈនេះព្រះអង្គជាប្រមុខរដ្ឋ ដើម្បីធានានូវនិរន្តរភាព បន្តលក្ខណៈស្របច្បាប់របស់រដ្ឋកម្ពុជាប្រជាធិប

---

[139] តាមការព្រមព្រៀង តេង ស៊ាវពីង - លី ខ្វាន់ យូ កម្ពុជាប្រជាធិបតេយ្យ ឬ ខ្មែរក្រហមអាចដាក់សមាជិក ណាក៏បាននៅក្នុងរដ្ឋាភិបាលថ្មី គ្មានអ្នកណាអាចបង្គាប់បញ្ជាបានឡើយ (The Three Points of Principle concerning the Kampuchean Question set forth by Vice-Chairman Deng Xiaoping During his Talks with Prime Minister Lee Kuan Yew on 11 November 1980, attached document, letter of Deng Xiaoping to Lee Kuan Yew dated May 28, 1981).

តេយ្យ និង ធានានូវឯករាជ្យ អធិបតេយ្យ ឯកភាព និង បូរណភាពទឹកដីជាតិនៃប្រទេសកម្ពុជាមួយ ដែលប្រកាន់អព្យាក្រឹតភាពមិនចូលបក្សសម្ព័ន្ធ ។ អព្យាក្រឹតភាពនេះ នឹង ត្រូវធានាដោយអន្តរជាតិ ។ ក្រុមប្រឹក្សាជាតិនោះមានតួនាទីផ្តល់មតិដល់រដ្ឋាភិបាលចម្រុះតែប៉ុណ្ណោះ ។ ចំណែកឯរដ្ឋាភិបាលចម្រុះ ដែលមានលោកតា សឺន សាន ជានាយករដ្ឋមន្ត្រីនឹងមានភារកិច្ច និង សមត្ថកិច្ចទូលំទូលាយ ដើម្បីដឹកនាំនយោបាយជាតិ និង ប្រើប្រាស់សិទ្ធិអំណាចលើគ្រប់វិស័យ នៅក្នុងរយៈពេលនៃការតស៊ូរំដោះជាតិ ។ សំណើនេះ គូសបញ្ជាក់យ៉ាងច្បាស់នូវលក្ខណៈបណ្តោះអាសន្ននៃរដ្ឋាភិបាល ដែលនឹងបំពេញតួនាទីត្រឹមតែក្នុងរយៈកាលឆ្លងកាត់ ឬ អន្តរកាលតែប៉ុណ្ណោះ[140] ។ ម្យ៉ាងទៀត សំណើនេះបានពង្រឹងតួនាទីរបស់នាយករដ្ឋមន្ត្រីដែលមានអំណាចទទួលយល់ព្រម ឬ ច្រានចោលសំណើតែងតាំងតំណែងសមាជិករដ្ឋាភិបាលណាមួយពីភាគីឯទៀត ។ ក្នុងន័យនេះលោកតា សឺន សាន អាចទាត់ចោលសំណើតែងតាំងមេដឹកនាំខ្មែរក្រហមល្បីៗដូចជា ប៉ុល ពត អៀង សារី នួន ជា តាម៉ុក ឬ អ្នកល្បីៗ ឯទៀត ។

នៅថ្ងៃទី ២៨ តុលា ១៩៨១ គណៈកម្មការចំពោះកិច្ច បានជួបប្រជុំគ្នាជាថ្មីទៀតជាលើកទី៧ ដោយពុំទទួលលទ្ធផលអ្វីទាំងអស់ ។ នៅថ្ងៃបន្ទាប់នារសៀលថ្ងៃទី ២៩ តុលា ១៩៨១[141] អ្នកតំណាងរបស់រ.ជ.រ.ប.ខ.ត្រូវបានកោះហៅឲ្យទៅប្រជុំជាបន្ទាន់នៅឯក្រសួងការបរទេសថៃ ។ នៅទីនោះ មន្ត្រីក្រសួងការបរទេសថៃលើកសំណួរឲ្យអ្នកតំណាងរ.ជ.រ.ប.ខ. ឆ្លើយជាបន្ទាន់ថាតើទទួល ឬ មិនទទួលនូវគំនិតនៃការបង្កើតរដ្ឋាភិបាលចម្រុះជាមួយខ្មែរក្រហម ។ មន្ត្រីក្រសួងការបរទេសថៃ សុំឲ្យតំណាងរ.ជ.រ.ប.ខ.នាំចម្លើយផ្ទាល់ពីលោកតា សឺន សាន ឲ្យបានរួសរាន់ក្នុងរយៈ

---

140 Memorandum presented by Mr. Son Sann, President of the K.P.N.L.F to the Ministry of Foreign Affairs of the Royal Thai Government, October 2, 1981.

141 KPNLF, Confidential Notes on the Formation of the Coalition Government of Democratic Kampuchea, November 1981.

ពេលប៉ុន្មានម៉ោងតែប៉ុណ្ណោះ ។ ក្រសួងការបរទេសថៃដាក់ឱសានវាទនៅល្ងាច ២៩ តុលា នោះដាក់កំហឹត បើពុំនោះទេនឹងបិទផ្លូវចរចាតទៅទៀត ។ មន្ត្រីនោះទូន្មានថា ក្នុងការចរចា បើភាគីរ.ជ.រ.ប.ខ. មិនអាចទទួលយកចំណុចទាំងអស់ យ៉ាងហោចណាស់ក៏អាចទទួលយក ដោយរក្សាសិទ្ធិតវ៉ាបាន ដើម្បីកុំឲ្យការចរចានោះគាំងស្ទះ ។

ពួកថៃហាក់ដូចជាធុញទ្រាន់ចំពោះពួកខ្មែរ ដែលនៅជ្រំជើងមិនដើរទៅមុខសោះក្នុងការចរចាបង្កើតរដ្ឋាភិបាលចម្រុះនេះ ។ នៅរសៀលនោះ លោកតា សឺន សាន បានផ្តល់ចម្លើយជូនលោក កាសេម កាសេមស៊ីរី លេខាធិការអចិន្ត្រៃយ៍នៃក្រសួងការបរទេសថៃ (បាឡាត់ក្រសួង) តាមរូបភាពចម្លើយផ្ទាល់មាត់ (Oral Reply) ដែលមានន័យសង្ខេបដូចតទៅ៖ ទី១ យល់ព្រមលើគោលការណ៍បង្កើតរដ្ឋាភិបាលចម្រុះជាមួយខ្មែរក្រហម តែសូមរក្សាសិទ្ធិតវ៉ា (Accepting with reser vations)តាមការទូន្មានរបស់មន្ត្រីថៃ ។ ទី២ ទទួលយកជាគោលការណ៍នូវចំណុច ១, ២, និង ៣ នៃអង្គប្រជុំគណៈកម្មការចំពោះកិច្ចកាលពីថ្ងៃទី ៤ និង ២៨ តុលា ១៩៨១ ដោយរក្សាសិទ្ធិមួយគឺ ឯ.ឧ. សឺន សាន មិនទទួលតួនាទីណាមួយទាំងអស់ក្នុងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ (ទាំងក្នុងក្រុមប្រឹក្សាជាតិ ទាំងក្នុងគណៈរដ្ឋមន្ត្រី) ។ ទី៣ ស្នើសុំបំភ្លឺជាបន្ទាន់ដល់ប្រជាពលរដ្ឋ ចំពោះគោលជំហរថ្មីនេះ ។ តាមចម្លើយនេះ លោកតា សឺន សាន ចាក់បណ្តោយតាមពួកថៃគឺទទួលយកទាំងអស់នូវចំណុចដែលខ្មែរក្រហមលើកឡើងទាំងប៉ុន្មាន ក៏ប៉ុន្តែលោកតាដាក់លក្ខខណ្ឌមួយវិញ ។ លក្ខខណ្ឌនោះគឺលោកតាមិនទទួលមុខតំណែងអ្វីទាំងអស់ ។ មិនតែប៉ុណ្ណោះ លោកតា សឺន សាន ថែមទាំងស្នើសុំទៅបំភ្លឺប្រជារាស្ត្រ ចំពោះគោលជំហរថ្មីនេះទៀតផង ។ យោងតាមយុទ្ធវិធីថ្មីដែលក្រសួងការបរទេសថៃបានចង្អុលបង្ហាញគឺ កុំប្រឆាំងតែអាចរក្សាសិទ្ធិតវ៉ា (Agree with reservations) ឬ

យល់ព្រមដោយមានលក្ខខណ្ឌនោះមក លោកតា សឺន សាន ក៏យល់ព្រមតាមមតិ ក៏ប៉ុន្តែ លោកតាយករូបលោកតាផ្ទាល់មកប្រើជាសន្លឹកបៀ "អាត់" នៅក្នុងការចរចាបន្តមកទៀត ។

# បើលោកតាមិនធ្វើ ព្រះអង្គក៏មិនធ្វើ

គណៈកម្មការចំពោះកិច្ច បានជួបប្រជុំជាច្រើនលើកទៀត នៅថ្ងៃទី ៣១ តុលា និង ថ្ងៃទី ១៤ វិច្ឆិកា ១៩៨១ ។ បន្ទាប់ពីបានរួមប្រជុំអស់ចំនួន ៩ លើកមក គណៈ កម្មការចំពោះកិច្ច ក៏ត្រូវបរាជ័យពុំអាចស្វែងរកការស្រុះស្រួលគ្នាបានឡើយ ។ ដោយឃើញគោលជំហររបស់លោកតា សឺន សាន មិនចូលរួមផ្ទាល់បែបនេះ សម្តេច សីហនុ បានផ្ញើសារទូរលេខមួយច្បាប់ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨១ ជូនលោកតា អ៊ិន តាំ ដែលមានន័យជាអាទិថា៖ "ខ្ញុំមិនអាចទទួលជាប្រធានប្រេស៊ីឌីយ៉ូម (ប្រធានរដ្ឋ ដែលជាមុខតំណែងស្នើឡើងដោយខ្មែរក្រហម) បានទេ ព្រោះថាផលប្រយោជន៍ដ៏យូរអង្វែងរបស់ប្រជារាស្ត្រខ្មែរ តម្រូវឲ្យយើងនៅក្រៅកម្ពុជាប្រជាធិបតេយ្យ"[142] ។ បើតាមលោកតា អ៊ិន តាំ សម្តេចបារម្ភថាបើព្រះអង្គសុខចិត្តចូលធ្វើការជាមួយខ្មែរក្រហម ដោយគ្មានលោកតា សឺន សាន ខ្លួនឯងចូលរួម ទុកឲ្យតែកូនចៅរបស់លោកតាចូលរួមនោះ លោកតា សឺន សាន អាចនឹងដើរឃោសនាយកចំណេញម្នាក់ឯងថា លោកតាមិនដែលជាប់ពាក់ព័ន្ធជាមួយខ្មែរក្រហមទេ និង ថាមានតែលោកតាទេ ដែលមានបាតដៃស្អាតមិនប្រឡាក់ឈាម ។ មែនទែនទៅ បើគ្មានការចូលរួមរបស់លោកតា សឺន សាន ទេ រដ្ឋាភិបាលចម្រុះថ្មី ក៏មិនខុសពីរាជ

[142] អ៊ិន តាំ, ឆ្នាំខួបទី៥ នៃរដ្ឋាភិបាលចម្រុះត្រីភាគី និង សម្លេងភ្នំពេញ, ទស្សនាវដ្តី នគរខ្មែរ ឆ្នាំទី ៩ លេខ ៩៨ ខែ មិថុនា ១៩៨៦ ទំព័រ ២ ។

រដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNK)[143] ដែលសម្តេច សីហនុ បានបង្កើតនៅទីក្រុងប៉េកាំងកាលពីឆ្នាំ ១៩៧០ ហើយដែលនៅទីបំផុតបាននាំ ប៉ុល ពត ឲ្យមកកាន់អំណាចនៅខែ មេសា ១៩៧៥ នោះឡើយ ។ បើគិតឲ្យសព្វគ្រប់ទៅ ការចូលរួមដោយផ្ទាល់របស់លោកតា សឺន សាន នៅក្នុងរដ្ឋាភិបាលចម្រុះអាចឲ្យរដ្ឋាភិបាលនោះទទួលទំនុកចិត្តច្រើន ព្រោះថា រ.ជ.រ.ប.ខ.ជាតួបន្លាស់មួយដែលអន្តរជាតិអាចទទួលយកបានផង និង ជាតួអង្គថ្មីលើឆាកនយោបាយក្នុងប្រទេសផង ។ ដូច្នេះសេចក្តីសំរេចរបស់លោកតា សឺន សាន ថាមិនចូលរួមដោយផ្ទាល់ក្នុងរដ្ឋាភិបាលចម្រុះបានក្លាយជាឧបស័គ្គចំបងក្នុងការបង្កើតរដ្ឋាភិបាលថ្មីនេះ ព្រោះថាបើលោកតាមិនចូលរួម សម្តេច សីហនុ ក៏មិនចូលរួមដែរ ។

ថ្ងៃទី ២២-២៣ វិច្ឆិកា រដ្ឋាភិបាលនៃប្រទេសសឹង្ហបូរី បានស្នើរូបមន្តមួយដែលហៅថា "រូបមន្តចម្រុះធូររលុង (Loose coalition) ដែលនៅក្នុងរូបមន្តនេះរដ្ឋាភិបាលចម្រុះមានគោលដៅចម្បងតែមួយគត់គឺ ការបន្តការតស៊ូប្រឆាំងនឹងការកាន់កាប់ប្រទេសកម្ពុជាដោយវៀតណាម បន្ទាប់មករដ្ឋាភិបាលនេះ នឹងត្រូវរំសាយដោយស្វ័យប្រវត្តិ ដើម្បីឲ្យមានការរៀបចំបោះឆ្នោត ដែលត្រូវរៀបចំឡើងដោយអង្គការសហប្រជាជាតិ" ។ រូបមន្តថ្មីនេះ បង្ហាញលក្ខណៈបណ្តោះអាសន្នរបស់រដ្ឋាភិបាលចម្រុះសមស្របតាមគោលជំហររបស់ រ.ជ.រ.ប.ខ. ដែលធ្លាប់លើកឡើងក្នុងគណៈកម្មការចំពោះកិច្ច ។ រ.ជ.រ.ប.ខ.បានគាំទ្ររូបមន្តនេះ ដោយគ្មានជជែកតវ៉ាអ្វីឡើយ ។ ចំណែកឯពួកខ្មែរក្រហម គេនៅតែប្រកាន់គោលជំហររឹងមាំរបស់ពួកគេដោយឈរលើគោលការណ៍ ៤ យ៉ាងគឺ៖ ១. គោលការណ៍ត្រីភាគីនិយម ២. គោលការណ៍ស្មើភាព និង មិនមានប្រៀបលើគ្នា ៣. គោលការណ៍សំរេចឯកច្ឆ័ន្ទចំពោះកិច្ចការសំខាន់ៗ ៤. គោលការណ៍ច្បាប់របស់រដ្ឋកម្ពុជាប្រជាធិបតេយ្យ- រដ្ឋាភិបាល

[143] Gouvernement Royal d'Union Nationale du Kampuchea (GRUNK).

ចម្រុះ ដែលនឹងត្រូវបង្កើត ត្រូវស្ថិតនៅក្រោមអំណាចច្បាប់របស់រដ្ឋកម្ពុជាប្រជាធិបតេយ្យ ដែលជារដ្ឋសមាជិករបស់អង្គការសហប្រជាជាតិ ។ បន្ថែមលើនេះ ខ្មែរក្រហមទាមទារកាន់កាប់ការងារខាងការបរទេសរបស់រដ្ឋាភិបាល និង ស្នើតែងតាំងលោក អៀង សារី ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ដែលផ្ទុយទាំងស្រុងនឹងជំហររបស់រ.ជ.រ.ប.ខ. ។

# ខ្មែរក្រហមទទួលការគាំទ្រពីសម្តេច សីហនុ

ដើម្បីគាបសង្កត់រ.ជ.រ.ប.ខ ឲ្យទទួលយកជំហររបស់ពួកគេ និង ឲ្យបន្ទន់ឥរិយាបថ ខ្មែរក្រហមក៏បានទៅគាល់សម្តេច សីហនុ ដើម្បីឲ្យសម្តេចស្រុះស្រួលយល់ព្រមតាមពួកគេ ។ សម្តេចក៏យល់ព្រមតាម ។ នៅក្នុងអនុស្សារណៈចុះថ្ងៃទី ៧ ឧសភា ១៩៨២[144] ផ្ញើជូនក្រសួងការបរទេសថៃ ខ្មែរក្រហមប្រកាន់គោលការណ៍ទាំង ៤ ខាងលើ ដោយលើកយកកិច្ចព្រមព្រៀងជាមួយសម្តេច សីហនុ នាខែ កុម្ភៈ ១៩៨២ ជាការគាំទ្រដល់គោលជំហររបស់ពួកគេ ។ ខ្មែរក្រហមទំលាក់កំហុសលើលោកតា សឺន សាន ថាជាអ្នកធ្វើឲ្យរាំងស្ទះដល់ការបង្កើតរដ្ឋាភិបាលចម្រុះ ។ អនុស្សារណៈរបស់ខ្មែរក្រហមនោះ មានសេចក្តីជាអាទិដូចតទៅ៖ "នៅក្នុងជំនួបជាមួយឯកឧត្តម ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋ និង ជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យ កាលពីថ្ងៃទី ២១ និង ២៣ កុម្ភៈ ១៩៨២ សម្តេចព្រះនរោត្តម សីហនុ បានទ្រង់ព្រមទទួលនូវគោលការណ៍ទាំងអស់(ខាងលើ)នៅពេលនេះ មានតែឯកឧត្តម សឺន សាន ទេ ដែលទាំងទស្សនវិស័យ ក៏ដូចជាសកម្មភាពជាក់ស្តែង មិនទាន់ទទួលយកនូវគោលការណ៍ខាងលើទាំងនោះនៅឡើយ" ។

[144] Democratic Kampuchea, Memorandum by the Democratic Party Concerning the "Declaration of the Formation of the Coalition Government of Democratic Kampuchea, Confidential Document, May 7, 1982.

នៅសម័យនោះ ក្រុមខ្មែរក្រហមបានទទួលការគាំទ្រយ៉ាងខ្លាំងពីឧត្តមសេនីយមួយចំនួននៃកងទ័ពជើងគោកថៃ ជាពិសេស ពីលោកឧត្តមសេនីយ ឆាវលិត យុងឆៃយុទ្ធ ដែលកាលគាត់នៅពាក់សក្តិវរសេនីយឯក បានទៅជួយរៀបចំនាំលោកតា សឺន សាន ឲ្យមកធ្វើជាអ្នកដឹកនាំចលនាតស៊ូមិនមែនកុម្មុយនីស្តក្នុងឆ្នាំ ១៩៧៩ ។ តាមពិតទៅឧត្តមសេនីយ ឆាវលិត ប្រើសន្លឹកបៀខ្មែរច្រើនសន្លឹកក្នុងពេលតែមួយ ដើម្បីក្តាប់ឲ្យណែននូវកូនសោរសំរាប់ដោះស្រាយបញ្ហាកម្ពុជា ។ លោក ឆាវលិត ត្រូវបានទទួលស្គាល់ថា ជាអ្នកយុទ្ធសាស្ត្រថៃដ៏សំខាន់ម្នាក់ ក្នុងការបង្ក្រាបពួកថៃក្រហម ឬ ថៃកុម្មុយនីស្ត ។ នៅទីបំផុត ឧត្តមសេនីយ ឆាវលិត ក៏ជាអ្នកធ្វើការគាបសង្កត់លើលោកតា សឺន សាន ឲ្យទទួលយកលក្ខខណ្ឌទាំងអស់របស់ខ្មែរក្រហមផងដែរ ។

## ខ្ញុំជូនលោកតា ទៅជួបទូតអាមេរិក ជាលើកដំបូង

នៅដើមឆ្នាំ ១៩៨២ លោកតា សឺន សាន ធ្វើដំណើរឡើងចុះពីមូលដ្ឋានរបស់គាត់ពីទីក្រុងបាងកកទៅទីក្រុងប៉ារីស និង រដ្ឋធានីនានានៃទ្វីបអឺរ៉ុប ។ នៅថ្ងៃទី ១៩ មីនា ១៩៨២ លោកតាបានអញ្ជើញទៅជួបលោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក អ៊ីវ៉ាន់ ហ្គាល់ប្រេត (Evan Galbraith) នៅទីក្រុងប៉ារីស[145] ។ ពេលនោះជាលើកទី១ដែលខ្លួនខ្ញុំត្រូវបានឲ្យទៅហែរហមលោកតាក្នុងឋានៈជាអ្នកជំនួយការ ទៅជួបលោកឯកអគ្គរដ្ឋទូត ។ នោះក៏ជាលើកទី១ដែលខ្ញុំបានចូលទៅក្នុងពិភពការទូត ។ ដូចរាល់ៗដងលោកបណ្ឌិត ឆាយ ហាន់ចេង ជាអ្នកបើកបររថយន្តនាំពួកយើងទៅកាន់ស្ថានទូត ចំណែកឯខ្ញុំៗមានភារកិច្ចជាអ្នកកត់ត្រាការពិភាក្សាទាំង

[145] Ieng Mouly, Compte-rendu de l’entretien du Président du FNLPK avec l’Ambassadeur des Etats Unis en France, Paris, le 19 mars 1982.

មូលរវាងលោកតា និង លោកទូតសហរដ្ឋអាមេរិក ។ តាមពិតទៅ នៅក្នុងជំនួបនោះ លោកតា សឺន សាន បានទៅសុំជំនួយមនុស្សធម៌មានថ្នាំពេទ្យ សំលៀកបំពាក់ និង គ្រាប់រំសេវ សំរាប់កងទ័ព និង ប្រជារាស្ត្រនៃភូមិរំដោះគឺភូមិសុខសាន្ត១ និង សុខសាន្ត២ ដែលត្រូវកងទ័ពហាណូយវាយកំទេច ។ លោក តា សឺន សានក៏បានធ្វើការថ្កោលទោសកងទ័ពវៀតណាម ដែលបានប្រើប្រាស់អាវុធគីមី នៅពេលវាយប្រហារមកលើភូមិរបស់រ.ជ.រ.ប.ខទាំងនោះ ។ លោកតាសន្យាជាមួយលោកទូតសហរដ្ឋអាមេរិកថា នៅពេលណាបានលទ្ធផលពីមន្ទីរពិសោធន៍ស្តីពីជាតិគីមីទាំងនោះ លោកតានឹងផ្សព្វផ្សាយជាសាធារណៈ ។

នៅក្នុងពេលលោកតា សឺន សាន ស្នាក់អាស្រ័យនៅប្រទេសបារាំង ខ្ញុំក៏បានជួយរៀបចំសន្និសីទកាសែតជាច្រើន ជូនលោកតានៅទីក្រុងប៉ារីស និង បានជូនដំណើរលោកតាប្រធាន ទៅធ្វើទស្សនកិច្ចតាមខេត្តនានា ។ នៅរាល់ការប្រជុំជាសាធារណៈទាំងឡាយ លោកតា សឺន សាន តែងបង្ហាញរូបខ្ញុំ និង លោក ប៉ែន ថាល់ ចំពោះអ្នកចូលរួមទាំងឡាយថាជាអ្នកស្ម័គ្រចិត្ត ទៅធ្វើការតស៊ូនៅសមរភូមិមុខ ។ តាមពិតទៅ លោកតា សឺន សាន ក៏មានផែនការពង្រឹងបុគ្គលិកផ្ទាល់របស់លោកតាឲ្យបានឆាប់រហ័សដែរ ដើម្បីត្រៀមទទួលការងារដែលនឹងមានកាន់តែច្រើនឡើងៗបន្ទាប់ពីការបង្កើតរដ្ឋាភិបាលចម្រុះ និង ដើម្បីត្រៀមទទួលជំនួយបរទេសដែលអាចនឹងកើនឡើងនោះ ។ វត្តមានរបស់ខ្ញុំនៅក្បែរលោកតា និង នៅលើសមរភូមិមុខ អាចនឹងជួយលោកតាឲ្យកាន់តែក្តាប់បានកាន់តែខ្លាំងឡើងនូវចលនា រ.ជ.រ.ប.ខ.ដែលកំពុងតែមានការរីកចំរើន ។ ការប្រជុំជាសាធារណៈចុងក្រោយបង្អស់បានធ្វើឡើងនៅទីក្រុងទូលូហ្ស (Toulouse) ដែលក្នុងចំណោមសមាជិក រ.ជ.រ.ប.ខ. ខ្ញុំមានមិត្តភក្តិជាច្រើននាក់ ។

# ខ្ញុំ និង បង ប៉ែន ថាល់ ចេញទៅសមរភូមិ

ការចេញដំណើររបស់អ្នកស្ម័គ្រចិត្តលើកនេះ មិនដូចការចេញដំណើរមុនៗទេ ការចេញដំណើររបស់ពួកយើងគឺ លោក ប៉ែន ថាល់ និង ខ្ញុំ ត្រូវបានផ្សព្វផ្សាយតាមទំព័រសារព័ត៌មាន ។ តាមការរៀបចំទុកជាមុន ពួកយើងត្រូវចេញដំណើរពីទីក្រុងប៉ារីសទៅទីក្រុងបាងកក នៅថ្ងៃទី ១៨ ឧសភា ១៩៨២ ។ ក៏ប៉ុន្តែ លោកតា សឺន សាន ត្រូវបានចេញដំណើរទៅមុន ព្រោះលោកតាត្រូវប្រញាប់ទៅមើលការខុសត្រូវលើការចរចាបង្កើតរដ្ឋាភិបាលចម្រុះ ។ ចំពោះរូបខ្ញុំ ខ្ញុំពុំបានត្រៀមលក្ខណៈអ្វីពិសេសសំរាប់ការចេញដំណើរនោះទេ លើកលែងតែខ្ចប់យកសៀវភៅ និង ខោអាវខ្លះៗតែប៉ុណ្ណោះ ព្រោះខ្ញុំត្រូវប្រគល់ផ្ទះរបស់ខ្ញុំនោះទៅប្រគេនព្រះតេជគុណព្រះគ្រូ ស សាស្រ្ត ឲ្យព្រះអង្គប្រើប្រាស់ជាកុដិបណ្តោះអាសន្នរបស់ព្រះអង្គ ទម្រាំលោកនិមន្តទៅគង់នៅវត្តណាមួយ ។ ដូច្នេះ ខ្ញុំក៏ប្រមែប្រមូលរបស់របររបស់ខ្ញុំដែលគ្មានអ្វីក្រៅពីសៀវភៅមើល ខោអាវក្រាស់ៗសំរាប់រដូវរងារ ឯកសារប្រចាំគ្រួសារ និង កែវ ចានល្អៗខ្លះ ទុកដាក់ក្នុងហិបដែកធំៗពីរ រួចយកទៅផ្ញើទុកក្នុងផ្ទះលោក ទេព ដារ៉ុង ។ ខ្ញុំសំរេចលក់រថយន្ត Renault 5 Le Car របស់ខ្ញុំឲ្យបងរបស់ដារ៉ុងឈ្មោះ ទេព សំប៊ុនណា តែសុំឲ្យគាត់ចាំទទួលយករថយន្តនោះ នៅឯអាកាសយានដ្ឋាន នៅថ្ងៃខ្ញុំឡើងយន្តហោះតែម្តង ។

នៅល្ងាចថ្ងៃសៅរ៍ទី ១៥ ឧសភា ១៩៨២ លោកតា លឹម គ្រី អតីតរដ្ឋមន្រ្តីយុត្តិធម៌ (សម័យសង្គមរាស្រ្តនិយម) ប្រធានការិយាល័យផ្សាយព័ត៌មានរបស់ រ.ជ.រ.ប.ខ.ប្រចាំទីក្រុងប៉ារីស បានរៀបចំពិធីជប់លៀងលាគ្នាមួយជូនជាកិត្តិយសដល់រូបខ្ញុំ និង លោក ប៉ែន ថាល់ ។ ដោយមានសមាជិកចូលរួមប្រហែល ៥០ នាក់ ។ នោះជាឱកាសដ៏រំភើបសំរាប់រូបខ្ញុំ នៅពេលដែលលោកតា លឹម គ្រី ថ្លែងសង្កថា

ដោយឥតព្រាងទុកលើកសរសើរសេចក្តីក្លាហាន ព្រមទាំងលើកកំពស់ពលីកម្មដល់អាយុជីវិតរបស់ពួកយើងទាំងពីរនាក់ ។ ជាការឆ្លើយតប ចំពោះការកោតសរសើរទាំងនេះ បង ប៉ែន ថាល់ ស្នើឲ្យខ្ញុំនិយាយជំនួស ។ ខ្ញុំក៏ក្រោកឡើង រួចហូតចេញពីហោប៉ៅអាវនូវអត្ថបទសរសេរដៃមួយច្បាប់ ដែលខ្ញុំបានត្រៀមជាស្រេច ។ ខ្ញុំបានសំដែងនូវមនោសញ្ចេតនាដឹងគុណ ចំពោះសហសេវិកទាំងឡាយដែលបានធ្វើការជាមួយគ្នាអស់រយៈពេលជាច្រើនឆ្នាំ និង ចំពោះមិត្តភាពដែលបានផ្តល់ដល់ពួកយើង ព្រមទាំងចំពោះស្មារតីស្នេហាជាតិដែលគេមានចំពោះប្រទេសជាតិ ព្រោះថាសហសេវិកទាំងអស់នោះ សុទ្ធតែបានចំណាយពេលវេលាដ៏មានតម្លៃធនធានប្រាក់កាស និង សម្ភារៈ ដើម្បីចូលរួមគាំទ្រការតស៊ូដ៏យូរអង្វែងសំរាប់ប្រជាជាតិយើង ។ សុន្ទរកថារបស់ខ្ញុំមានន័យជាអាទិ៍ថា៖[146] "ក្នុងកាលៈទេសៈដែលប្រទេសជាតិកំពុងត្រូវបរទេសជិះជាន់កាន់កាប់ដូចសព្វថ្ងៃនេះ យើងជាកុលបុត្រខ្មែរមានករណីយកិច្ចធ្វើពលីកម្ម ដើម្បីជួយស្រោចស្រង់កេរដំណែលដូនតាយើងកុំឲ្យសាបសូន្យ ។ យើងទាំងអស់គ្នា បានឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃមាតុប្រទេស ដោយសុខចិត្តជួយឧបត្ថម្ភទាំងខាងសម្ភារៈ ទាំងខាងសតិអារម្មណ៍ដល់ការតស៊ូរបស់ប្រជារាស្ត្រយើង ដោយចូលមករួបរួមក្នុងជួរណេសិរ្សជាតិរំដោះប្រជារាស្ត្រខ្មែរ" ។ នៅពេលខ្ញុំអានសុន្ទរកថានេះចប់ ខ្ញុំក៏បានលើកយកមកបន្ថែមនូវពាក្យស្លោករបស់អ្នកដឹកនាំជាតិបារាំងសម័យសង្គ្រាមលោកទី១ ឈ្មោះលោក ហ្សក ក្លេម៉ង់សូ (Georges Clemenceau) ដែលមានសេចក្តីជាអាទិ៍ថា៖ "បើធ្វើត្រឹមតែជាវីរបុរសមិនទាន់គ្រប់គ្រាន់ទេ អ្វីដែលយើងចង់បានគឺ ជ័យជំនះនៅក្នុងសង្គ្រាម" ។

នៅព្រលានយន្តហោះនាថ្ងៃទី ១៨ ឧសភា ១៩៨២ មានជនជាតិខ្មែរប្រមាណ ១០០ នាក់ មកជូនដំណើររបស់ពួកយើង ។ ថ្ងៃនោះ ជាព្រឹត្តិការណ៍ប្រវត្តិ

[146] អៀង មូលី អត្ថបទសរសេរដៃ គ្មានចុះថ្ងៃ ខែ ។

សាស្ត្រមួយសំរាប់ជីវិតខ្ញុំ ។ ក្នុងចំណោមហ្វូងមនុស្ស ខ្ញុំសង្កេតឃើញឥស្សរជនមួយក្រុមដឹកនាំដោយលោកតា ស៊ឹម វ៉ា អតីតនាយករដ្ឋមន្ត្រី និង ជាអ្នកនយោបាយប្រឆាំងសម្តេច សីហនុ យ៉ាងស្លាប់រស់មួយរូប ។ ក្នុងនោះ ក៏មានព្រះសង្ឃជាច្រើនអង្គដែលនិមន្តមកសូត្រជយន្តោ ប្រោះព្រំផ្តល់ពរជ័យដល់ពួកយើង សុំឲ្យយើងទាំងពីរនាក់ទទួលជ័យជំនះគ្រប់យ៉ាង។ លោកតា ស៊ឹម វ៉ា សំដែងការកោតសរសើរចំពោះសេចក្តីសំរេចរបស់ខ្ញុំ ក្នុងការលះបង់ភាពសុខស្រួលនៅទីក្រុងប៉ារីស ដើម្បីទៅធ្វើការតស៊ូនៅសមរភូមិមុខ ដោយលោកតាមានប្រសាសន៍ថា៖ "ការលះបង់នេះជាសេចក្តីស្នេហាជាតិមាតុភូមិដ៏បរិសុទ្ធបំផុត" ។ នៅពេលច្រើនខែក្រោយបន្ទាប់មក លោកតា ស៊ឹម វ៉ា បានសរសេរសំបុត្រមួយច្បាប់មកខ្ញុំមានសេចក្តីជាអាទិថា៖ "ដោយសារអ៊ុំមានអាយុច្រើន អ៊ុំពុំមានលទ្ធភាពធ្វើការលះបង់ (payer le luxe) ទៅនៅសមរភូមិមុខ ដើម្បីបំរើមាតុភូមិយើងបានឡើយ" ។ មិត្តខ្ញុំ រ៉ូឡង់ រូស្សូ (Roland Rousseau) ដែលបានមកជូនដំណើរដែរនោះ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះឃើញមនុស្សច្រើនពេក មកជូនពរពួកយើង ។ លោក សុខ វ៉ាន់ធី ម្ចាស់ភោជនីយដ្ឋាន "នាគទិសខាងជើង" (Dragon du Nord) បានមកចាប់ដៃខ្ញុំចាប់ហើយចាប់ទៀត មិនចង់លែងប្រកបដោយពាក្យពេចន៍សោកស្តាយ ដោយការបែកគ្នា ព្រមទាំងជូនពរឲ្យជួបតែជ័យជំនះ ។ នៅពេលហៀបនឹងឡើងយន្តហោះបង វ៉ាន់ធី ចាប់ដៃខ្ញុំ បង្ខំឲ្យខ្ញុំដោះនាឡិកាដៃខ្ញុំម៉ាក Timex មានតម្លៃ ១០០ ហ្វ្រង់ទៅឲ្យគាត់ ។ ខ្ញុំមានការភ្ញាក់ផ្អើលដែរ ដោយមិនដឹងគាត់ចង់យកទៅធ្វើអ្វី បើនាឡិកានោះ មានតម្លៃថោកយ៉ាងនេះ ។ ក៏ប៉ុន្តែបង វ៉ាន់ធី និយាយថាទុកជាវត្ថុអនុស្សាវរីយ៍ ។ នៅពេលខ្ញុំហុចនាឡិកាខ្ញុំទៅឲ្យគាត់ៗក៏ហុចនាឡិកាគាត់មកឲ្យខ្ញុំវិញទុកជាការដោះដូរគ្នា ។ នៅពេលនោះ ខ្ញុំមិនបានចាប់អារម្មណ៍អ្វីប៉ុន្មានទេចំពោះនាឡិ

ការបស់បង វ៉ាន់ធី នោះ ខ្ញុំក៏ពាក់ជាប់នៅដៃភ្លាម ។ ក្រោយមក ទើបខ្ញុំដឹងថានាឡិកានោះ មានតម្លៃជិតពីរម៉ឺនដុល្លារឯនោះ ព្រោះជានាឡិកាម៉ាករ៉ូឡិច (Rolex) ។

យើងទាំងពីរនាក់បង ប៉ែន ថាល់ និង ខ្ញុំ បានលាមិត្តភក្តិអ្នកជូនដំណើរទាំងអស់ ដោយក្តីអាឡោះអាល័យ ។ បន្ទាប់មក យើងនាំគ្នាដើរទៅបញ្ជរអន្តោប្រវេសន៍ ដើម្បីឲ្យនគរបាលត្រួតពិនិត្យឯកសារធ្វើដំណើរ និង បោះទិដ្ឋាការចេញ រួចនាំគ្នាអង្គុយរង់ចាំយន្តហោះ នៅក្នុងបរិវេណតំបន់អន្តរជាតិនៅសាលរង់ចាំ ។ នៅពេល ដែលយើងកំពុងរង់ចាំឡើងជិះយន្តហោះនោះ យើងក៏ឃើញមិត្តនារីរបស់យើងម្នាក់ឈ្មោះនាង ដារ៉ាវិចិត្រ បានមកដល់ ព្រោះតែចង់ជួបមុខពួកយើងនៅនាទីចុងក្រោយ ។ នៅពេលនោះ យើងពុំបានដឹងថា ដារ៉ាវិចិត្រ បានដើរតាមពីក្រោយពួកយើងជាប់រហូត ដោយពុំមានប័ណ្ណសំគាល់ខ្លួនអ្វីមកជាប់នឹងខ្លួនឡើយ ។ ប៉ុន្តែយើងដឹងថានាង ដារ៉ាវិចិត្រ ជាអ្នកពូកែនិយាយ បានមាត់បានក អាចបញ្ចុះបញ្ចូលនគរបាលអន្តោប្រវេសន៍ឲ្យអនុញ្ញាតឲ្យនាងឆ្លងកាត់តំបន់ត្រួតពិនិត្យបាន ។ ក៏ប៉ុន្តែនៅពេលដែលពួកយើងចូលទៅក្នុងយន្តហោះបាត់ទៅ ហើយនៅពេលត្រូវវិលត្រឡប់ចេញទៅវិញនោះ នាង ដារ៉ាវិចិត្រ ក៏ត្រូវឆ្លងកាត់តំបន់ត្រួតពិនិត្យម្តងទៀត ។ ម្តងនេះនគរបាលអន្តោប្រវេសន៍ជាអ្នកត្រួតពិនិត្យថ្មី មិនបានដឹងថាតើនាងត្រូវបានអនុញ្ញាតឲ្យឆ្លងកាត់តំបន់អន្តរជាតិដោយមាត់ទទេទេនោះ ក៏បានសួររកប័ណ្ណសំគាល់ខ្លួន ។ ដោយគ្មានប័ណ្ណសំគាល់ខ្លួនជាប់មកជាមួយ ដារ៉ាវិចិត្រ ក៏ត្រូវនគរបាលឃាត់ខ្លួន អស់រយៈពេលជាច្រើនម៉ោង នៅក្នុងវាលយន្តហោះ ហ្សាលដឺហ្គោល (Charles de Gaulle) ។ មែនទែនទៅ ខ្ញុំដឹងរឿងរ៉ាវថា ដារ៉ាវិចិត្រ ត្រូវប៉ូលីសបារាំងឃាត់ខ្លួននេះ បន្ទាប់ពីពួកយើងបានធ្វើដំណើរមកដល់ទីក្រុងបាងកកតាមរយៈសំបុត្រ ដែលដារ៉ាវិចិត្រ ផ្ញើមកពួកយើងតាមក្រោយតែប៉ុណ្ណោះ ។

# បង ប៉ែន ថាល់ ថា៖ កុំឲ្យបាត់បង់សេចក្តីថ្លៃថ្នូរ

នៅលើយន្តហោះ ខ្ញុំកាន់តែស្គាល់បង ប៉ែន ថាល់ ច្បាស់ឡើងៗគឺគាត់ជាអ្នកចេះដឹងជ្រៅជ្រះណាស់ ។ គាត់ធ្លាប់បានសិក្សានៅទីក្រុងទូលូហ្ស(Toulouse) មានសញ្ញាប័ត្រជាន់ខ្ពស់ខាងផ្នែកពាណិជ្ជកម្ម និង ចេះភាសាបារាំង និង អង់គ្លេសយ៉ាងស្ទាត់ជំនាញ ។ នៅក្នុងរយៈពេលនៃការហោះហើរ ទោះបីជាពួកយើងទិញសំបុត្រយន្តហោះថ្នាក់ថោកជាងគេ (Economy class) យ៉ាងណាក៏ដោយ ក៏បង ប៉ែន ថាល់ ចេះនិយាយបញ្ចុះបញ្ចូលនារីអ្នកបំរើឲ្យមកផ្តល់ឲ្យយើងនូវស្រាសាំប៉ាញ និង ស្រាល្អៗជាបន្តបន្ទាប់ ដែលជាសេវាសំរាប់ថ្នាក់ធុរកិច្ច (Bussiness class) ឬ ថ្នាក់ខ្ពស់ជាងទៀត ។ នៅក្នុងរបប ប៉ុល ពត បង ប៉ែន ថាល់ បានបាត់បង់ប្រពន្ធ និង កូនស្រីជាទីស្រឡាញ់របស់គាត់ ។ តាមរយៈការសន្ទនាគ្នា ខ្ញុំអាចមើលឃើញគាត់ជាមនុស្ស ដែលមានវិបត្តិខាងផ្លូវចិត្តយ៉ាងធំធេង ។ គាត់ច្បាស់ជាទទួលនូវទារុណកម្មដ៏ធ្ងន់ធ្ងរ ដែលតម្រូវឲ្យយកសុរាមកជាគ្រឿងបន្លប់ទុក្ខ ឬ ដើម្បីបំភ្លេចបទពិសោធន៍ដ៏ចុកចាប់ ក្នុងរយៈពេលឆ្លងកាត់នាសម័យរបបប្រល័យពូជសាសន៍ ។ ជាមួយគ្នានោះ ខ្ញុំក៏មើលឃើញភាពក្លាហានអង់អាចមុះមុតរបស់គាត់ដែរ ។ ទើបតែរំដោះខ្លួនផុតពីរបប ប៉ុល ពត មិនទាន់បានប៉ុន្មានផង ឥឡូវគាត់ស្ម័គ្រចិត្តចូលមកបំរើ រ.ជ.រ.ប.ខ. នៅសមរភូមិមុខ ទុកចោលកូនប្រុសម្នាក់រស់នៅជាមួយមិត្តភក្តិឯទីក្រុងប៉ារីសទៀតផង ។ ភ្លាមៗនោះ យើងទាំងពីរនាក់ ក៏កាន់តែមានភាពជិតស្និទ្ធគ្នាឡើងក្នុងមិត្តភាព និង ភាតរភាព ។ បង ប៉ែន ថាល់ និយាយដោយសង្កត់ពាក្យថា៖ "ប្អូនប្រុស យើងអាចបាត់បង់អ្វីៗទាំងអស់បាន តែយើងមិនអាចបាត់បង់សេចក្តីថ្លៃថ្នូរបានឡើយ" ។ "ឥឡូវយើងសុខចិត្តដាក់ជីវិតយើងរៀងៗខ្លួននៅក្នុងកន្ត្រកតែមួយគឺ យើងជិះទូកតែមួយជាមួយគ្នា" ។

នៅលើអាកាសវេហា ខ្ញុំគិតមមៃតែទៅលើការតស៊ូរំដោះជាតិ រំដោះកម្ពុជាពីការកាន់កាប់របស់បរទេស រំដោះប្រជារាស្ត្រខ្មែរឲ្យមានសេរីភាព និង លទ្ធិប្រជាធិបតេយ្យ ។ ខ្ញុំអត់បាននឹកឃើញឧបសគ្គអ្វីទាំងអស់ ឬ អំពីបរាជ័យអ្វីនៅក្នុងការតស៊ូនេះឡើយ ។ ម្យ៉ាងទៀត ខ្ញុំក៏មិនមានគំនិតអ្វីជាក់លាក់ថាតើការតស៊ូរំដោះជាតិនេះត្រូវការពេលវេលាវែងរហូតដល់ណាដែរទេ ។ ក៏ប៉ុន្តែ ខ្ញុំមានគំនិតមួយយ៉ាងសាមញ្ញគឺ ខ្ញុំនឹងដាក់ផុកជីវិតខ្ញុំក្នុងរយៈពេល ១០ ឆ្នាំ ។ ខ្ញុំស្ម័គ្រចិត្តចំណាយពេល ១០ ឆ្នាំដើម្បីមកបំរើចលនាតស៊ូ ជាពិសេស រ.ជ.រ.ប.ខ. ដោយគ្មានគំនិតចង់បានអ្វីក្រៅតែចង់ឃើញទឹកដីដូនតាខ្មែរមកជាទឹកដីខ្មែរវិញ និង ប្រជាពលរដ្ឋខ្មែរមានសិទ្ធិសំរេចវាសនាខ្លួនដោយខ្លួនឯងតែប៉ុណ្ណោះ ។ មែនទែនទៅ គំនិតខ្ញុំនាសម័យនោះជាគំនិតផ្សងព្រេងពេកណាស់ ។ ដំណឹងដែលថា ម្ដាយខ្ញុំនៅរស់រានមានជីវិតនៅឡើយ ធ្វើឲ្យខ្ញុំមានកម្លាំងចិត្តយ៉ាងខ្លាំង ។ ខ្ញុំគិតថាអំណើះតទៅ ខ្ញុំក៏អាចចូលទៅជួយរំដោះម្ដាយបង្កើតខ្ញុំ និង ទៅចូលរួមរំដោះទឹកដីកំណើតរបស់ខ្ញុំមកវិញផង ។ មកដល់ចំណុចនេះខ្ញុំហាក់ដូចជាមានកាតព្វកិច្ចមួយដែលត្រូវតែបំពេញ ជាពិសេសនៅពេលដែលខ្ញុំនឹកដល់សំបុត្ររបស់បងស្រី ទេពធីតា ដែលសរសេរជាអាទិថា៖ "ទោះជាត្រូវជន្លៀសទៅនៅស្រុកស្រែក៏ដោយ ក៏ពុក(ឪពុករបស់ខ្ញុំ)នៅតែថ្វាយបង្គំព្រះសំបូងសំរូងបន់ស្រន់សូមឲ្យទេវតា និង វត្ថុសក្ដិសិទ្ធិទាំងឡាយក្នុងលោកតាមជួយថែរក្សារូបប្អូន(រូបខ្ញុំ) ឲ្យបានសេចក្ដីសុខគ្រប់ប្រការដើម្បីប្អូន អាចមកជួយរំដោះពួកយើងឲ្យរួចពីកណ្ដាប់ដៃពួកផ្ដាច់ការ...." ។

## ខកចិត្ត ពេលជាន់ទឹកដីថៃ ថ្ងៃដំបូង

នៅព្រឹកថ្ងៃទី ១៩ ឧសភា ១៩៨២ យន្តហោះរបស់យើងក៏បានមកចុះចតនៅអាកាសយានដ្ឋានដនមឿង ទីក្រុងបាងកកនៃប្រទេសថៃ ។ មិនដូចជាអ្នក

ដំណើរធម្មតាឯទៀតៗទេ ពួកយើងមានមនុស្សរង់ចាំនៅជណ្តើរយន្តហោះ ។ នៅជាមួយមន្ត្រីថៃម្នាក់ ខ្ញុំក្រឡេកឃើញលោក នាង ជិនហន អគ្គលេខាធិការ រ.ជ.រ.ប.ខ. កំពុងនាំគ្នាចាំទទួលពួកយើង ។ បន្ទាប់ពីសំដែងការគួរសមរវាងគ្នារួចហើយ លោក នាង ជិនហន (និយាយជាភាសាបារាំងដ៏ឥតខ្ចោះរបស់គាត់) បានបង្ហាញពួកយើងដល់មន្ត្រីថៃនោះ ដែលមានឋានន្តរសក្តិជាវរសេនីយឯក (សក្តិប្រាំ) តែមានសំលៀកបំពាក់ស៊ីវិល ។ លោកសក្តិប្រាំថៃនេះជាមន្ត្រីយោធាដែលមានតួនាទីមើលការខុសត្រូវលើក្រុមអ្នកតស៊ូរ.ជ.រ.ប.ខ.យើង ។ គាត់មានទឹកមុខញញឹមញញែមរាក់ទាក់នឹងពួកយើងណាស់ ។ យើងស្គាល់តែឈ្មោះសំងាត់របស់គាត់ដែលគាត់ប្រើប្រាស់សំរាប់ធ្វើទំនាក់ទំនងជាមួយពួកយើងតែប៉ុណ្ណោះ យើងមិនស្គាល់ឈ្មោះពិតប្រាកដរបស់គាត់ទេ ។ ពួកយើងត្រូវបានណែនាំឲ្យហៅលោកសក្តិប្រាំថា៖ "លោក ម៉ុល" ។

លោក ម៉ុល ប្រមូលលិខិតឆ្លងដែនរបស់យើងយកទៅបោះត្រាទិដ្ឋាការនៅការិយាល័យអន្តោប្រវេសន៍ រួចនាំពួកយើងទៅយកវ៉ាលីស ។ បន្ទាប់មក គាត់នាំពួកយើង ដើរទៅរករថយន្តដ៏ចំណាស់របស់គាត់ ។ ទោះជាមានឋានន្តរសក្តិរហូតដល់ថ្នាក់វរសេនីយឯក ដែលជាឋានៈដាន់ខ្ពស់មួយរបស់កងទ័ពថៃយ៉ាងណា ក៏ដោយ ក៏លោក ម៉ុល មិនមានអ្នកបើកបរទេ ។ គាត់បររថយន្តដោយខ្លួនឯង ។ លោក ម៉ុល នាំពួកយើងមកឆ្ងាយពីព្រលានយន្តហោះដនមឿង ឆ្ពោះទៅកាន់តំបន់មួយឈ្មោះបាងកកណយ ។ បន្ទាប់ពីឆ្លងកាត់ផ្លូវដ៏ចង្អៀតជាច្រើន យើងក៏ចូលផ្លូវធំមួយឈ្មោះ ចារ៉ាន់ សានិតវង្ស (Charan Sanitwong) រួចបត់ចូលច្រកមួយឈ្មោះ "សយ" (Soi) លេខ ២២ គឺ សយ រដ្ឋាសា (Soi 22 Rathasa) ។ ចូលតាមច្រកនោះ ប្រហែលមួយរយម៉ែត្ររថយន្តក៏ឈប់នៅមុខភូមិគ្រឹះមួយ ដែលមានរបងព័ទ្ធជុំវិញយ៉ាងជិត ដែលគេពុំអាចមើលឃើញសកម្មភាពអ្វីនៅខាងក្នុងបរិ

វេណបានឡើយ ។ ភ្លាមនោះទ្វាររបងក៏បើកឡើង លោក ម៉ុល បររថយន្តចូលទៅឈប់ខាងក្នុង ។ យុវជនខ្មែរពីរនាក់ ចេញមកទទួលពួកយើង និង ជញ្ជូនវ៉ាលីសចេញពីរថយន្ត ។ ទីបំផុត ពួកយើងក៏បានធ្វើដំណើរមកទីដៅរបស់យើង ។

ភូមិគ្រឹះនេះ ដែលមានលក្ខណៈមិនប្លែកពីផ្ទះអ្នកស្រុកសាមញ្ញឯទៀត នៅក្នុងតំបន់នោះ ជាទីស្នាក់ការធំរបស់ រ.ជ.រ.ប.ខ. និង និវេសនដ្ឋានរបស់លោកតាសឺន សាន និង សហការីសំខាន់ៗរបស់លោកតាប្រចាំនៅទីក្រុងបាងកក ។ ផ្ទះនេះត្រូវបានជួលពីមន្ត្រីយោធាថៃមួយរូបទៀតគឺ លោកវរសេនីយឯក ស៊ុជិនដា ក្រាប្រាយង្គ (Suchinda Krapayung) ដែលនៅពេលនោះ មានតួនាទីជានាយទាហានទី២ បន្ទាប់ពីលោកឧត្តមសេនីយ ឆាវលិត ។ នៅទសវត្សរ៍ឆ្នាំ ១៩៩០ លោកស៊ុជិនដា ឡើងឋានៈរហូតដល់នាយឧត្តមសេនីយ (ផ្កាយ ៤) និង ឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីផង ។ ចំណែកលោក ម៉ុល វិញ ក្រោយមក ទើបយើងដឹងឈ្មោះពិតប្រាកដថា សុម៉េធ ទៀនផេង (Sumet Tiengpheng) ។ ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ គាត់ឡើងដល់ឧត្តមសេនីយត្រី (ផ្កាយ២) រហូតដល់ចូលនិវត្តន៍ ។ តាមភាសាថៃ គេហៅត្រឹមឧត្តមសេនីយត្រី តែតាមពិតមានផ្កាយពីរ ព្រោះ ក្នុងកងទ័ពថៃគ្មានសក្តិផ្កាយមួយទេ នៅក្រោមផ្កាយពីរមានតែថ្នាក់វរសេនីយឯកពិសេសតែប៉ុណ្ណោះ ។

ពួកយើងមកដល់ចំពេលអ្នកនៅក្នុងផ្ទះ កំពុងស្រស់ស្រូបអាហារពេលព្រឹក ។ នៅតុបាយ ខ្ញុំក្រឡេកឃើញលោកឧត្តមសេនីយ សក់ ស៊ុតសាខន កំពុងអង្គុយពិសាកាហ្វេផង និង ជក់បារីហុយទ្រលោមផង ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ធ្លាប់ធ្វើជាមេដឹកនាំកំពូលចុងក្រោយគេបង្អស់នៃរបបសាធារណរដ្ឋរបស់លោក លន់ នល់ ។ បន្ទាប់ពីការដួលរលំនៃរបបសាធារណរដ្ឋ លោកឧត្តមសេនីយបានទៅរស់នៅមួយរយៈឯសហរដ្ឋអាមេរិក ។ ប៉ុន្មានខែមុន គាត់បានស្ម័គ្រចិត្ត

មកបំរើរ.ជ.រ.ប.ខ. ។ នៅពេលដែលលោកឧត្តមសេនីយកំពុងពិសាកាហ្វេនោះ យើងក៏ដឹងថា នៅឯជាន់ខាងលើផ្ទះ លោកតា សឺន សាន កំពុងជាប់រវល់ត្រៀមចេញដំណើរទៅទីក្រុងតូក្យូនៃប្រទេសជប៉ុន ។ ពេលឃើញពួកយើងភ្លាម អ្នកស្រី សួន កាសេត មានសេចក្តីត្រេកអរណាស់ ជាពិសេស ពេលឃើញបង ប៉ែន ថាល់ ដែលអ្នកស្រីធ្លាប់ស្គាល់ជាយូរមកហើយ ។ អ្នកស្រី សួន កាសេត ហៅបង ប៉ែន ថាល់ ថា "បងថាល់ៗ" យ៉ាងពេញមាត់ បង្ហាញពីភាពស្និទ្ធស្នាលរវាងអ្នកទាំងពីរ ។ អ្នកស្រីក៏ត្រូវប្រញាប់ចេញដំណើរជាមួយលោកតា សឺន សាន ទៅទីក្រុងតូក្យូដែរ ។ លោកតា សឺន សាន ក៏មានការរីករាយ ដោយឃើញយើងមកដល់ តែលោកតាគ្មានពេលនិយាយលេងជាមួយពួកយើងឲ្យបានច្រើនទេ ព្រោះប្រញាប់ចេញដំណើរ ។ លោកតាផ្តាំឲ្យបង ប៉ែន ថាល់ ទៅសំរាកនៅក្នុងបន្ទប់ជាមួយគាត់ ព្រោះនៅមានគ្រែទំនេរមួយ ។ ចំណែករូបខ្ញុំ លោកតាទុកឲ្យអគ្គលេខា នាង ជិនហន ចាត់ចែងរកកន្លែងឲ្យ ។ ក៏ប៉ុន្តែលោកអគ្គលេខា ហាក់ដូចជាមិនសូវរវល់អើពើអ្វីប៉ុន្មានទេ ។ គាត់និយាយបែបប្រហើរថានៅខាងលើបែបមានកន្លែងទំនេរ ។ លោក ប៊ុន សាយ និង លោក ហ៊ីង គន្ថុន ដែលយើងធ្លាប់មានទំនាក់ទំនងល្អជាមួយគ្នា ក៏ហាក់ដូចជាមិនសូវអើពើចំពោះវត្តមានរបស់ពួកយើងដែរ ។ ពួកគាត់និយាយមករកពួកយើងបែបចុងមាត់ចុងក ។ សំដែងភាពរាក់ទាក់ជាងគេមករកខ្ញុំ ហាក់ដូចជាធ្លាប់ស្គាល់គ្នាជាយូរមកហើយគឺលោកឧត្តមសេនីយ សក់ ស៊ុតសាខន ។ លោកឧត្តមសេនីយប្រាប់ឲ្យខ្ញុំនៅជាមួយគាត់នៅជាន់ខាងលើ ។ នៅពេលដែលគណៈប្រតិភូចេញទៅព្រលានយន្តហោះផុតទៅ ដោយមានលោក ម៉ុល ជាអ្នកជូនដំណើរផង ពួកយើងក៏នាំគ្នាឡើងទៅជាន់ខាងលើ ។ បង ប៉ែន ថាល់ ចូលទៅក្នុងបន្ទប់របស់លោកតា សឺន សាន ដែលនៅជ្រៅទៅខាងក្នុងផ្ទះ ហើយដែលនៅចំពីមុខបន្ទប់មួយទៀតជាទីដែលលោក ហ្គាហ្វា ស្នាក់នៅផង ធ្វើការផង ។ ខ្ញុំ និង លោកឧត្តមសេនីយ សក់

ស៊ុតសាខន ស្នាក់នៅក្នុងបន្ទប់ដែលទំនងជាបន្ទប់ទទួលភ្ញៀវដ៏ធំល្វឹងល្វើវ ព្រោះគ្មានតុទូអ្វីទាំងអស់ លើកលែងតែគ្រែបត់មួយ និង ទូខោអាវរុំព័ទ្ធដោយសំពត់កៅស៊ូមួយដែលជារបស់ផ្ទាល់ខ្លួនរបស់លោកឧត្តមសេនីយ ។ នៅជាន់ខាងក្រោម គេបានរៀបចំឲ្យមានបន្ទប់ទទួលភ្ញៀវ ដែលនៅទីនោះលោកតា សឺន សាន អាចទទួលភ្ញៀវសំខាន់ៗបាន ។ ជាមួយនោះដែរក៏មានបន្ទប់ប្រជុំ និង ការិយាល័យរបស់លោកអគ្គលេខា នាង ជិនហាន និង បុគ្គលិករបស់គាត់ ព្រមទាំងបន្ទប់បាយ និង បន្ទប់ទឹក ។

ឥឡូវនៅជាន់ខាងលើ ខ្ញុំអាចទម្រេតខ្លួនបានព្រោះមានកន្លែងទូលំទូលាយ ប៉ុន្តែគ្មានខ្នើយ ភួយ មុង កន្ទេល ពូក ឬ កន្សែង ឬ ក្រមាឡើយ ។ ដូច្នេះសេចក្តីត្រូវការជាបន្ទាន់របស់ខ្ញុំគឺ ត្រូវប្រញាប់ប្រញាល់ទៅផ្សារ ដើម្បីស្វែងរកទិញរបស់ប្រើប្រាស់ដ៏ជាចាំបាច់ទាំងនោះ ។ យុវជនម្នាក់ ក្នុងចំណោមយុវជនពីរនាក់ ដែលបានបើកទ្វាររបងចាំទទួលស្វាគមន៍ពួកយើង បានសុខចិត្តនាំខ្ញុំទៅទិញរបស់របរទាំងអស់នោះ នៅឯផ្សារក្នុងតំបន់ក្បែរផ្ទះ ។ យុវជននោះ ជាជនពិការដាច់ជើងម្ខាងដោយសារគ្រាប់មីនឈ្មោះ សុវណ្ណ ។ សុវណ្ណ មានរាងមាំ សម្បុរខ្មៅលក្ខណៈខ្មែរ ទឹកមុខញញឹម និយាយមករកពួកយើងដោយមានការគួរសមជានិច្ច ។ សុវណ្ណចេះនិយាយភាសាថៃបានយ៉ាងស្ទាត់ជំនាញ ។ សុវណ្ណ បានត្រូវអនុញ្ញាតឲ្យមករស់នៅៗទីស្នាក់ការកណ្តាលរបស់រ.ជ.រ.ប.ខ. នៅទីក្រុងបាងកក ព្រោះនោះគឺជាគុណបំណាច់ចំពោះពលីកម្ម ដែលយុវជននេះបានបំពេញជូនរណសិរ្ស ។ ក្នុងភាពយុវវ័យ ទោះបីជាទទួលរងគ្រោះដាច់ជើងយ៉ាងណាក៏ដោយ ក៏យើងហាក់មើលមិនឃើញនូវពិការភាពរបស់គេដែរ ព្រោះសុវណ្ណពាក់ជើងសិប្បនិមិត្ត និង ដើរបានស្មើល្អដូចមនុស្សធម្មតាយ៉ាងដូច្នោះ ។

ខ្ញុំទៅទិញអីវ៉ាន់ប្រើប្រាស់ ដោយចាយវាយប្រាក់ផ្ទាល់ខ្លួនឯងព្រោះខ្ញុំគិតថានេះជារឿងកំប៉ិកកំប៉ុកផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ ធាតុអាកាសពេលព្រឹកនៅទីក្រុង

បាងកក ហាក់ដូចជាក្តៅស្អុះស្អាប់ខ្លាំងណាស់ ព្រោះខ្ញុំខានជួបរដូវក្តៅបែបនេះអស់រយៈពេលជាង ៩ ឆ្នាំមកហើយ ។ ខ្ញុំបែកញើសជាប់ ដូច្នេះជាញឹកញយខ្ញុំតែងតែបបួលអ្នកដើរជាមួយឲ្យចូលក្នុងហាង ឬ ទីកន្លែងណាដែលមានម៉ាស៊ីនត្រជាក់ ។ ក៏ប៉ុន្តែ ដោយហេតុថាពួកយើងដើរតាមផ្លូវតូចៗនោះ រានលក់អីវ៉ាន់ទាំងឡាយគ្មានម៉ាស៊ីនត្រជាក់ទេ ដូច្នេះទាល់តែពួកយើងដើរទៅតាមផ្លូវធំៗ ទើបមានហាង និងសណ្ឋាគារ ឬ អាគារដែលមានម៉ាស៊ីនត្រជាក់ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំចូលចិត្តគយគន់មើលមនុស្សម្នាទាំងឡាយដែលកំពុងធ្វើដំណើរកកកុញតាមផ្លូវ ។ ព្រោះខ្ញុំឃើញហ្វូងមនុស្សទាំងនោះ មានមុខមាត់ហាក់ដូចជាជនជាតិខ្មែរយើងដែរ ។ នៅពេលនោះ ខ្ញុំគួរសារភាពថាសម្រស់នារីជនជាតិថៃហាក់មិនទាន់ទាក់ទាញអារម្មណ៍របស់ខ្ញុំនៅឡើយទេ ព្រោះភ្នែកខ្ញុំនៅមានទម្លាប់គាប់ចិត្តតែទៅលើនារីអឺរ៉ុបនៅឡើយ ។ ខ្ញុំមើលមិនឃើញនារីថៃស្អាតទាល់តែសោះ ។ ស្អាតយ៉ាងដូចម្តេច បើច្រមុះកំពិតៗយ៉ាងនេះ ដោយភ្លេចគិតថាខ្លួនខ្ញុំក៏មានច្រមុះកំពិតដែរ ។ នារីថៃអ្នកលក់មានអាកប្បកិរិយារួសរាយរាក់ទាក់ និង គួរសមទន់ភ្លន់គួរឲ្យចូលចិត្ត ។

សុវណ្ណ បានប្រាប់ពួកយើងឲ្យប្រយ័ត្នកុំឲ្យពួកថៃដឹងថា ពួកយើងជាជនជាតិខ្មែរ ។ ក៏ប៉ុន្តែ នៅពេលនិយាយគ្នាជាមួយសុវណ្ណនោះ យើងមិនអាចនិយាយអ្វីក្រៅពីភាសាខ្មែរបានឡើយ ព្រោះសុវណ្ណមិនចេះបារាំង ឯយើងក៏មិនចេះថៃ ។ ដូច្នេះ នៅពេលឮយើងនិយាយជាមួយ សុវណ្ណ ពួកនាងៗអ្នកលក់តែងសួរ សុវណ្ណថា និយាយភាសាអ្វី? សុវណ្ណឆ្លើយបំភ្លៃថានិយាយភាសា "ម៉ាឡេ ភូមា ឬ ហ្វីលីពីនជាដើម" ។ សុវណ្ណមិនចង់ឲ្យពួកគេដឹងថាពួកយើងជាខ្មែរ ព្រោះបើកាលណាពួកថៃដឹងថាយើងជាខ្មែរ ពួកគេនឹងមើលងាយពួកយើងភ្លាម ។ ពួកថៃ ចាត់ទុកជនភៀសខ្លួនខ្មែរ ជាមនុស្សថោកទាបជាងខ្លួន ។

ខ្ញុំចូលចិត្ត និង ជក់អារម្មណ៍លើស្ថាបត្យកម្មរបស់ថៃ ជាពិសេស វត្តអារាម និង អាគារសាធារណៈ ដែលមានរចនាបថប្រហាក់ប្រហែលខ្មែរយើងដែរ ហើយដែលខ្ញុំខានជួបប្រទះអស់រយៈពេលច្រើនឆ្នាំមកហើយ ។ បើគិតពីឆ្នាំ ១៩៧៣ ដែលខ្ញុំបានស្គាល់ទឹកដីថៃជាលើកដំបូងរហូតមក ខ្ញុំឃើញប្រទេសថៃមានការផ្លាស់ប្តូរច្រើនណាស់ មានការលូតលាស់គួរឲ្យកត់សំគាល់ ។ ចំណុចនេះ ធ្វើឲ្យខ្ញុំនឹកស្រណោះស្រុកខ្មែរ នឹកដល់ការខូចខាតរបស់ខ្មែរដែលជាមហាវិនាសកម្មមួយក្នុងរយៈពេលប៉ុន្មានទសវត្សរ៍នេះ ដោយសារសង្គ្រាម និង ដោយសារអស្ថិរភាពនយោបាយ និង អំណាចផ្តាច់ការ ។

នៅក្នុងអវត្តមានរបស់លោកតា សឺន សាន ខ្ញុំមានអារម្មណ៍ថា ពួកយើងហាក់ដូចជាមិនបានទទួលការស្វាគមន៍ឲ្យបានកក់ក្តៅឡើយ ទោះជាយើងមកដល់ចំថ្ងៃដ៏ក្តៅហែងនាខែ ឧសភា នោះយ៉ាងណាក៏ដោយ ។ កាលពីម្តៃប្បួនម៉ោងមុនពេលយើងចេញដំណើរពីទីក្រុងប៉ារីសមក សន្ទុះទឹកចិត្តយើងឡើងខ្ពស់ត្រដែតរហូតដល់យើងប្តេជ្ញាថាលះបង់អ្វីៗទាំងអស់ ទាំងអាយុជីវិត ដើម្បីធ្វើការតស៊ូសង្គ្រោះប្រជាពលរដ្ឋ និង ប្រជាជាតិខ្មែរ ។ ក៏ប៉ុន្តែ ភាពប៉ក់រវើយដែលយើងបានទទួលនៅពេលមកដល់ទីក្រុងបាងកក បានធ្វើឲ្យខ្ញុំសន្និដ្ឋានថាអ្នកដែលមកមុនយើង ប្រហែលមិនជឿថាយើងមកធ្វើការតស៊ូដើម្បីជាតិទេ ពួកគេគ្មានជំនឿលើសុឆន្ទៈរបស់ពួកយើងឡើយ ។ អ្នកទាំងនោះ ប្រហែលជាយល់ថាពួកយើងអាចនឹងធ្វើឲ្យពួកគេបាត់បង់មុខមាត់ បុណ្យសក្តិ ឬ ឥទ្ធិពលដែលគេកំពុងមាននៅក្នុងរង្វង់រ.ជ.រ.ប.ខ.មិនខានឡើយ ។ ពួកគេប្រហែលជាយល់ថាពួកយើងអាចមកដណ្តើមតួនាទី ឬ ការងាររបស់ពួកគេមិនខានឡើយ ។ មែនទែនទៅ នៅពេលនោះមិនមែនតែពួកយើងដែលទើបមកថ្មីនេះទេ ដែលពួកគេមានការសង្ស័យ សូម្បីតែឧត្តមសេនីយ សក់ ស៊ុតសាខន ដែលមកដល់មុនពួកយើង ក៏ទទួលស្វាគមន៍ដ៏

សោះកក្រោះមិនខុសពីពួកយើងដែរ ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន អតីតអ្នកទទួលខុសត្រូវខ្ពស់បំផុតជាចុងក្រោយនៃរបបសាធារណរដ្ឋខ្មែរ ក៏បានជួប បញ្ហាមិនទុកចិត្តគ្នានេះដែរ ពីសំណាក់យុទ្ធមិត្តដែលបានចូលមកធ្វើការមុន ។ ពួក គេវាយតម្លៃពួកយើងថា ជាមនុស្សរបស់លោកតា សឺន សាន មិនមែនមកធ្វើការ តស៊ូក្នុងគំនិតលះបង់អ្វីទេ តែទំនងជាមកតាមផែនការពង្រឹងក្រុមលោកតាប្រឆាំង តទល់ជាមួយក្រុមមួយ ទៀតគឺ ពួកកូម៉ិច ដែលមាន លោក ដៀន ដែល លោក ហ៊ីង គន្ថុន និង លោក នាង ជិនហន ជាមេខ្លោង ។ ជាសំណាងល្អដែរដែល បង ប៉ែន ថាល់ ធ្លាប់ស្គាល់ និង មានភាពជិតស្និទ្ធជាមួយអ្នកទាំងបីនាក់នោះ ទើប ទីបំផុតពួកអស់លោកទាំងនោះ បានទទួលស្គាល់រូបខ្ញុំថាជា "ប្អូនប្រុសម្នាក់របស់ ប៉ែន ថាល់" ។

ច្បាស់ណាស់ហើយថាក្រុមយោធាថៃបានអនុញ្ញាតឲ្យអ្នកដឹកនាំរ.ជ.រ.ប.ខ. រស់នៅ និង ដឹកនាំចលនាតស៊ូពីទីក្រុងបាងកក ។ អ្នកដឹកនាំរបស់យើងសម័យ នោះធ្វើដំណើរញឹកញាប់ពីបាងកកទៅទល់ដែនខ្មែរថៃ ឬ ទៅក្នុងទឹកដីខ្មែរតែម្តង ។ កាលពួកយើងនៅទីក្រុងប៉ារីស ពេលណាគេនិយាយអំពីតំបន់រំដោះ ឬ អំពីធ្វើការ ក្នុងតំបន់រំដោះ យើងមិនដែលគិតថា តំបន់រំដោះទាំងនោះមានរួមទាំងទីក្រុងបាង កកឡើយ ។ យើងស្មានតែតំបន់រំដោះទាំងអស់សុទ្ធតែនៅក្នុងទឹកដីខ្មែរទាំងអស់ ។ តាមការគ្រប់គ្រងរបស់យោធាថៃ ពួកយើងត្រូវរស់នៅក្នុងផ្ទះសុវត្ថិភាពមួយ ដែល មានការការពារ ឬ យាមកាមដោយយោធាថៃម្នាក់ ឬ ពីរនាក់ស្លៀកពាក់ជាជនស៊ី វិល និង ដែលគ្មានកាន់អាវុធ ។ យោធាថៃនោះអាចធ្វើជាអ្នកយាមការពារយើងផង ឬ អាចធ្វើជាអ្នកបើកបរឲ្យយើងផង ។ យើងមិនអាចចេញក្រៅផ្ទះ ដែលយើងហៅ ថាផ្ទះសុវត្ថិភាព ដោយគ្មានការអនុញ្ញាត ឬ ដោយគ្មានការជូនដំណើរពីយោធាថៃ យ៉ាងហោចណាស់ក៏មួយនាក់បានឡើយ ។ ជាទូទៅ ពួកយើងអាចចេញក្រៅផ្ទះ

បានតាមរថយន្ត ដោយមានយោធាថៃជាអ្នកបើកបរឲ្យឬទៅជាមួយពួកគេ ។ យើងមានទម្លាប់ហៅអ្នកបើកបរឲ្យយើងនោះ ដែលជាយោធាថា "ហួណា" ។ ពាក្យថៃ "ហួ" មានន័យថា "ក្បាល" រីឯពាក្យ "ណា" ថា "មុខ" បានន័យថា "អ្នកដឹកមុខ" ឬ "អ្នកដឹកនាំ" ។ ដោយសារពួកយើងស្ថិតនៅក្រោមការគ្រប់គ្រងរបស់យោធាថៃ យើងហៅទាហានថៃទាំងអស់ថា "ហួណា" គឺ តាំងពីអ្នកបើកបររហូតដល់លោក ម៉ុល ឬ ឧត្តមសេនីយ ឆាវលិត ថា ហួណា ហួណា ទាំងអស់ ។

នៅសម័យនោះ រដ្ឋាភិបាលថៃមានគោលនយោបាយប្រឆាំងយ៉ាងខ្លាំងក្លាចំពោះជនអន្តោប្រវេសន៍ខុសច្បាប់មកពីប្រទេស កម្ពុជា លាវ និង វៀតណាម ។ ប្រសិនបើប៉ូលីសថៃ ឆែកឆេរទៅឃើញថា ជនជាតិណាមួយ ក្នុងចំណោមជនជាតិមកពីប្រទេសទាំងបី គ្មានច្បាប់អនុញ្ញាតឲ្យស្នាក់នៅ ឬ គ្មានឯកសារបញ្ជាក់អត្តសញ្ញាណទេនោះ ជននោះនឹងត្រូវឃាត់ខ្លួនរួចបញ្ជូនទៅពន្ធនាគារតែម្តង ។ ជនជាតិខ្មែរដែលផ្សងសំណាងលបលួចរស់នៅដោយខុសច្បាប់ នៅក្រៅជំរុំកៀសខ្លួន ឬ នៅទីក្រុងបាងកក ត្រូវស្ថិតនៅក្រោមការភ័យខ្លាចជារៀងរាល់ថ្ងៃ ។ ពួកគេខ្លាចប៉ូលីសចាប់ឃុំ ឬ ចាប់ដាក់គុក ។ គួរកត់សំគាល់ថាខ្មែរយើងភាគច្រើន មានមុខមាត់ប្រហាក់ប្រហែលជនជាតិថៃដែរ ។ ពួកគេអាចធ្វើដំណើរទៅទីណាក៏បាន ប្រសិន បើគ្មានការឆែកឆេរកអត្តសញ្ញាណប័ណ្ណ ឬ ប្រសិនបើគ្មាននរណាដឹងថាជាជនជាតិខ្មែរ ។ ក៏ប៉ុន្តែ ប្រសិនបើមានថៃណានិយាយរកខ្មែរយើងដែលចេះភាសាថៃ ខ្មែរយើងនោះ អាចនិយាយថៃបាន ដោយមានសំនៀងប៉ែឡាំ ដែលអាចឲ្យគេសង្ស័យថា ជាជនបរទេសបាន ។ ជនជាតិថៃភាគច្រើនៗតែរាយការណ៍ទៅប៉ូលីសភ្លាម កាលបើដឹងថាមានជនសង្ស័យខុសច្បាប់ដូចជាខ្មែរយើងជាដើម ។ ប៉ូលីសនឹងធ្វើការឆែកឆេរភ្លាម ។ ខ្មែរយើងដែលរស់នៅខុសច្បាប់ក្នុងទឹកដីថៃ មានការភ័យខ្លាចណាស់ ។ យ៉ាងនេះ ទើប សុវណ្ណ ហាមមិនឲ្យពួកយើងភ្លាត់ភ្លេចខ្លួនឲ្យគេដឹង

ថាយើងជាជនជាតិខ្មែរ ទោះបីជាយើងមកពីប្រទេសបារាំងក៏ដោយ ។ ម្យ៉ាងយើងដើរដោយមានតែខ្មែរគ្នាយើង ដោយគ្មានទាហានថៃ "ហួណា" មកជាមួយផង ។ ម្យ៉ាងទៀត យើងក៏គ្មានឯកសារសំគាល់ខ្លួននៅជាប់នឹងខ្លួនផង ព្រោះលោក ម៉ុល ដែលបានយកលិខិតឆ្លងដែនរបស់យើង ទៅបោះត្រាទិដ្ឋាការចូលប្រទេសថៃនោះ បានទុកឯកសារនោះ មិនប្រគល់ឲ្យត្រឡប់មកយើងវិញទេ ។ ដូច្នេះ ពួកយើងក៏មានលក្ខណៈមិនខុសពីជនភៀសខ្លួនខ្មែរឯទៀត ដែលនៅក្រៅច្បាប់ដែរ ដែលប៉ូលីសថៃអាចឆែកឆេរ និង ចាប់ខ្លួនបានគ្រប់ពេលវេលា ។ ក៏ប៉ុន្តែ បន្ទាប់ពីមានការបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីរួចមក នៅឆ្នាំ ១៩៨២ ទើបលោក ម៉ុល ប្រគល់ឯកសារធ្វើដំណើររបស់យើងមកវិញទាំងអស់ ។

ចាប់ពីថ្ងៃទីមួយដែលខ្ញុំជាន់ទឹកដីថៃនៅទីក្រុងបាងកក ខ្ញុំហាក់ដូចជាចាប់ផ្តើមលោតចូលទៅក្នុងតំបន់ក្តៅគគុកនៃភ្នក់ភ្លើងសង្គ្រាម ។ ខ្ញុំគិតថា បើខ្ញុំមិនអាចធ្វើដំណើរដោយសេរីផង តើខ្ញុំអាចបំពេញបេសកកម្មរបស់ខ្ញុំដោយជោគជ័យដែរឬទេ? ខ្ញុំចេះតែគិតហើយគិតទៀតថា បើយើងស្ថិតនៅក្រោមការគ្រប់គ្រងរបស់យោធាថៃបែបនេះ តើយើងអាចពង្រីកចលនាតស៊ូរបស់យើងឲ្យធំជាត់តទៅទៀតបានឬទេ? មានសំណួរជាច្រើនចោទឡើងនៅក្នុងខួរក្បាលរបស់ខ្ញុំ ដូចជាថាតើយើងត្រូវដោះស្រាយបញ្ហាមិនយល់ចិត្តគ្នាមិនទុកចិត្តគ្នា ជាមួយសហសេវិកទាំងឡាយដែលបានចូលមកបំរើរ.ជ.រ.ប.ខ.មុនយើងយ៉ាងដូចម្តេច?ចំណោទទាំងនេះ ធ្វើឲ្យខ្ញុំខ្វល់ខ្វាយយ៉ាងខ្លាំង នេះមិនទាន់និយាយដល់រូបភាពធំនៃការតស៊ូរបស់យើងមួយទៀត គឺ សង្គ្រាមរំដោះជាតិ និង សង្គ្រាមទប់ទល់កុំឲ្យពួកខ្មែរក្រហមវិលត្រឡប់មកកាន់អំណាចវិញផង ។ ដោយសារធាតុអាកាសក្តៅផង ដោយសារខុសពេលវេលាគ្នារវាងម៉ោងពេលប្រទេសបារាំង និង ប្រទេសថៃផង ខ្ញុំដេកមិនលក់សោះ ។ ជាមួយនោះ នៅមានសម្លេងរំខានរបស់ "តុកតុក" រថកង់បី ដែលបើកកាត់មុខផ្ទះមិនដាច់

មកបន្ថែមទៀត ។ ជាការគួរឲ្យចាប់អារម្មណ៍ រាល់រថកង់បី "តុកតុក" តែងតែរពាទ៍ម៉ាស៊ីនបង្កើនល្បឿន នៅពេលមកដល់ផ្ទះរបស់ពួកយើង ។ ទោះយ៉ាងណាក៏ដោយ ខ្ញុំសំរេចចិត្តប្តេជ្ញាធ្វើអ្វីៗក្នុងឋានៈជាកុលបុត្រម្នាក់របស់កម្ពុជា ។ រាល់បញ្ហាសុទ្ធតែមានដំណោះស្រាយ ទោះតាមរូបភាពអ្វីក៏ដោយ ។



លោកតា យិន អ៊ុច (ជីតាខ្ញុំខាងម្តាយ) ១៨៩០?-១៩៥០
(លោកតា ទទួលមរណភាពនៅពេលខ្ញុំនៅជាទារកនៅឡើយ)



លោកយាយ ហ៊ូ ឱ (ជីដូនខ្ញុំខាងឪពុក)
(លោកយាយទទួលមរណភាពច្រើនឆ្នាំ
មុនខ្ញុំចាប់កំណើតមកម្ល៉េះ)



លោកយាយ អ៊ុង គូ
(ជីដូនខ្ញុំខាងម្តាយ ១៨៩៥-១៩៧៩
លោកយាយទទួលមរណភាពក្នុងជន្មាយុ ៨៤ ឆ្នាំ
ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩)



ឪពុកខ្ញុំឈ្មោះ អៀង មុត ( ១៩១៥ -១៩៧៥ )
( ទទួលមរណភាពនៅសម័យ ប៉ុល ពត ដោយអត់អាហារក្នុងជន្មាយុ ៦០ ឆ្នាំ )



ម្ដាយខ្ញុំឈ្មោះ អ៊ុច សុខា (១៩២៦-២០១២)
(ទទួលមរណភាពក្នុងជន្មាយុ ៨៦ ឆ្នាំ ដោយជរាពាធ)





បងប្រុសទី១ ឈ្មោះ អៀង ឈឿន
( ហៅបងនាង ស្លាប់កាលអាយុ ៣២ ឆ្នាំ )

បងប្រុសទី២ ឈ្មោះ អៀង ស៊ីនឿន
( ហៅបងផាត ស្លាប់កាលអាយុ ៣០ ឆ្នាំ )





ប្អូនប្រុសឈ្មោះ អៀង ណារីន
( ស្លាប់កាលអាយុ ១៨ ឆ្នាំ )

ប្អូនប្រុសឈ្មោះ អៀង វុធៀន
( ស្លាប់កាលអាយុ ១៥ ឆ្នាំ )

( បងប្អូនទាំងអស់នេះ ត្រូវបានរបប ប៉ុល ពត យកទៅសម្លាប់ )



ក្រុមយុវនៃនៃនិស្សិតមហាវិទ្យាល័យពាណិជ្ជសាស្ត្រឆ្នាំសិក្សា ១៩៦៦-៦៨



ទស្សនកិច្ចសិក្សានៅទីក្រុងកែប នៅឆ្នាំ ១៩៦៧
រូបពីឆ្វេងទៅស្តាំគឺៈ អៀង មូលី ស៊ុន សារ៉ុម នូ វ៉ាន់ថន
និង សារុន ឈឿន

កន្លែងហ្វឹកហាត់នៃកងទ័ពចលនាតស៊ូមិនមែនកុម្មុយនីស្ត នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០
នៅតំបន់ភ្នំបន្ទាត់ មុនការបង្កើតកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ



ប្រជាពលរដ្ឋខ្មែរដែលជួបប្រទះភាពអត់ឃ្លាន នាំគ្នាធ្វើដំណើរមកកាន់តំបន់ជាយដែន
ខ្មែរ-ថៃ ដើម្បីស្វែងរកជំនួយខាងផ្នែកស្បៀង និង ថ្នាំសង្កូវ បន្ទាប់មក
គេនាំគ្នាដឹកជញ្ជូនជំនួយមនុស្សធម៌ទាំងនោះចូលមកក្នុងប្រទេសវិញ





អតីតនាយទាហានជាន់ខ្ពស់នៃរបបសាធារណរដ្ឋ និង អ្នកតស៊ូមួយចំនួន
កំពុងជួបជុំគ្នានៅទីក្រុងបាងកកប្រទេសថៃ នៅដើមឆ្នាំ ១៩៧៩
ដើម្បីសិក្សារកវិធីបង្កើតកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ
រូបពីឆ្វេងទៅស្តាំ ទី១ លោក អ៊ឹម ឈូដេត ទី២ លោក ចក់ បូរី និង ទី៣ លោក ដៀន ដែល
( កំពុងអានឯកសារ ) រូបនៅខាងស្តាំបំផុត ( កំពុងអានឯកសារដែរ ) លោក កែវ ជួន
ប្រធានចលនាបក្សីចាំក្រុង មានជំរុំនៅក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ក្បែរស្រុកណាំយឺន
ខេត្តឧប៊ុនរ៉ាចថានី ប្រទេសថៃ



ពីឆ្វេងទៅស្តាំរូបទី៣ លោក អ៊ឹម ឈូដេត  លោក សេក សំអៀត
លោក ដៀន ដែល និង លោក កែវ ជួន



លោក ងៀន ដែល ( ពាក់វ៉ែនតា ) ចែកអំណោយដល់ជនភៀសខ្លួនខ្មែរនៅដើមឆ្នាំ ១៩៨០
( តាមបណ្ដោយទល់ដែនខ្មែរ-ថៃ )




( រូបពីឆ្វេងទៅស្ដាំ ) លោក ហ្គាហ្វា, លោក អៀជ្ជ គិមម៉េង
លោក ចក់ បូរី និង លោក ព្រុំ វិត

ពីធីសច្ចាប្រណិធានរបស់កងទ័ព នៅទសវត្សរ៍ឆ្នាំ ១៩៨០



និង ពិធីសច្ចាប្រណិធាននៃកម្មសិក្សាការីនៃសាលាសង្គ្រាមនយោបាយ



សមាជជាតិលើកទី១ នៃរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ
បានប្រារព្ធឡើងនៅលើទឹកដីខ្មែរ កាលពីខែ មេសា ១៩៨០
ដោយមានការចូលរួមពីថ្នាក់ដឹកនាំ តំណាងប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និង
អ្នកសារពត៌មានអន្តរជាតិ



រូបពីឆ្វេងទៅស្តាំនៅជួរខាងមុខ៖ លោក អ៊ឹម ឈូដេត លោក ហ៊ីង គុន្ទុន
លោក ដៀន ដែល (ក្នុងឯកសណ្ឋានយោធា) និង លោកតាប្រធាន សឺន សាន
កំពុងថ្លែងទៅកាន់អង្គសមាជ



នៅទសវត្សរ៍ឆ្នាំ ១៩៧០ មានការជួបជុំបងប្អូនខ្មែរ នៅទីក្រុង ម៉ង់ ឡាស្ចូលី
( Mantes-la-Jolie ) ប្រទេសបារាំង



រូបពីស្តាំទៅឆ្វេង៖ រូបទី១ លោក ឡុក សែម ទី២ រូបអ្នកនិពន្ធ ( អៀង មូលី )
ទី៣ លោក ផាន់ សូរីយាស៊ី និង រូបទី ៤ លោក សុខ ឱវច្ន័ន




ដំណើរកំសាន្ត ក្នុងទសវត្សរ៍ឆ្នាំ ១៩៧០  នៅទីក្រុងមាត់សមុទ្រ ឌៀព ( Dieppe )
រូបថតអ្នកនិពន្ធរាប់ពីឆ្វេងទៅស្តាំ ទី៣ អង្គុយជួរខាងមុខ

សកម្មភាពបំរើរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ នៅប្រទេសបារាំង និង អឺរ៉ុប



វាគ្មិនក្នុងអង្គប្រជុំផ្តល់ព័ត៌មាន ជូនជនរួមជាតិខ្មែរនៅទីក្រុងប៉ារីស នារដូវក្តៅឆ្នាំ ១៩៨០
រូបពីឆ្វេងទៅស្តាំ៖ ទី១ អ្នកនិពន្ធ (អៀង មូលី)
ទី២ លោកអតីតនាយករដ្ឋមន្ត្រី ស៊ឹម វ៉ា ទី៣ លោកអតីតរដ្ឋមន្ត្រីទី១ សឺន សាន
និង ទី៤ លោកអតីតនាយករដ្ឋមន្ត្រី ឈាន វ៉ម



សន្និសីទកាសែតនៅប្រទេសហុល្លង់រួមជាមួយលោកតា សឺន សាន




ចូលរួមក្នុងគណៈប្រតិភូ រ.ដ.រ.ប.ខ. ទៅប្រជុំអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក
នាទសវត្សរ៍ឆ្នាំ ១៩៨០ (ថតជាមួយលោក ចាយ សេរីវុឌ្ឍ)



ដឹកនាំគណប្រតិភូមកពីសាយធូ ទៅចូលរួមប្រជុំនៅប្រទេសបារាំងឆ្នាំ ១៩៨៤
រូបជួរទី១ និង ទី២ ពីស្តាំទៅឆ្វេង ភិក្ខុ ហេង មណីចិន្តា និង អ្នកនិពន្ធ (អៀង មូលី)

នៅទីស្នាក់ការ រ.ជ.រ.ប.ខ. នៅម៉ាយ៉ាឡាប់ ទីក្រុងបាងកក នៅពេលទទួលទានអាហារ
ពេលព្រឹក (ឆ្នាំ ១៩៨៣)




រូបពីឆ្វេងទៅស្តាំៈ ទី១ លោកឧត្តមសេនីយ សក់ ស៊ុតសាខន (កំពុងអានសារពត៌មាន)
ទី២ លោក ប៉ែន ថាល់ និង ទី៣ លោក ស៊ូ គិមស៊ុន



អ្នកនិពន្ធ (អៀង មូលី) កំពុងថ្លែងទៅកាន់ជនភៀសខ្លួន នៅជំរុំណាំយឺន ឬ បក្សីចាំក្រុង
នៅពេលដែលលោក ប៉ែន ថាល់ និង កែវ ជួន អង្គុយស្តាប់ជាមួយអ្នកដឹកនាំឯទៀត (ឆ្នាំ ១៩៨៣)

## រូបភាពសំណង់ខ្លះ នៅក្នុងជំរុំអំពិល នៅឆ្នាំ ១៩៨៤ នៅលើទឹកដីខ្មែរ




សេនាធិការរបស់តំបន់ប្រតិបត្តិការសឹក ២០៣




សាលាបឋមសិក្សាស្រោចស្រង់

សកម្មភាពទ្រទ្រង់ព្រះពុទ្ធសាសនានៅជំរំ សាយធូ ទសវត្សរ៍ឆ្នាំ ១៩៨០-១៩៩០



រូបអ្នកនិពន្ធ ថ្លែងសង្កថា នៅពេលដែលព្រះគ្រូ ពិន សែម និង លោក ប៉ែន ថុល កំពុងស្តាប់





ពិធីចែកសញ្ញាបត្រនៅជំរំសាយធូ

ទស្សនកិច្ចរបស់អ្នកនិពន្ធ (អៀង មូលី) នៅជំរុំប្រទ្ធិសែន (ឆ្នាំ ១៩៨៤)



កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ នៅជំរុំសាយធូ (ឆ្នាំ ១៩៨៥)



# ដំណើរទស្សនកិច្ចនៅក្នុងតំបន់រំដោះ



ការពិភាក្សាជាមួយលោកមេបញ្ជាការ ខូ ឈា នៅទីបញ្ជាការឈានមុខក្នុងទឹកដីខ្មែរចម្ងាយ ៤ គ.ម ពីជំរុំសាយធូ មុននឹងធ្វើដំណើរចូលទៅក្នុងតំបន់បន្ទាយឆ្មារ-ថ្មពួក (ខែធ្នូ ១៩៩០)



យើងធ្វើដំណើរតាមម៉ូតូ

# ទស្សនកិច្ចនៅក្នុងតំបន់រំដោះ



រូបពីឆ្វេងទៅស្តាំ ៖ រូបទី២ លោកបណ្ឌិត ឡៅ ម៉ុងហៃ រូបទី៤ លោក ប៉ែន ថុល រូបទី៥ លោក ឡាយ ខែក រូបទី៦ លោក សុគន្ធ រូបទី៧ អ្នកនិពន្ធ (អៀង មូលី) (ខែធ្នូ ១៩៩០)



អ្នកនិពន្ធ (អៀង មូលី)
និង លោក ឡាយ ខែក
កំពុងពិនិត្យការខ្វះខាត
ពាងស្តុកទឹក
នៅតំបន់ថ្មពួក



នៅឆ្នាំ១៩៩០ បានទទួលយុទ្ធជនដែលចូលមករួបរួម ឈប់ច្បាំងគ្នានៅលើទឹកដីខ្មែរ



ត្រួតពិនិត្យគ្រឿងសព្វាវុធដែលប្រមូលបានពីទីលានប្រយុទ្ធ



ចុះសួរសុខទុក្ខប្រជាពលរដ្ឋនៅតំបន់ថ្មពួក បន្ទាយឆ្មារ ឆ្នាំ ១៩៩០



លើកទឹកចិត្តកុមារឲ្យខំរៀនសូត្រ

ទស្សនកិច្ចនៅតំបន់រំដោះ (ថ្មពួក-បន្ទាយឆ្មារ ខែ ធ្នូ ១៩៩០)





# ទស្សនកិច្ចនៅប្រាសាទ បន្ទាយឆ្មារ



នេះជាទស្សនកិច្ចលើកទី៣ ដែលខ្ញុំបានធ្វើនៅប្រាសាទបន្ទាយឆ្មារ លើកទី១ នៅឆ្នាំ ១៩៨៣ លើកទី២ នៅឆ្នាំ ១៩៨៩ និង នៅពេលនេះនៅឆ្នាំ ១៩៩០

